OLD VERSION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-May-2013, 11:20
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី១៧៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក ម៉ាតេអូ គ្រីប៉ា*(Mr.Matteo CRIPPA)*

លោក ស៊ីម៉ុន មេសិនប៊ឺជ
*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឃីត រេយន័រ*(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គីមសួន

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធារី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វេង ហ៊ត់ | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ហ្វីលីព ស្មូត (TCE-65) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក ហ្វីលីព ស្សុត** (TCE-65)

សួរដោយលោក វ៉េង ហ៊ាត់ ផ្ដើមពី៖ ......................................................................ទំព័រ ១
សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្ដើមពី៖.............................................................ទំព័រ ១២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយ-ការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ សូមកត់សម្គាល់ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីខាងក្រោមបន្ទប់សវនាការនេះ។ តាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។ រីឯអ្នកជំនាញដែលត្រូវបន្តផ្ដល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក ហ្វីលីព ស្សូត លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ សូមអរគុណ។

[០៩:០៣:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះអ្នកជំនាញរូបនេះ។ សូមអញ្ជើញ!

**លោក វេង ហ៊ត់៖**

អរគុណលោកប្រធាន សូមគោរពអង្គសវនាការ ក្រុមប្រឹក្សាទាំងមូល។ សួស្ដី ស្សូត ខ្ញុំឈ្មោះ វេង ហ៊ត់ មកពីការិយាល័យសហព្រះរាជអាជ្ញា។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វេង ហ៊ត់៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួនទៅកាន់លោក អ្វីដែលខ្ញុំផ្ដោតអារម្មណ៍ និងសំណួរទៅកាន់លោកនេះ គឺទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា មនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តនេះ

ឯង។ បន្ទាប់មកសហការីរបស់ខ្ញុំ ថារីក គាត់ផ្តោតអារម្មណ៍ ឬផ្តោតសំណួរទៅលើការវិវត្តន៍ជាប្រវត្តិសាស្ត្រ និងការប្រែប្រួលនៃគោលនយោបាយទាំងនេះ។ អ្វីដែលខ្ញុំបានសួរបន្ថិចទៀតនេះ គឺដកស្រង់ចេញពីសៀវភៅរបស់លោក ដែលមានចំណងជើងថា “ប៉ុល ពត: ប្រវត្តិសុបិនអាក្រក់” ហើយឯកសារនេះចៅក្រម ខាតវ៉ាយថ៍ កាលពីសម្សិលមិញ គាត់បានបញ្ចូលទៅក្នុងឯកសារ E3/9។ ដោយសារសៀវភៅរបស់លោកមិនមានជាភាសាខ្មែរទេ ខ្ញុំសូមអានអត្ថបទជាភាសា ERN អង់គ្លេសជាមួយនិងបារាំង។

ខ្ញុំសូមលើកឡើងជាដំបូង លោកបានពិពណ៌នាអំពីសារៈសំខាន់នៃសេចក្តីសម្រេចចិត្តនានាដែលគ្រោងនៅក្នុងសៀវភៅរបស់លោក។ លោកបានសរសេរថា ធ្វើឡើងនៅក្នុងខែឧសភា ឆ្នាំ៧៥ នៅឯប្រាសាទប្រាក់។ ឯកសារនេះនៅក្នុងទំព័រទី៩ -- ទី៨, ទី៩ នៃសៀវភៅរបស់លោក ដែលមាន ERN ជាភាសាអង់គ្លេស 00396200 រហូតដល់ 01, ERN ជាភាសាបារាំង 006339 -- ច្រឡំ 00639460។

[០៩:០៧:០៣]

លោកសរសេរថា “ចំពោះអ្វីៗកំពុងកើតឡើងដោយនឹកស្មានមិនដល់នេះ អ្នកសម្រេចចិត្តសម្របសម្រួលលើបដិវត្តន៍ដាច់ខាតបំផុតនៅក្នុងពិភពលោកបានប្រកាន់យកនូវការសម្រេចចិត្តដ៏ម៉ឺងម៉ាត់។ បន្ទាប់ពីការពិភាក្សារយៈពេល១០ថ្ងៃ ដើម្បីបំបែកក្រុមរណសិរ្សអួតថា ខ្លួនជាអ្នកសីហនុនិយម និងក្រុមមិនមែនកុម្មុយនីស្តដទៃទៀត ដើម្បីជួយដណ្តើមអំណាចនេះដើម្បីបោះបង់ចោលគោលនយោបាយនិយមកណ្តាល ដូចអ្វីដែលសម្ព័ន្ធមិត្តកំពុងតែប្រកាន់យក ហើយជំនួសដោយការបង្កើតនូវនយោបាយដូចពាក្យស្លោកមួយឃ្លាថា មហាអស្ចារ្យ មហាលោតផ្លោះ។ ត្រូវតែផ្លោះមួយជំហានឲ្យបានសម្រេចនូវរបបកុម្មុយនីស្តពេញលេញដោយគ្មានការសម្របសម្រួល ឬព្រមព្រៀងអ្វីឡើយ។ អ្វីដែលស្លាប់ទៅហើយត្រូវតែកប់ចោល”។

[០៩:០៨:២៨]

នៅក្នុងទំព័រទី១២ ភាសាអង់គ្លេស ERN 00396204, ភាសាបារាំង 00639465 លោកបានសរសេរថា “នៅក្នុងស្ថានភាពដ៏ហិង្សាដ៏ខ្លាំងនេះ ទោះជាក្នុងពេលសង្គ្រាម ឬបដិវត្តន៍ក៏ដោយ ប្រជាជនស្លូតត្រង់គឺជាអ្នករងគ្រោះ។ មន្ត្រីសហរដ្ឋអាមេរិកនិយាយចំណុចនៃការខ្វះខាតត្រឹមតែមួយជ្រុង។ ចំណែកម៉ៅ និយមនិយាយអំពីការបំបែកសិទ្ធិ ដើម្បីធ្វើម្ហូមអូមីលែត។ នៅក្នុងកម្ពុជាប្រជាធិបតេយ្យការខូចមួយជ្រុង គឺមិនមានកំណត់ទេ។ អ្វីៗដែលនៅក្រៅបដិវត្តន៍បានក្លាយជាគោលដៅដែលត្រូវពួកគេកម្ទេចស្របច្បាប់ និងចាំបាច់។ វាមិនគ្រាន់តែជីវិតគ្មានតម្លៃប៉ុណ្ណោះទេ។ តែការសម្លាប់បានក្លាយទៅជា

សកម្មភាពដែលគ្មានហេតុផល។ ប្រទេសទាំងមូលត្រូវដាក់នៅក្នុងសភាពជាទេសភាពដែលក្នុងទ្រឹស្តីបានបដិសេធគ្រប់អ្វីៗដែលមានភាពជាមនុស្ស"។ ឥឡូវនេះ ខ្ញុំមានសំណួរមួយចំនួនទៅកាន់លោកស្សូត។ ខ្ញុំសូមឲ្យលោកជួយពន្យល់បន្ថែមនូវអត្ថន័យនៃពាក្យដែលលោកប្រើថា "បដិវត្តន៍ដាច់ខាតបំផុតនៅក្នុងលោក" តើមានអត្ថន័យយ៉ាងដូចម្ដេចដែរ?

[០៩:១០:៤១]

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** មិនមានបក្សកុម្មុយនីស្តនៅទីណាក៏ដោយ ទោះបីកូរ៉េខាងជើង ចិន ឬក៏ប្លុកសូវៀតក៏ដោយ គឺថាមានបំណងចង់ធ្វើដំណើរឲ្យបានឆាប់រហ័យ និងទាំងបានទាំងស្រុងទៅដល់ទៅឈានកាន់រដ្ឋកុម្មុយនីស្ត ដូចដែលកំណត់ដោយលោក កាល់ម៉ាក្ស ដែលថារដ្ឋនោះត្រូវតែមានសមភាពស្មើគ្នាទាំងស្រុង។ ហើយជាពិសេសនៅពេលដែលក្បាលម៉ាស៊ីនរដ្ឋដែលត្រូវធ្វើដំណើរអ្វីចរិតលក្ខណៈមួយនៃកម្ពុជាប្រជាធិបតេយ្យ គឺថាក្បាលម៉ាស៊ីនដឹកនាំរបស់រដ្ឋ ហើយជាការពិត គឺប្រតិបត្តិការរបស់បក្ស គឺថាត្រូវតែកម្រិតនៅក្នុងកម្រិតមួយជាអប្បបរមា ហើយដោយមិនមានការយោគយល់ជាមួយនឹងតថភាពពិតណាមួយនោះឡើយ ទាក់ទងទៅនឹងការបង្កើតឲ្យមានភាពសមភាពទាំងស្រុង ទាក់ទងទៅនឹងទ្រព្យសម្បត្តិ។ ហើយក្នុងន័យនេះឯង ប៉ុល ពត ដែលជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា គឺថាស្វែងរកហេតុផលដ៏ជ្រុលនិយមមួយ ហើយជាលទ្ធផលដូចដែលលោកដឹងហើយ គឺថាមានមហន្តរាយយ៉ាងខ្លាំងនេះឯង។

[០៩:១២:៣១]

**ស៖** សំណួរបន្ទាប់។ នៅក្នុងទស្សនៈរបស់លោក និងយោងតាមការស្រាវជ្រាវរបស់លោកអំពីប្រវត្តិចលនាបដិវត្តន៍ និងគោលនយោបាយរបស់បក្សកុម្មុយនីស្ត។ ខ្ញុំមានសំណួរដូចខាងក្រោមនេះ តើសេចក្ដីសម្រេចនៅខែឧសភា ឆ្នាំ១៩៧៥ តំណាងឲ្យការចាកចេញពីការអនុវត្តពីអតីតកាល ឬមួយក៏សេចក្ដីសម្រេចខែឧសភា ឆ្នាំ១៩៧៥ នោះ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា នៅតែមានការទាក់ទង និងៗធ្លាប់អនុវត្តនៅដើមទសវត្សរ៍ទៅ៦០។ តើអ៊ីចឹងមែនទេ?

**ឆ៖** ប្រសិនបើលោកមើលទៅលើការវិវត្តន៍នៃចិននៅក្រោយឆ្នាំ១៩៤៩ ដែល ម៉ៅ ហៅថាលទ្ធិប្រជាធិបតេយ្យថ្មី ដែលបក្សកុម្មុយនីស្តសហការជាមួយហ្នឹងផ្នែកមិនមែនជាកុម្មុយនីស្ត ដូចជាសហគ្រាសឯកជន ហើយបួនប្រាំឆ្នាំក្រោយមក គឺថាវាមានទម្រង់ ជឿទម្រង់ទំនើបនៃកុម្មុយនីស្តគឺថាវាមិនជ្រុលនិយមពេក វាមិនអាក្រក់ពេល។ នៅក្នុងប្រទេសកម្ពុជាសេចក្ដីសម្រេចនៅក្នុងខែមិថុនា គឺមិនមែន

ចង់ធ្វើដូច្នោះទេ។ តើវាជាជម្រើសមួយធ្ងន់ធ្ងរ ឬក៏គ្រោះថ្នាក់ឬ ដែលបក្សកុម្មុយនីស្តកម្ពុជាអាចអនុវត្ត និយាយអំពីលទ្ធិប្រជាធិបតេយ្យថ្មីនេះ? តើវាជាជម្រើសមួយធ្ងន់ធ្ងរដែលរបបកម្ពុជាប្រជាធិបតេយ្យ អាចសហការជាមួយផ្នែកដែលមិនមែនជាកុម្មុយនីស្ត។

[០៩:១៥:៥០]

ខ្ញុំថាមិនមែនដូច្នេះទេ ដោយសារថានេះដោយសារតែការវិវត្តន៍ពីមុននៅតាមបណ្តាខេត្តនានា មានជាឧទាហរណ៍ដូចជាមានបញ្ហាអន្តរការនៃការធ្វើឲ្យរដ្ឋមួយដែលមិនមានទ្រព្យសម្បត្តិ គឺថាការលុប បំបាត់លុយកាក់ ដូចជាក្រដាសប្រាក់នៅរបប លន់ នល់ គឺថាមិនត្រូវបានចាយវាយតទៅទៀតទេ។ មាន ការយល់ព្រមអំពីសមូហភាពភាវូបនីយកម្ម ដែលនេះគឺការឆ្ពោះទៅកាន់ទិសដៅនេះតែម្តង។ សេចក្តី សម្រេចនៅក្នុងខែមិថុនា ដែលបានសម្រេចនោះ គឺត្រូវលុបចោល។ និយាយអំពី គឺបក្សកុម្មុយនីស្តដែល ឈានទៅដល់កុម្មុយនីស្តកំពូលតែម្តង ដែលត្រូវតែឆ្ពោះ គឺថាហៅ ភាពបរិសុទ្ធ។ វាអាចវាមានអន្តរ-កាលមួយ ទោះបីជាវាមានលក្ខណៈដូចគ្នា ឬមិនដូចគ្នាក្តី។

**ស៖** ខ្ញុំសូមបញ្ជាក់ម្តងទៀត នេះគឺជាគំនិតដែលខ្ញុំយល់តាមលោកនិយាយទេ។ ខ្ញុំគិតថា សំណួរ របស់ខ្ញុំអំមិញនេះ លោកអាចឆ្លើយថា "សេចក្តីសម្រេចនៅក្នុងខែឧសភា ឆ្នាំ៧៥ គឺដើរតាមទម្រង់ដែល បានសម្រេចកន្លងមក តាំងពីទសវត្សរ៍៧០ម្ល៉េះ"។ តើខ្ញុំយល់អ៊ីចឹង ត្រូវដែរទេ?

**ឆ៖** បាទ ខ្ញុំកំពុងរង់ចាំឆ្លើយ។ ខ្ញុំមិនអាចឆ្លើយរហូតដល់មីក្រូហ្វូននេះគឺថាត្រូវបានបើក។ លោកតំណាងសហព្រះរាជអាជ្ញាត្រឹមត្រូវហើយ មានទំនាក់ទំនងអ្វីដែលបានកើតឡើងក្រោយ១៧ មេសា ៧៥ រួមទាំងសេចក្តីសម្រេចនៅឯព្រះកែវមរកត ប៉ុន្តែវាមិនមែនជាការភ្ជាប់ដែលទៅតាមមធ្យោបាយ មួយដូចដែលបានធ្វើនោះទេ។ វាអាចកើតឡើងជាយថាហេតុទៅតាមទិសដៅមួយ ដែលខ្មែរក្រហម បានចង្អុលបង្ហាញនោះ ប៉ុន្តែមិនបានកើតឡើងដោយបានឆាប់រហ័សនោះទេ។ នេះគឺជាសេចក្តីសម្រេច ពួកគេបានធ្វើសេចក្តីសម្រេចនេះឡើង។

[០៩:១៨:០៨]

**ស៖** អរគុណ ស្សេត។ ខ្ញុំមានសំណួរតទៅទៀត នៅលើសេចក្តីថ្លែងការណ៍របស់លោក ដែល ថា អ្វីៗទាំងអស់ដែលនៅក្រោមបដិវត្តន៍ បានក្លាយទៅជាគោលដៅស្របច្បាប់ និងចាំបាច់ក្នុងការកម្ទេច។ តើខ្ញុំសួរ ថាតើសេចក្តីសម្រេចនេះ មានទាក់ទិនអ្វីខ្លះទៅលើទំនាក់ទំនងបក្សកុម្មុយនីស្តកម្ពុជា និង វណ្ណៈសិប្បដែលសម្ព័ន្ធមិត្តពីមុនៗមកនោះ?

**ឆ៖** សេចក្តីសម្រេចនៅក្នុងខែឧសភា មានន័យថា រណសិរ្សលែងមានសារៈប្រយោជន៍ជាចាំបាច់អ្វីតទៅទៀតហើយ។ ដូច្នេះហើយសេចក្តីសម្រេចគឺថា ថាតើបក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងចាត់ចែងជាមួយរណសិរ្សដោយរបៀបណា? តើបក្សកុម្មុយនីស្តកម្ពុជាតើនាំកុម្មុយនីស្តនោះទៅដល់ចុងបញ្ចប់ដោយរបៀបណា? ដូចដែលចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧៦ អំពីប្រព័ន្ធកម្ពុជាប្រជាធិបតេយ្យដ៏បរិសុទ្ធនេះ។ តំណាងរបស់សម្តេច សីហនុ គឺនៅក្រៅបដិវត្តន៍ សម្តេច សីហនុ ក៏ដូចជាសមាជិករណសិរ្ស គឺអ្នកដែលមិនមែនមកពីស្នូលនៃបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ សេចក្តីសម្រេច គឺថាលោតផ្លោះទៅដល់រដ្ឋកុម្មុយនីស្តឲ្យបានឆាប់រហ័ស ទៅដល់ចុងបញ្ចប់តែម្តង។

[០៩:២០:០៩]

**ស៖** ខ្ញុំសួរបន្តិចទៀត ទាក់ទងជាមួយនឹងសេចក្តីសម្រេចនេះ គឺសម្រេចក្នុងការកម្ទេច តើការសម្រេចកម្ទេចនេះមានទំនាក់ទំនងជាមួយនឹងសម្ព័ន្ធមិត្តពីមុនៗមកទេ? ខ្ញុំចង់បញ្ជាក់អ៊ីចឹង។

**ឆ៖** បាទ ជាការពិតហើយ សម្ព័ន្ធ -- អតីតសម្ព័ន្ធមិត្តគឺអ្នកសមាសធាតុដែលមិនមែនជាកុម្មុយនីស្ត ដូចជារណសិរ្ស។ សេចក្តីសម្រេចក្នុងខែឧសភា ផលវិបាកនៃសេចក្តីសម្រេចនេះ គឺថាទំនាក់ទំនងនោះ គឺមិនគួរបន្តទៀត ដូចដែលមានពីមុនទេ ត្រូវតែផ្លាស់ប្តូរ ដោយសារអំណាចទាំងអស់ស្ថិតក្នុងដៃរបស់សមាជិកស្នូលនៃបក្សកុម្មុយនីស្តកម្ពុជា។ បញ្ហានេះ គឺថាត្រូវតែដោះស្រាយជាមួយរណសិរ្សដោយសារតែរណសិរ្សជាសមាសធាតុមិនមែនជាកុម្មុយនីស្ត។ នេះគឺជាសេចក្តីសម្រេច ដើម្បីបង្កើតនៅរដ្ឋធម្មនុញ្ញ -- ដើម្បីប្រកាសឲ្យប្រើនៅរដ្ឋធម្មនុញ្ញថ្មី ហើយលទ្ធផលនៃរដ្ឋធម្មនុញ្ញនេះ គឺថា នាំឲ្យសម្តេច សីហនុ ព្រះអង្គលាលែង ហើយបញ្ចប់សមាសធាតុរណសិរ្ស។ នេះគឺអ្វីដែលកើតមានឡើងក្រោយសេចក្តីសម្រេចក្នុងខែឧសភា។

[០៩:២១:៥១]

**ស៖** អរគុណ ស្បត។ ខ្ញុំបន្តសំណួរទៀត ខ្ញុំចង់ស្វែងយល់ថា តើគោលនយោបាយនេះ គោល-នយោបាយស្តីពីការសម្រេចកម្ទេចនេះ វាប៉ះពាល់ទៅដល់ប្រជាជនធម្មតាដែលនៅក្រៅជួរដែរឬទេ? ទី១។ ទី២ ថាតើសេចក្តីសម្រេចហ្នឹង វាមានផលប៉ះពាល់ទៅដល់អ្នកដែលនៅក្នុងជួរដែរទេ?

**ឆ៖** គោលនយោបាយកម្ទេច គឺកម្ទេចអ្នកទាំងឡាយណាមិនចូលរួមជាមួយបដិវត្តន៍ឲ្យស្មោះអស់ពីដួងហឫទ័យ គឺថារបៀបចូលរៀន វារាងផែលៗ ដូចដែលអ្វីដែលយើងទើបបានពិភាក្សា គឺមានន័យថា អ្នកនៅខាងក្រៅបដិវត្តន៍ ដូចជាអ្នកនៅក្នុងរណសិរ្ស គឺលែងមានភាពចាំបាច់សម្រាប់ដំណាក់កាល

ក្រោយមកទៀតហើយ។ ហេតុអ្វីបានជាគេកម្ទេចប្រជាជនដូច្នេះ? ហេតុអ្វីបានជាគេសង្ស័យទៅលើប្រជាជនយ៉ាងដូច្នេះ? ខ្ញុំគិតឃើញថា លើកឡើងពីចំណុចមួយដែលថា វាជាចំណុចជាមូលដ្ឋាននៃមនោគមន៍វិជ្ជារបស់ខ្មែរក្រហមហើយ។

[០៩:២៣:២១]

និយាយអំពីភាពជាឯកជន ការសួរសំណួរទាំងឡាយណាពាក់ព័ន្ធទៅដល់របបហ្នឹង គឺថាវាជាទម្រង់មួយនៃពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិឯកជន ដោយគិតថា វាជាគំនិតយោបល់ឯកជក ខុសពីគំនិតរបស់អង្គការ គំនិតរបស់បដិវត្តន៍។ ហើយទ្រព្យសម្បត្តិឯកជន ទោះបីជាខាងផ្នែកបញ្ញាស្មារតីក្តី សម្ភារៈក្តី គឺថាវាជាការជំទាស់មួយដ៏ខ្លាំងក្លា ដែលកើតចេញពីអ្នកដែលនៅខាងក្រៅបដិវត្តន៍ គឺជាជាងអ្នកដែលនៅក្នុងបដិវត្តន៍។ ដូច្នេះបញ្ហាទាំងឡាយណាដែលបង្ហាញឲ្យឃើញពីទស្សនៈទាក់ទងទៅនឹងទ្រព្យសម្បត្តិឯកជន ទស្សនៈឯកជន គេចាត់ទុកថា ជាការជំទាស់ទៅនឹងបដិវត្តន៍ហើយ ទោះបីវាកើតមានឡើងនៅថ្នាក់ខ្ពស់ក្តី នៅក្នុងស្រទាប់ប្រជាជនសាមញ្ញក្តី។ ដោយសារតែបដិវត្តន៍នេះ បដិសេធមិនទទួលយកការមន្ទិលសង្ស័យណាមួយ ឬភាពមិនប្រាកដប្រជាណានោះ។ ដូច្នេះអ្នកដែលមានទស្សនៈផ្សេង ទស្សនៈឯកជនដែលវាប្រឆាំងទៅនឹងទស្សនៈសមូហភាព គឺថាអាចនឹងឈានទៅដល់ការកម្ទេច។

[០៩:២៤:៥៤]

**ស៖** អរគុណ ស្មួត។ ខ្ញុំតសំណួរទៀត។ ឥឡូវនេះ ខ្ញុំត្រឡប់ទៅសៀវភៅរបស់លោកវិញម្តង។ នៅផ្នែកដដែល ដែលយើងបានពិនិត្យមុននេះបន្តិច លោកបាននិយាយអំពីការបំបាត់សិទ្ធិបុគ្គលនៅក្នុងរបបនោះ។ នៅក្នុងទំព័រទី១១, ភាសាអង់គ្លេស ERN 00396203, បារាំង 00639462។ លោកសរសេរថា “លុយ តុលាការ កាសែត ប្រៃសនីយ៍ និងប្រព័ន្ធទំនាក់ទំនងទូរស័ព្ទក្រៅប្រទេស និងសូម្បីតែទស្សនទានអំពីទីក្រុងក៏ត្រូវបានលុបបំបាត់ចោលទាំងស្រុង។ សិទ្ធិបុគ្គលមិនត្រឹមតែបានកាត់បន្ថយក្នុងគោលបំណងជាសមូហភាពទេ តែត្រូវបានធ្វើឲ្យរលាយសាបសូន្យជាមួយគ្នាតែម្តង។ ការផ្តើមគំនិត គំនិតច្នៃប្រឌិត គំនិតប្លែក ត្រូវបានដាក់ទោសដោយបុគ្គលខ្លួនឯងតែម្តង។ ស្មារតី ឧត្តមគតិបុគ្គលត្រូវបានគេលុបបំបាត់ជាលក្ខណៈប្រព័ន្ធ”។ ខ្ញុំមានសំណួរ នៅក្នុងទស្សនៈរបស់លោក ខ្ញុំចង់ដឹងថាអ្វីជាហេតុផលនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការលុបបំបាត់ឲ្យរលាយសាបសូន្យនូវសិទ្ធិបុគ្គលបែបនេះ?

[០៩:២៧:២១]

**ឆ៖** ដោយសារថា បើសិនណាជាយើងមានសិទ្ធិឯកជន ដូចជាគំនិតយោបល់ជាឯកជន ទ្រព្យសម្បត្តិឯកជន មានន័យថាមនុស្សមិនមានភាពស្មើគ្នាទេ។ ខ្ញុំមិនមានយោបល់អ្វីសម្រាប់លោក ខៀវ សំផន នោះទេ ក៏ប៉ុន្តែខ្ញុំបាននិយាយទៅកាន់មន្ត្រី ខ្ញុំមិនមាននិយាយជាមួយ ខៀវ សំផន ប៉ុន្តែ និយាយជាមួយមន្ត្រីនៅក្នុងរដ្ឋាភិបាលដែលចូលរួមសិក្ខាសាលាដែលបើកវគ្គដោយលោក ខៀវ សំផន ដែលគាត់និយាយថា "បើសិនបុគ្គលម្នាក់មានអ្វីច្រើនជាងបុគ្គលម្នាក់ទៀត នេះមានន័យថាមិនមែនកុម្មុយនីស្តទេ។ មធ្យោបាយតែមួយគត់ធានាទៅដល់កុម្មុយនីស្តនោះ គឺថាម្នាក់ៗត្រូវតែមានអ្វីៗដូចគ្នាស្មើគ្នា ហើយមិនត្រូវអ្នកណាម្នាក់មិនមានអ្វីនោះទេ"។ នេះនិយាយពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិឯកជន។ ចំណុចនេះក៏អនុវត្តទៅដល់ខាងផ្នែកគំនិតនិយម និងសម្ភារនិយមនោះផងដែរ។

[០៩:២៨:៥៣]

**ស៖** អរគុណ ស្មួត។ ខ្ញុំតសំណួរ។ ខ្មែរក្រហម -- ខ្ញុំសួរថា តើខ្មែរក្រហមមានវិធីអ្វីខ្លះសម្រាប់ជីវិតគ្រួសារ និងជាពិសេសសិទ្ធិគ្រួសារក្នុងការរស់នៅជាមួយគ្នា និងសម្រាប់កូនក្មេងតូចៗរស់នៅក្នុងជាមួយនឹងឪពុកម្តាយរបស់គាត់?

**ឆ៖** ជំហរជាមូលដ្ឋាននេះ គឺថាក្រុមគ្រួសារពិតប្រាកដនេះគឺជាអង្គការហើយ។ ហើយមិនមែនជាគេហៅថា គ្រួសារដែលមានសមាជិកច្រើនពីជីដូនជីតារហូតមកដល់កូនចៅនោះទេ។ ហើយដូច្នេះឯងទំនាក់ទំនងសមាជិកគ្រួសារ។ ខ្ញុំមិនចង់និយាយអំពីបញ្ហាកូពីនិយមនោះទេ។ នៅក្នុងប្រទេសកម្ពុជាគឺថាគេអនុវត្តតាមគោលនយោបាយណា? តើមន្ត្រីមូលដ្ឋានអនុវតាមគោលនយោបាយបែបណា? ប៉ុន្តែខ្មែរសង្វាក់សំខាន់ហ្នឹង គឺថាសមាជិកគ្រួសារមិនអនុញ្ញាតឲ្យជ្រៀតជ្រែកចូលទៅដល់ភាពស្មោះត្រង់របស់បុគ្គលម្នាក់ៗចំពោះបក្សកុម្មុយនីស្ត ចំពោះអង្គការនោះទេ។ ដូច្នេះជាលទ្ធផលគឺថាវាមានទម្ងន់ទំនាក់ទំនងក្នុងគ្រួសារមានទម្ងន់តិចបំផុត និងរួមទាំងរបបអាពាហ៍ពិពាហ៍គ្រួសារនៅក្នុងអំឡុងខ្មែរក្រហមហើយជាពិសេសគឺរវាងទាហាន និងស្ត្រីក្មេងៗ រវាងកងទ័ពហើយនិងនារីក្មេងៗ។ ការគោលបំណងនៃអនុវត្តជាក់ស្តែងគឺបង្កើតក្មេងៗ ដែលជាផ្នែកមួយនៃប្រជាពលរដ្ឋ ដែលខុសពីសមាជិកគ្រួសារមួយចំនួនដែលគេ ខ្មែរក្រហមយល់ មានទស្សនៈយល់ផ្សេងពីនេះ។

[០៩:៣១:០៧]

**ស៖** បាទ នៅក្នុងប្រធានបទនេះដដែល ខ្ញុំមានបំណងពិនិត្យមើលទៅលើការសរសេររបស់លោក ដូចជាការលុបបំបាត់រចនាសម្ព័ន្ធតុលាការ និងប្រព័ន្ធច្បាប់នៅក្នុងរបបនេះ ពីឆ្នាំ១៩៧៥ ដល់ ៧៩។

កាលពីម្សិលមិញ ចៅក្រម ខាតវ៉ាយថ៍ ស្គួរ, លោក ស្បូត បានប្រាប់ថា "ប្រព័ន្ធតុលាការគ្មានតែម្តង" នៅម៉ោងមួយសែសិបបីនាទី។ ឥឡូវនេះ ខ្ញុំមានសំណួរបន្ថែម សូមឲ្យលោកជួយពន្យល់ថាហេតុអ្វីបានជាគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាអនុញ្ញាតឲ្យមានការលុបបំបាត់ប្រព័ន្ធតុលាការបែបនេះ?

**ឆ៖** បាទ ខ្ញុំពិតជាបានពិនិត្យឃើញ។ ខ្ញុំសូមជម្រាបថា ខ្ញុំពិនិត្យឃើញថាការលុបបំបាត់នូវតុលាការនេះគឺជាតថភាពមួយទាក់ទងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយហេតុថាគោលបំណងតែមួយគត់នៃតុលាការ គឺធ្វើការវិនិច្ឆ័យក្តីដោយឯករាជ្យ។ គំនិតនៃអ្វីៗដែលថាត្រូវតែឯករាជ្យចេញពីបក្សនោះ គឺថាជាផ្នែកមួយ គេចាត់ទុកថាជាការជំទាស់ទៅនឹងបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះគេមិនចាំបាច់ឲ្យមានតុលាការទេ គឺបក្សខ្លួនឯងជាអ្នកសម្រេច។ អ្វីផ្សេងៗទៀតគឺចាត់ទុកថាជាការជំទាស់ គឺថាអ៊ីចឹងហើយ គេចាត់ទុកថាតុលាការ គឺជាស្ថាប័នគ្មានសារសំខាន់សម្រាប់បក្សកុម្មុយនីស្តកម្ពុជាទេ។ ដូច្នេះ គេគ្មានតុលាការទេ។

[០៩:៣៣:១៩]

**ស៖** អរគុណ ស្បូត។ ខ្ញុំក៏មានសំណួរបន្ថែមដែរ។ ខ្ញុំចង់ដឹងថាតើមានប្រព័ន្ធណាមួយនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនេះ មកជំនួសប្រព័ន្ធតុលាការនៅពេលនោះបានយ៉ាងដូចម្តេចដែរ?

**ឆ៖** ខ្ញុំគិតថាបើយើងនិយាយតាមពាក្យដែលយើងប្រើនោះ គឺថាយើងពិបាកនឹងប្រើពាក្យថា "យុត្តិធម៌" ណាស់នាសម័យនោះ។ យើងឃើញមានប្រព័ន្ធមួយដែលគេប្រើថា អ្នកណាដែលត្រូវគេសង្ស័យថាមិនមានភាពស្មោះត្រង់ គេនឹងត្រូវប្រកាស់ឆ្លើយដាក់ ឬក៏ចោទប្រកាន់ទោសទៅឲ្យមេភូមិ ឬក៏សហករណ៍គេដឹង ហើយក៏បញ្ជូនដំណឹងហ្នឹងទៅថ្នាក់ស្រុក។ នៅក្នុងករណីខ្លះ ពេលគេរកឃើញថាគ្មានកំហុស គឺគេអាចនឹងដោះលែងមកវិញ។ ប៉ុន្តែក្នុងករណីដែលគេយល់ថាមិនអាចកែកំហុសវិញនោះ បាទក្នុងករណីភាពច្រើននឹងត្រូវបានគេសម្លាប់ហើយ ជនដែលត្រូវសង្ស័យនោះ។ ប៉ុន្តែក្នុងករណីខ្លះ គេអាចនឹងធ្វើសេចក្តីសម្រេចនៅថ្នាក់សហករណ៍ជាសមូហភាព អាចនឹងត្រូវគេសម្រេច។ ប៉ុន្តែក្នុងករណីធ្ងន់ធ្ងរ ឬក៏គេចាត់ទុកថាធ្ងន់ធ្ងរ ហ្នឹងគេបញ្ជូនទៅមន្ទីរសន្តិបាល ឬក៏ ស-២១ ដែលគេនឹងត្រូវសួរចម្លើយបន្ទាប់មកគេនឹងប្រហារជីវិត។ ហើយខ្ញុំពិបាកនឹងជម្រាបលោកថា យើងហៅប្រព័ន្ធនេះ ជាប្រព័ន្ធយុត្តិធម៌ណាស់។ គឺជាប្រព័ន្ធឆ្ពោះទៅរកការលុបបំបាត់ ឬក៏កម្ទេចមនុស្សចោល។ នេះទើបសមជាងគឺមិនមានអ្វីអាចហៅបានល្អជាងនេះទេ គឺបែបនេះឯង។

[០៩:៣៥:៣៦]

**ស៖** អរគុណ ស្សូត។ ខ្ញុំមានសំណួរមួយទាក់ទងនឹងទស្សនៈដែលលោកជាអ្នកប្រវត្តិសាស្ត្រ និងទស្សនវិទូផ្នែកការស្រាវជ្រាវនេះ។ សូមលោកជួយផ្តល់ហេតុផលដូចខាងក្រោម។ ខ្ញុំនឹងសួរ ប្រសិនបើនៅក្នុងប្រទេសទាំងមូល អ្នកដឹកនាំប្រទេសទាំងមូល មិនបានលើកកំពស់លើប្រព័ន្ធតុលាការ ឬក៏មិនបាន -- ឬក៏បណ្តោយឲ្យមានការលុបបំបាត់ប្រព័ន្ធតុលាការបែបនេះ។ តើវាអាចមានផលវិបាកទៅអនាគតយ៉ាងដូចម្តេចដែរ?

**ផ៖** ផលវិបាកនោះ គឺថាអ្វីដែលយើងឃើញនោះឯង ប៉ុន្តែខ្ញុំសូមជម្រាបថា អាស្រ័យទៅលើមនោគមន៍វិជ្ជានៃបក្សកុម្មុយនីស្តកម្ពុជា គឺជាចំណុចដែលថា ជាលទ្ធផលដែលគេរំពឹងទុក ហើយនិងវាផុសចេញពីអ្វីពីគោលដៅនៃមនោគមន៍វិជ្ជានោះឯង។ ដោយសារថាគេមានប្រព័ន្ធមួយដែលជាប្រព័ន្ធផ្ទុយពីសិទ្ធិសេរីភាពរបស់បុគ្គល។ ជាពិសេសនៅថ្នាក់មូលដ្ឋាន ហើយនិងនៅថ្នាក់ខេត្ត។ រាល់ការធ្វើសេចក្តីសម្រេច ត្រូវបានធ្វើឡើងដោយក្រុមតូចនៃមនុស្សមួយក្រុម គឺថាអាចនៅគណៈអចិន្ត្រៃយ៍ ឬក៏ដោយ ប៉ុល ពត, នួន ជា ឬក៏សមាជិកផ្សេងៗទៀត ផ្អែកទៅលើប្រធានបទដែលគេត្រូវសម្រេចនោះឯង។

[០៩:៣៧:៣២]

**ស៖** អរគុណ ស្សូត។ ខ្ញុំនឹងបន្តសំណួរទាក់ទងទៅនឹងការលុបបំបាត់លុយ។ កាលពីម្សិលមិញចៅក្រម ខាតវ៉ាយថ៍ បានសួរ ស្សូត ប្រាប់ថា "ទាក់ទងនឹងការលុបបំបាត់លុយនេះ គឺប្រជាជនមិនអាចធ្វើអ្វីកើត"។ លោកប្រាប់អ៊ីចឹង។ អ្វីដែលខ្ញុំសួរនៅទីនេះ ខ្ញុំក៏មិនច្បាស់ត្រង់ហ្នឹងដែរ ខ្ញុំចង់ដឹងថា តើមានគោលនយោបាយអ្វី ឬក៏ការពិចារណាបែបទ្រឹស្តីអ្វី នៅពីក្រោយការសម្រេចចិត្តដោយមេដឹកនាំខ្មែរក្រហម ដើម្បីបំបាត់លុយ បន្ទាប់ពីជ័យជម្នះនេះ?

**ផ៖** ទាក់ទងនឹងបញ្ហានេះ គឺថាមានបញ្ហាពីរដែលខុសគ្នា។ សម្ភូហភាពរូបនីយកម្ម កើតមានឡើងនៅគ្រប់កុម្មុយនីស្តរបស់ប្រទេសផ្សេងៗដែរ ហើយវាមិនស្ថិតនៅក្រៅពីបរិបទកម្ពុជាប្រជាធិបតេយ្យទេ។ នេះមិនមែនមានន័យថា កម្ពុជាប្រជាធិបតេយ្យត្រូវរក្សាទុកលុយនោះទេ។ នៅប្រទេសចិនមានការពិភាក្សាតិចតួចណាស់ អំពីការលុបបំបាត់ចរាចរលុយកាក់នេះ គឺថានៅទសវត្សឆ្នាំ១៩៥០ ហើយគេ -- ក្នុងរបបកុម្មុយនីស្តចិន ហើយនិងរបបកុម្មុយនីស្តផ្សេងៗទៀតនោះ គេអាចនឹងប្រើលុយកាក់ខ្លះ។

[០៩:៣៩:១៨]

ហេតុអ្វីបានជានៅកម្ពុជាប្រជាធិបតេយ្យ គេសម្រេចថាលុបចោលលុយកាក់ទាំងស្រុងទាំងនេះ? ដោយហេតុថា ដូចដែលខ្ញុំជម្រាបពីខាងដើម កម្មសិទ្ធឯកជនប្រភេទណាក៏ដោយ គឺជាប្រភពនៃអសមភាព ហើយគោលការណ៍ណែនាំគ្រឹះនោះ គឺថាគេដឹកនាំថា គេពន្យល់ថា ទ្រព្យសម្បត្តិវាធ្វើឲ្យមាន -- មិនមានសមភាព ហើយបើសិនជាប្រើលុយកាក់នោះ គឺថាបើសិនថាអាចនឹងធ្វើឲ្យម្នាក់មានលុយច្រើនជាងម្នាក់។ អ្នកដែលមានលុយច្រើន គឺថាអាចទិញរបស់ច្រើនជាង ល្អជាង។ អាហ្នឹងហើយ វាបង្កើតនូវភាពមិនស្មើគ្នា។ ដូច្នេះហើយ ជាច្រកមួយដែលគេធ្វើសេចក្ដីសម្រេច គឺថាគ្មានលុយកាក់ គ្មានទ្រព្យសម្បត្តិឯកជន គេចាត់ទុកថា អាហ្នឹងហើយយើងមានសមភាពទាំងស្រុង។ អានេះ គឺតថភាពមួយ ជាភាពសមហេតុផលមួយដែលថាកាល -- ហើយគេចាត់ទុកថាជីវិតបែបនោះ គឺជាជីវិតធម្មតារបស់ជនកុម្មុយនីស្ដនោះឯង។

**ស៖** ខ្ញុំមានសំណួរមួយទៀតទាក់ទងនឹងសេចក្ដីសម្រេចស្ដីពីការបង្កើតសហករណ៍ និងការអនុវត្តសមូហភាវូបនីយកម្ម។ សំណួរនេះ ចៅក្រម ឡាវែន៍ ក៏បានសួរ ហើយកាលពីម្សិលមិញ ស្សូត ក៏បានពន្យល់ថា ប្រព័ន្ធបែបសហករណ៍នេះគឺ ស្សូត និយាយថា “ធ្វើឲ្យមនុស្សដូចគ្នា”។ ប្រសិនបើយើងប្រៀបធៀបទៅ ឧបមាថា ១ម៉ែត្រ៦០ហ្នឹង គឺថាតម្រឹមឲ្យដូចៗគ្នា។ ខ្ញុំមានចម្ងល់មិនច្បាស់ដែរ ខ្ញុំថាតើនៅពីក្រោយការបង្កើតប្រព័ន្ធសហករណ៍នេះ ហើយនិងគោលនយោបាយហ្នឹង តើមានអ្វីនៅពីក្រោយហ្នឹង?

[០៩:៤១:៤៧]

**ឆ៖** ដំបូងឡើយ គេមានមូលហេតុមួយចំនួនរបស់គេ នៅក្នុងប្រព័ន្ធលទ្ធិកុម្មុយនីស្ដនោះ គឺថាគេចាត់ទុកទ្រព្យសម្បត្តិនោះ គឺថាត្រូវតែគ្រប់គ្រងឲ្យមានសមភាព ឬក៏ភាពសមស្រប ដើម្បីកុំឲ្យមានការកេងប្រវ័ញ្ចពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ហ្នឹងនៅក្នុងលទ្ធិកុម្មុយនីស្ត។ ប៉ុន្តែមូលដ្ឋានជាសនិទានភាពត្រឹមត្រូវហ្នឹង គឺថាគេត្រូវតែគ្រប់គ្រងការផ្គត់ផ្គង់ស្បៀងអាហារជាស្រូវអង្ករ ជាពិសេសគឺដូចជាយើងឃើញថា ដូចជាសម្ព័ន្ធមិត្តវៀតណាមរបស់ពួកគេអ៊ីចឹងដែរ។ បន្ទាប់មកគេនិយាយថា ធាតុផ្សំខាងមនោគមន៍វិជ្ជាដែលគេបានពិភាក្សានោះ គឺគេមានឆន្ទៈ ឬក៏មហិច្ឆតា ដើម្បីបង្កើតនៅប្រព័ន្ធមួយដែលថាជនគ្រប់រូបត្រូវតែមានសមភាព។ ហើយយើងឃើញថា គេអាចមានមូលហេតុសមស្របទៅតាមគំនិតផ្ដួចផ្ដើមដែលនឹងធ្វើឲ្យកសិករក្រីក្រមានជីវភាពកើនឡើង។ ដូចម្សិលមិញ យើងបានឮថា ប៉ុល ពត បានព្យាយាមធ្វើឲ្យពលរដ្ឋកម្ពុជាភាគច្រើនឲ្យមានជីវភាពកើនឡើង ប៉ុន្តែតាមការពិតគាត់ធ្វើមិនដល់នោះទេ។

[០៩:៤៣:១៥]

នៅក្នុងប្រព័ន្ធកុម្មុយនីស្តដែលយើងអាចឃើញ គឺថាផលិតកម្មកសិកម្ម គេចាត់ទុកថាជាមធ្យោបាយដែលកម្ពុជាប្រជាធិបតេយ្យហ្នឹង គេចាត់ទុកថាឲ្យមានការរីកចម្រើន ហើយរឹងមាំ។ ដូច្នេះហើយមនុស្សភាគច្រើនគេ -- គេចង់ឲ្យមនុស្សភាគច្រើនដាក់ចូលទៅក្នុងសហករណ៍ឲ្យធ្វើការនៅក្នុងវិស័យកសិកម្ម ដើម្បីឲ្យវាមានចំណុចរឹងមាំខ្លាំងដើម្បីកម្ពុជាអាចអភិវឌ្ឍន៍បានលឿន រីកចម្រើនបានលឿន។ ម្តងទៀត ខ្ញុំចង់ជម្រាបពាក្យមួយថា គឺមានមួយ គឺថាចំណុចនេះមិនមែនថាគ្មានមូលដ្ឋានគាំទ្រ មូលដ្ឋានសមស្របទេ គឺថាវាមានន័យ វាមានអត្ថន័យ ប៉ុន្តែវាបង្កើតជាបញ្ហានៅក្នុងការអនុវត្ត គឺថាយើងអាចនឹងនឹកឃើញហើយថា ប្រព័ន្ធបែបនេះអាចនឹងត្រូវបានមានយុត្តិធម៌ សមធម៌ត្រឹមត្រូវ ហើយអាចនឹងសម្រេចគោលបំណងមួយចំនួន ដោយមិនឲ្យមានការឈឺចាប់ទៅលើអ្នកដែលអនុវត្តបើសិនជាគេអនុវត្តបានត្រឹមត្រូវនោះ។

[០៩:៤៤:៣៤]

**ស៖** ខ្ញុំមានសំណួរចុងក្រោយទៅ ស្សូត។ អម្បាញ់មិញយើងពិភាក្សាអំពីការបង្កើតគោលនយោបាយស្តីពីការលុបបំបាត់លុយ ហើយនិងការព្រាងគោលនយោបាយដើម្បីបង្កើតប្រព័ន្ធសហករណ៍ និងអនុវត្តសម្ងហភាពបនីយកម្ម។ ឥឡូវនេះ គម្រោងទាំងអស់នេះ ផែនការទាំងអស់នេះ គេចាប់ផ្តើមធ្វើ។ តើមានរយៈពេលយូរប៉ុនណា ដើម្បីអនុវត្តអាផែនការទាំងអស់ហ្នឹងបន្ទាប់ពីថ្ងៃរំដោះ១៧ មេសា ឆ្នាំ១៩៧៥?

**ឆ៖** គេអាននិយាយថា គឺមិនត្រឹមតែនិយាយការលុបបំបាត់លុយកាក់ទេ។ សម្ងហភាវូបនីយកម្ម ក៏ដូចគ្នាដែរ គឺការផ្លាស់ប្តូរទីលំនៅប្រជាជនជាទូទៅ ទៅចូលសហករណ៍នោះ គឺជាដំណាក់កាលមួយដែលគេចាត់ទុកថាខ្មែរក្រហមបានទទួលជោគជ័យរបស់គេនោះ គេដាក់ឲ្យមនុស្សទាំងអស់នោះធ្វើការនៅក្នុងសហករណ៍ជាសម្ងហភាព។ អ៊ីចឹងគឺថាសេចក្តីសម្រេចនោះ គឺថាអាចនឹងមានការយឺតយ៉ាវ។ យើងពិបាកនឹងចុចយកថាចំណុចណាហ្នឹងថាវាដើរលឿនបែបណានោះ គឺថានៅក្នុងខែឧសភា គេសម្រេច ធ្វើសេចក្តីសម្រេចមួយនៅវិហារព្រះកែវមរកត គឺថាគេចង់បង្កើតឲ្យមានជាប្រព័ន្ធធនាគារមួយដែលអនុញ្ញាតឲ្យប្រើប្រាស់លុយកាក់។

[០៩:៤៦:២៦]

ហើយយើងបានបញ្ជាក់និយាយពីម៉្សិលមិញផងដែរ។ គឺថាក្រដាសប្រាក់គំរូត្រូវបានបោះពុម្ព

ហើយត្រូវយកប្រើ -- យកទៅទៅបង្ហាញតាមសហករណ៍ គេប្រាប់ថានេះឯងជាលុយគំរូដែលគេនឹងត្រូវប្រើ។ ប៉ុន្តែពាក្យបានផ្សព្វផ្សាយ បន្ទាប់មកគឺថាគេនិយាយថា គេគ្រាន់តែឲ្យគំរូទេ គឺមិនបានប្រើប្រាស់ទេ។ ប៉ុន្តែសេចក្តីសម្រេចហ្នឹងធ្វើឡើងនៅខែឧសភា បន្ទាប់ពីហ្នឹងទៅ គឺត្រូវបានបញ្ចប់ទៅវិញ។ ប៉ុន្តែប៉ុន្មានសប្តាហ៍ពីក្រោយនោះ គឺថាគឺគេដឹងគ្រប់គ្នាថា គេគ្រាន់តែបង្ហាញទេ គេមិនដែលយកមកឲ្យប្រើជាលុយកាក់ចរាចរអ្វីទេ។

**លោក វ៉េង ហ៊ិត៖**

អរគុណស្មូត។ ខ្ញុំបញ្ចប់សំណួរខ្ញុំត្រឹមប៉ុណ្ណេះ ហើយ ថារីក សហការីរបស់ខ្ញុំនឹងសួរលោកបន្តទៅទៀត។

អរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

[០៩:៤៧:៤៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ភាគីទាំងអស់ ហើយនិងលោកអ្នកជំនាញ។ ខ្ញុំ ហើយសូមអរគុណចំពោះលោកអ្នកជំនាញដែលបានអញ្ជើញមកកម្ពុជាដើម្បីផ្តល់សក្ខីកម្ម។ នេះជាលើកទី២ហើយ ដែលលោកអញ្ជើញមក។ លើកទី១នោះ យើងជាអកុសល យើងមិនបានស្តាប់លោកទេ។ ហើយខ្ញុំនឹងសួរអំពីប្រធានបទមួយចំនួនទៅលោកថ្ងៃនេះ ហើយនិងស្អែកព្រឹកតទៅទៀត។ ហើយខ្ញុំនឹងសួរទៅតាមលំដាប់លំដោយ តាមរយៈអំពីការវិវត្តនៃគោលនយោបាយដែលលោកបាននិយាយ ប៉ុន្តែខ្ញុំចាប់ផ្តើមដំបូងអំពីចុចយកចំណុចមួយ ឬក៏ពីរដែលលោកទើបតែបានពន្យល់ទៅតុលាការ។

[០៩:៤៨:៤១]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** បញ្ហានេះ យើងនៅថ្មីៗនៅឡើយទេ។ លោកនិយាយអំពីទស្សនៈនៃការបំផ្លាញនូវកម្មសិទ្ធិឯកជន ហើយនិងបញ្ហាមួយចំនួនទៀត លោកបានពិភាក្សាអំពីវគ្គសិក្សាដែលលោកខៀវ សំផន បានបើកវគ្គនោះដែលលោកបានឮពីគាត់តាមរយៈការសម្ភាសន៍នោះ ហើយការដកស្រង់ពីសៀវភៅនោះគឺថាទាក់ទងទៅនឹងបញ្ហានេះដែរ ដែលលោកនៅចាំនៅក្នុងគំនិតលោកនៅឡើយទេ។ នៅក្នុងទំព័រ៣១៦ របស់សៀវភៅលោក បាទគឺពាក់កណ្តាលនៃទំព័រ៣១៦។ អង់គ្លេស ERN 00396524, បារាំង ERN 0063870។ នេះជាសេចក្តីដកស្រង់ "តាមពិត អ្វីដែលពាក់ព័ន្ធនៅក្នុងប្តូរនូវចិត្តគំនិតនោះ គឺថាធ្វើឲ្យ

មានការច្បាស់លាស់ទៅលើអ្នកមកចូលរួមថ្មីនៅក្នុងវគ្គសិក្សាដែល ខៀវ សំផន បានធ្វើ”។ បន្ទាប់លោក ស្រង់ ដែលគាត់បាននិយាយ “អ្វីដែលយើងធ្វើបក្សកុម្មុយនីស្ត -- បដិវត្តន៍កុម្មុយនីស្តនោះ គឺថាចំណុចទី១ គឺត្រូវបំបាត់កម្មសិទ្ធឯកជន។ កម្មសិទ្ធឯកជនប៉ុន្តែវាអាចមាននៅក្នុងជាសម្ភារៈ និងស្មារតី។ ដើម្បីបំបាក់កម្មសិទ្ធឯកជន វិធានការត្រឹមត្រូវគឺត្រូវជម្លៀសប្រជាជនចេញពីទីក្រុង ប៉ុន្តែទ្រព្យសម្បត្តិខាងផ្លូវចិត្តវិញ ខាងស្មារតី គឺថាអ្វីៗដែលអ្នកគិតថាជារបស់អ្នកគ្រប់យ៉ាងនោះ”។

[០៩:៥០:៣៦]

បន្ទាប់មកគឺនៅខាងក្រោមនេះបន្តិច កថាខណ្ឌបន្ទាប់ហ្នឹង “ចំណេះដែលចេះនៅក្នុងខួរក្បាលគំនិតនោះ គឺថាជាកម្មសិទ្ធខាងបញ្ញា គឺដើម្បីក្លាយទៅជាឧបករណ៍របស់បក្ស យើងត្រូវសម្អាតចិត្តគំនិតឲ្យច្បាស់ ដើម្បីឲ្យចំណេះដែលបានមកពីអាណានិគម ហើយនិងពីមូលធននិយមត្រូវតែបំផ្លាញចោលឲ្យអស់ កម្ទេចចោលឲ្យអស់”។ តើនេះជាអ្វីដែលលោកបានស្តាប់ឮពីគាត់ ហើយនិងការសិក្សារបស់លោកបានរកឃើញបែបនេះដែរឬទេ?

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** បាទ ពិតគឺអ៊ីចឹង។

**ស៖** ខ្ញុំសូមអានចំណុចមួយទៀតនៅបន្ទាប់ពីសេចក្តីដកស្រង់ខាងដើមនេះ លោកបាននិយាយថា “លោក ខៀវ សំផន បានប្រាប់អ្នកទាំងនោះឲ្យប្រយ័ត្នថារក្សាប្រកាន់ឲ្យខ្ជាប់ចំពោះបញ្ហាដែលយើងបានពិភាក្សា គឺថាយើងត្រូវតែប្រកាន់ខ្ជាប់ អនុវត្តឲ្យបានខ្ជាប់”។ ហើយនៅក្នុងបរិបទនេះ ខ្ញុំគិតថាលោកបានឃើញថាហេតុការណ៍នេះគឺនៅចុងឆ្នាំ១៩៧៥ ដែលផ្តល់វគ្គហ្នឹងចំពោះពួកបញ្ញវន្ត ពួកបញ្ញាជន ហើយខ្ញុំឲ្យលោកកែតម្រូវ បើខ្ញុំបញ្ជាក់កាលបរិច្ឆេទនេះមិនត្រឹមត្រូវ។

ខ្ញុំសួរលោកថា ប្រហែលលោកបាននិយាយរួចហើយ នៅពេលដែលយើងនិយាយអំពីសេចក្តីដកស្រង់មួយនោះ ហេតុអ្វីបានជាគំនិតនេះសំខាន់សម្រាប់បុគ្គលម្នាក់ៗ? ហេតុអ្វីក៏ត្រូវផ្សាយគំនិតនេះទៅដល់មហាជន? ម៉េចក៏គេមិនរក្សាទុកនៅក្នុងជួរកម្មាភិបាលខ្ពស់បក្សរបស់គេ?

[០៩:៥២:២៨]

**ឆ៖** នេះជាផ្នែកមួយ នេះជាការគិតផ្តត់គំនិតទូទៅអំពីការសម្លាត់ ជាគោលការណ៍សម្ងាត់របស់បក្សកុម្មុយនីកម្ពុជា។ ចំណេះដឹងគឺសម្រាប់តែអ្នកណាដែលគេត្រូវការចេះទេ។ បន្ទាប់ពីហ្នឹង គឺថារហូតទៅដល់ចុងបញ្ចប់នៃរបបនេះ ដែលវៀតណាមឈ្លានពានមកនោះ គឺថាអ្វីៗដែលខ្មែរក្រហមបាន

ធ្វើនោះ គឺថាសុទ្ធតែជាការសម្ងាត់ទាំងអស់។ អ្វីដែល ខៀវ សំផន បាននិយាយដែលថាត្រូវរក្សាការសម្ងាត់តែសម្រាប់កម្មាភិបាល កុំប្រាប់មហាជនឲ្យដឹងពីការសម្ងាត់ទាំងអស់នេះ គឺនេះជាចំណុចសំខាន់របស់គេនោះឯង។ ចំណុចនេះគឺថាត្រូវទុកជាការសម្ងាត់ កុំនិយាយចេញឲ្យសោះ។ នេះហើយគឺជាចំណុចមូលដ្ឋានដែលគេធ្វើ។

**ស៖** អ្វីដែលខ្ញុំយល់គឺថា នៅក្នុងការណែនាំរបស់គាត់នោះ គឺអាចនឹងទៅតាមមាគ៌ាបក្សរបស់ៗគេដែរឬទេ? ប្រសិនជាខ្ញុំដកស្រង់ខុស សូមលោកកែខ្ញុំផង។

[០៩:៥៣:៤៣]

**ឆ៖** ខ្ញុំគិតថាលោកអាចនិយាយថានយោបាយ អានោះគឺថាជាមាគ៌ា ជាគោលការណ៍ណែនាំរបស់បក្ស។

**ស៖** សូមអរគុណ។ សំណួរ ដូច្នេះខ្ញុំនឹងនិយាយអំពីប្រធានបទមួយម្តងទៅតាមលំដាប់លំដោយ ដើម្បីឲ្យតុលាការ ហើយនិងភាគីបានយល់ឲ្យច្បាស់អំពីគោលនយោបាយ ហើយនិងការណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ ខ្ញុំត្រឡប់ទៅឆ្នាំ១៩៦០។ នៅក្នុងសៀវភៅរបស់លោកបាននិយាយយ៉ាងលម្អិតអំពីសម័យកាលនោះ ហើយលោកបានរៀបរាប់អំពីការវិវត្តជាច្រើននៃដំណាក់កាលបក្សនោះ។ និយាយដោយសង្ខេបនោះ គឺថាសូមលោកកែខ្ញុំ បើខ្ញុំលើកឡើងត្រូវ ខ្ញុំនឹងនិយាយពីឆ្នាំ១៩៥០ អំពីកុម្មុយនីស្តដែលមានការវិវត្តចេញមកពីចលនាកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជាដែលថាមានសម្ព័ន្ធភាពជាមួយវៀតណាមពីដំបូងដើមនោះ។ ហើយលោកបានរៀបរាប់អំពីគណៈកម្មាធិការទីក្រុង គណៈកម្មាធិការផ្សេងៗនៅក្នុងទីក្រុងភ្នំពេញ ហើយនិងជាយក្រុងផ្សេងៗទៀតនោះ។ ហើយលោកបាននិយាយផងដែរអំពី ប៉ុល ពត, នួន ជា បានចូលរួមនៅក្នុងគណៈកម្មាធិការក្រុង នៅក្នុងឆ្នាំ១៩៥០បន្តមកនោះ។ បន្ទាប់មក លោកបានរៀបរាប់អំពីសមាជនៅក្នុងឆ្នាំ១៩៦០ នៅក្នុងខែធ្នូ។

ចំណុចចាប់ផ្តើមរបស់ខ្ញុំ ខ្ញុំចាប់ផ្តើមពីចំណុចនេះ គឺថាជាព្រឹត្តិការណ៍ដ៏សំខាន់មួយ របស់បក្សកុម្មុយនីស្តកម្ពុជាដែលលើកឡើងនូវសេចក្តីសម្រេចមួយចំនួន។ ខ្ញុំសូមដកស្រង់ចេញពីសៀវភៅត្រង់ចំណុចមួយ ដែលចាប់ផ្តើមពីទំព័រ១៣៧ ហើយបន្តទៅពីរទំព័រទៀតនៅក្នុងសៀវភៅរបស់លោក។ ហើយ ERN អង់គ្លេស 00396337, បារាំង ERN 00639617។

[០៩:៥៥:៥៦]

លោកបានរៀបរាប់អំពីការប្រមូលប្រជុំនៃគណៈប្រតិភូ២១នាក់ នៅផ្ទះមនុស្សម្នាក់ឈ្មោះ អ៊ុក

សុគន្ធ។ លោកបាននិយាយថា ការប្រជុំនោះ៣ថ្ងៃ។ នៅពេលនោះ គឺថាគេនៅ ទាំងអស់គ្នានៅតែមួយកន្លែងទេ។ ខ្ញុំសូមដកស្រង់សម្ដីរបស់លោក សារៈសំខាន់នៃការប្រជុំនោះ សូមដកស្រង់ "កម្មវិធីត្រូវបានសម្រេចដោយការប្រជុំ គឺកំណត់អំពីការចំណុចចាប់ផ្ដើមនូវមាគ៌ានយោបាយឯករាជ្យ គឺថាវណ្ណៈសក្ដិភូមិរបស់ សីហនុ ត្រូវបានលុបបំបាត់ចោល ហើយដែលអ្វីជាវៀតណាមបានលើកឡើងនោះ គឺជាខ្លាំងនោះ គឺថាជាឧបករណ៍របស់ចក្រពត្តិ។ ចំពោះ -- បើនិយាយអំពីកម្ពុជាត្រូវតែគោរពទៅតាមគោលការណ៍។ ដូច្នេះ កម្ពុជាត្រូវតែតស៊ូ លុបបំបាត់ចោលរបបសក្ដិភូមិ ដោយសន្តិវិធី ឬក៏ដោយវិធីផ្សេង"។ ខ្ញុំចង់ឲ្យលោកពន្យល់ ពង្រីកអំពីសេចក្ដីសម្រេចនេះ ទាក់ទងទៅនឹងចំណុចមួយដែលថា ហាណូយបានដាក់នយោបាយមួយ ដើម្បីសហការជាមួយ សីហនុ នោះ។ តើលោកអាចពន្យល់បន្ថែមបានទេ?

[០៩:៥៧:២៦]

**ឆះ** នៅក្នុងអំឡុងពេលទាំងមូលនេះ គឺថាដែលចាប់ផ្ដើមអំពីចំណុចចាប់ផ្ដើមមកនោះ ដែលថាគេមានឥស្សរៈ ហើយនិងក្រុមបះបោរប្រឆាំងបារាំងហ្នឹង គឺមកដល់ចុងទសវត្សរ៍ឆ្នាំ៦០, ១៩៦០ យើងឃើញថា ដំណាក់កាលមួយជំហានម្ដង គឺដកខ្លួនចេញរបស់បក្សកុម្មុយនីស្តកម្ពុជា ចេញពីវៀតណាម។ មានមូលហេតុពីរសំខាន់ហ្នឹង, គឺថាទី១ វៀតណាមចង់ឲ្យគេមើលឃើញថា ឬក៏គេចាត់ទុកខ្លួនគេថាជាបង ហើយឲ្យសមមិត្តប្អូន ដែលថាកម្ពុជាហ្នឹង មើលគេជាគំរូ ហើយរហូតមកដល់ឆ្នាំ១៩៦០ វានៅតែគំនិតហ្នឹងដដែល។ ប៉ុន្តែគេចាប់ផ្ដើមប្ដូរនៅឆ្នាំ១៩៧០ នៅពេលកម្ពុជាបានធ្វើសមាជមិនបានប្រាប់ទៅវៀតណាម មិនបានអញ្ជើញតំណាងវៀតណាមមកចូលរួមនោះ។ នេះហើយជាចំណុចចាប់ផ្ដើមសំខាន់ដែលបក្សកុម្មុយនីស្តកម្ពុជាឈានទៅរកឯករាជ្យរបស់ខ្លួននោះ។

[០៩:៥៨:៣៩]

ចំណុចទីពីរ គឺថាកម្ពុជា និងវៀតណាមនោះ គឺមានផលប្រយោជន៍ខុសគ្នា។ ចំពោះវៀតណាម សីហនុ គឺទ្រង់ឯករាជ្យ ដែលមានសមានចិត្ត។ ប៉ុន្តែមានចំណុចជាច្រើននៅក្នុងសម័យកាលនោះជាគោលការណ៍ហ្នឹង គេជឿថា អ្វីដែលអាមេរិកាំងនឹងធ្វើនោះ គឺវៀតណាមកុម្មុយនីស្តនឹងឈ្នះ ហើយគេនឹងធ្វើសេចក្ដីនយោបាយទៅតាមនោះ។ ចំពោះវៀតណាម គឺថាតាមសត្យានុម័តិ គឺសម្ដេច សីហនុ ជាសម្ព័ន្ធភាព។ ចំពោះបក្សកុម្មុយនីស្តកម្ពុជាវិញ គឺថាសម្ដេច សីហនុ និងរដ្ឋាភិបាលរបស់ព្រះអង្គគឺថានឹងត្រូវបានកំហិតនូវលទ្ធភាពមួយចំនួនដើម្បីការជំទាស់ ដែលមានថាការជំទាស់ទៅតាមផ្លូវច្បាប់នោះ។ ដូច្នេះ របបនោះគេចាត់ទុកថាជាខ្មាំង។ អ៊ីចឹងគឺថា គេមានវិធីសាស្ត្រពីរ មានផលប្រយោជន៍ពីរនៅក្នុង

គំនិតហ្នឹង។

**ស៖** ហើយយើងខ្ញុំនឹងត្រឡប់មករកប្រធានបទនេះវិញ នៅពេលណាមួយ។ សេចក្ដីដកស្រង់មួយអំពីផ្នែកដដែលនេះ បើសិនជាលោក -- ទំព័រ១៣៨, លើសៀវភៅរបស់លោក លោកបាននិយាយអំពីការជ្រើសតាំងមេដឹកនាំថ្មី។ សមាជបានតាំងតែងសមាជិកមេដឹកនាំ ហើយ ទូ សាមុត បានក្លាយជាលេខ, នួន ជា អនុលេខា, សាឡុត ស នៅលំដាប់ទីបី។ អ្នកទាំងបីនេះ ជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍។ អៀង សារី ដែលមានគុណសម្បត្តិសមស្របនោះ គឺថាជាអ្នកដឹកនាំវង់កុម្មុយនីស្ដនៅបារាំង ជាអ្នកដឹកនាំអតីត -- ស្ថិតនៅលំដាប់ទី៤ នៃបញ្ជី ហើយនិងក្រុមនិស្សិតដែលត្រឡប់មកពីបរទេសវិញនៅលំដាប់បន្តបន្ទាប់។ នេះជាចំណុចដែលយើងឃើញថា បញ្ញាជន ហើយស្ថិតនៅក្នុងបក្ស ថ្នាក់ដឹកនាំបក្សនោះ តើមានអានុភាពកើនឡើងនៅក្នុងអំណាចថា តើមានលក្ខណៈសំខាន់អ្វីទេនៅក្នុងសម័យកាលនោះ? ថាតើលោកអាចពន្យល់បន្ថែមតុលាការអ្វីទៀតបានដែរឬទេ?

[១០:០១:០១]

**ឆ៖** ខ្ញុំគិតថា អាចនិយាយបានថា នេះជាចំណុចកត់សម្គាល់នៃរយៈកាលដ៏សំខាន់ ជាឱកាសដ៏សំខាន់នៅពេលដែលយើងមើលឃើញថា បញ្ញាជនដែលត្រឡប់មកវិញនោះ សំខាន់ពីព្រោះនៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ បក្សនៅតែមានសារៈសំខាន់ ហើយភាគច្រើនគឺជាសមាជិកមកពីឥស្សរៈ ដូចជា ទូ សាមុត, កែ ពក, សោ ភឹម។ យើងត្រឡប់មកដល់ឆ្នាំ១៩៦០ គណៈអចិន្ត្រៃយ៍មានសមាជិកពេញសិទ្ធិបីរូប មិនមែនជាអតីតមេដឹកនាំឥស្សរៈនេះទេ។ ទូ សាមុត នៅជាប្រធាននៅឡើយ ហើយ នួន ជា ចេញមកពីក្រុមដែលអប់រំដោយថៃ, ហើយ ប៉ុល ពត ជានិស្សិតត្រឡប់មកវិញ, ហើយ អៀង សារី ក៏ដូច្នោះដែរ។ មានតែម្នាក់ទេដែលជា សោម ភឹម ដែលជាមេទ័ពនោះ។ អ៊ីចឹងហើយប្រព័ន្ធនោះបានប្ដូរ ហើយនិងប្ដូរជាបន្តទៅទៀត ទោះបីតែថាអ្នកទាំងនេះ អ្នកក្រុមទាំងបីនេះជាពិសេសមានតែក្រុមពីរទេ ដែលសំខាន់នោះ។

[១០:០២:១៨]

ក្រោយមកគេហៅថាផ្ទះថ្ម ហើយនិងផ្ទះធ្វើពីឈើអីជាដើម។ បន្ទាប់មកគេហៅពួកឥស្សរៈ ហើយបូកនឹង នួន ជា បន្ថែមទៅលើក្រុមឥស្សរៈនោះ ដែលមិនទាន់មានសារៈសំខាន់ទេ មកពីកុម្មុយនីស្ដថៃ។ អ៊ីចឹងថាជាក្រុមតូចទេ។

**ស៖** នៅពេលដែលយើងនិយាយអំពីសម័យកាលនេះ -- អំឡុងពេលនេះ យើងពិនិត្យមើលបរិបទ

គឺថាអាចនឹងចុងទសវត្សរ៍ឆ្នាំ១៩៥០ ឬ៦០ យើងមើលទំព័រ១៣២ នៃសៀវភៅរបស់លោក។ ERN អង់គ្លេស 00396332, បារាំង ERN 00639611។ លោកបាននិយាយនៅត្រង់នេះថា សកម្មភាពរបស់ ខៀវ សំផន នៅក្នុងអំឡុងពេលនោះ គឺអ្វីខ្លះ? វាមានភាពពាក់ព័ន្ធទៅនឹងការពិភាក្សារបស់យើងនាពេលនេះ លោកបាននិយាយដូចខាងក្រោមនេះ សូមដកស្រង់ "ដោយមានការក្លាហានគាត់បានដើរតាមគំរូរបស់ ហ៊ូ យន់ របស់សង្គមរាស្ត្រនិយម ប៉ុន្តែគេចាត់ទុកគាត់ថា គាត់ជាមន្ត្រីជាន់ខ្ពស់ដែលមានជោគវាសនាល្អ ហើយគាត់ -- ហើយបន្ទាប់មកការចាត់តាំងចេញពីគណៈក្រុងសម្ងាត់ ជាបញ្ញវន្តឲ្យទទួលបន្ទុកក្នុងការធ្វើសមានចិត្ត ហើយនិងពង្រឹងជីវិតនយោបាយជាតួនាទីដែលលោក ខៀវ សំផន ស័ក្តិសមចំពោះការងារនេះ"។ តើខ្ញុំយល់ត្រឹមត្រូវទេត្រង់ដកស្រង់នេះ សូមបើខ្ញុំដកស្រង់ខុសអាចនឹងចុងទសវត្សរ៍ឆ្នាំ១៩៥០ ឬដើមទសវត្សរ៍ឆ្នាំ១៩៦០។ ផ្នែកទៅលើការសិក្សារបស់លោក ថាតើទំនាក់ទំនងរវាងលោក ខៀវ សំផន និងក្រុមសម្ងាត់ គណៈកម្មការសម្ងាត់ក្រុងរបស់បក្សហ្នឹងយ៉ាងដូចម្ដេចបាទ?

[១០:០៤:៣៨]

**ឆះ** យើងនិយាយពីដើមឆ្នាំ១៩៦០ បាទ គឺថាវាមានទំនាក់ទំនងបែបនោះមែន។ ការទាក់ទងផ្ទាល់ជាមួយអ្នកណា ដោយវិធីណា នោះជាបញ្ហាដែលពិបាកយល់ ពីព្រោះថាវាមាន -- និយាយពីរបបសីហនុ សង្គមរាស្ត្រនិយមនៅកាលនោះ គឺមានការរៀបរាប់អំពីថាតើនៅក្នុងអំឡុងពេលនោះ គណៈកម្មការក្រុងរបស់កុម្មុយនីស្តមាន វន វ៉េត ជាដើមហ្នឹង បានធ្វើការទំនាក់ទំនងហ្នឹងខុសៗគ្នាតាមបណ្ដាញរបស់គេ។ បើយើងនិយាយថា វាមានការទាក់ទងដោយមិនផ្ទាល់ ដោយប្រយោល។ អ៊ីចឹងខ្ញុំសូមបន្ថែមលោកមិនបានអានឃ្លាបន្ទាប់នោះទេដែលនិយាយថា "ខៀវ សំផន ជាអ្នកស័ក្តិសមចំពោះតួនាទីនេះ គាត់ជាអ្នកឧត្តមគតិនិយម ហើយមានសីលធម៌ ហើយសម្បជញ្ញៈសង្គមបានល្អ គួរតែដាក់នៅក្នុងតំណែងនេះ"។ ហើយខ្ញុំដាកចេញពីសំណួរលោកបន្តិច នោះគឺថាលោក ខៀវ សំផន ធ្លាប់ជាមនុស្សរឹងមាំ ហើយជាអ្នកប្រកាន់ទ្រឹស្ដី ហើយជាមនុស្សដែលធ្វើការគឺស៊ីសង្វាក់ដូចថា *ខន់ស៊ីស្តែន* – គឺថាប្រកាន់អ្វីយកអាហ្នឹង គឺថាជាមនុស្សមានសីលធម៌ខ្ពស់ ហើយគាត់បន្តប្រកាន់នូវគោលការណ៍នេះដោយមិនចាំបាច់សួរសំណួរមកខ្លួនឯងច្រើនទេ ចំពោះអ្វីដែលគាត់ជឿជាក់ហើយនោះ គាត់មិនត្រូវមានឆ្ងល់លើអ្វីទេ។ បើថាគាត់សួរខ្លួនឯងច្រើនពេក ដូចជាធ្វើឲ្យខ្លួនឯងមិនមានសមត្ថភាព ការយល់អ៊ីចឹងវិញ។

[១០:០៦:៣៧]

**សះ** ដើម្បីបញ្ជាក់ឲ្យច្បាស់អំពីរបៀបទំនាក់ទំនងនេះ គឺថាប៉ុន្តែខ្ញុំយល់ត្រឹមត្រូវហើយអំពីខ្លឹម

សារដែលលោកយោងហ្នឹង គឺថាមានការចាត់តាំងដែលផ្តល់ទៅឲ្យលោក គឺដែលគណៈក្រុងសម្ងាត់នោះបានចាត់តាំងឲ្យលោក ខៀវ សំផន នោះ?

**ផៈ** បាទលោកដកស្រង់ត្រឹមត្រូវហើយអំពីអ្វីដែលខ្ញុំសរសេរនោះ។

**សៈ** សៀវភៅរបស់ហ្នឹងគឺថាពោរពេញទៅដោយព័ត៌មានគួរឲ្យចាប់អារម្មណ៍ និងសំខាន់ច្រើនណាស់។ ដោយសារខ្ញុំមានពេលវេលាមានកំណត់នោះ ខ្ញុំនឹងសួរតែចំណុចសំខាន់ៗបំផុតទេ។ ឥឡូវនេះខ្ញុំនឹងឈានចូលទៅដល់ឆ្នាំ១៩៦៤ លោកបានមើលសៀវភៅលើក្រដាស់ទំព័រ១៤៦។ ម្សិលមិញលោកបាននិយាយអំពីការប្តូរឈ្មោះរបស់បក្ស។ មូលហេតុដែលខ្ញុំបង្អង់បន្តិចហ្នឹង ខ្ញុំសួរសំណួរមួយចំនួន។ លោកបានរៀបរាប់អំពីការផ្លាស់ប្តូរ ឬក៏ចលនាចូលទៅដល់ថា ដកខ្លួនចេញពីការគ្រប់គ្រងរបស់វៀត-ណាមទៅជាបក្សឯករាជ្យ។ ឆ្នាំ១៩៦៤ មេដឹកនាំមួយចំនួនគឺថា បានរត់គេចខ្លួនចេញពីភ្នំពេញខ្លះទៅហើយ។ ទំព័រ១៤៦, ERN 003696346, បារាំង ERN 00639331។ អ៊ីចឹងគឺថានៅក្នុងឆ្នាំ១៩៥៣ លោកនិយាយថា “សញ្ញាជាក់ស្តែងមួយនៃជំហរឯករាជ្យនោះ គឺថាកើតឡើងនៅក្នុងរដូវរងារ -- រដូវផ្ការីក ដែលថាបក្សកុម្មុយនីស្តកម្ពុជាហ្នឹង គឺថាគេប្រជុំ បានធ្វើឡើងនៅព្រំដែនខាងកម្ពុជាដែលប្រើពេលពីរបីសប្តាហ៍ បានធ្វើសេចក្តីសម្រេចព្រាងមួយដែលទទួលយក គឺថាទម្រង់នៃការចលនាតស៊ូទាំងអស់ប្រឆាំងនឹង សីហនុ ផងដែរ។ គឺខ្លួនទីពឹងខ្លួន ហើយឲ្យមានសេរីភាពពីការត្រួតត្រារបស់វៀតណាមផងដែរ។

[១០:០៩:២១]

ដើម្បីឲ្យពេញទាំងស្រុង ខ្ញុំអានទំព័រមួយទៀត ដែលសេចក្តីព្រាងនៃសេចក្តីសម្រេចនោះគឺថាមានទាំងស្រុង។ លោកបាននិយាយថា “នៅខែមករា ឆ្នាំ១៩៦៣ គណៈអចិន្ត្រៃយ៍បានប្រជុំសម្រេចគឺក្នុងប្រជុំទី២ គឺថាជាគំនិតមូលដ្ឋានដើម្បីឈានទៅរកសង្គមនិយម គឺថាត្រូវប្រើហិង្សាបដិវត្តន៍ដើម្បីប្រឆាំងនឹងសក្តិភូមិ នាយទុន ហើយមេខ្លោងនៃចក្រពត្តិនិយម ហើយនិងនាយទុននិយម សក្តិភូមិនិយមត្រូវតែលុបបំបាត់ចេញពីកម្ពុជា។ នេះគឺ នេះជាការផ្លាស់ប្តូរ ឬក៏ការវិវត្តទៅរកភាពឯករាជ្យ ឬក៏សេរី-ភាពរបស់បក្សកុម្មុយនីស្តកម្ពុជានៅពេលនោះដែរឬទេ?

**ផៈ** នេះគឺជាជំហានដ៏សំខាន់ដើម្បីគេឈានទៅរកឯករាជ្យ។

**សៈ** ការអនុម័តិយកអំពីការប្រើហិង្សាបដិវត្តន៍ដើម្បីលុបបំបាត់ពួកសក្តិភូមិ នាយទុនអីទាំងអស់នេះ តើអានេះជាផ្នែកនៃការវិវត្តផ្លាស់ប្តូរគោលនយោបាយរបស់បក្សដែរឬទេ?

**ឆ៖** នេះហើយវាច្បាស់លាស់ជាងអ្វីដែលគេនិយាយពីមុនអំពីទម្រង់នៃការតស៊ូពីខាងដើមនោះ គឺខុសពីពេលនេះ។ ហិង្សាប្រដាប់អាវុធ ហិង្សាបដិវត្តន៍ហ្នឹងគឺថា បើយើងនិយាយពីគំនិតដែលយើងនិយាយថា ការដើរទៅរកអំណាចតាមប្រព័ន្ធសភាអីជាដើមនោះ គឺថាគេមិនបានអនុញ្ញាតឱ្យមានការជំទាស់អ្វីនោះទេ។ អ៊ីចឹងនៅក្នុងវិធីមួយនៅក្នុងកម្រិតខ្លះ គឺថាគេបង្ខំឱ្យប្រើអំពើហិង្សា បើទោះបីជាមានជម្រើសអ្វីៗផ្សេងទៀតនោះក៏ដោយ។ ហើយយើងឃើញថា គេនឹងឈានទៅដល់ហិង្សាបដិវត្តន៍នោះ។

[១០:១១:៤១]

**ស៖** បាទ ការវិវត្តមួយថ្មីទៀត គឺការទស្សនៈយល់ឃើញអំពីជនបទរវាងជនបទ ហើយនិងទីក្រុង ហើយនិងផលវិបាកខ្លះដែលបក្សធ្លាប់ជួបប្រទះ។ នៅក្នុងការរៀបរាប់របស់លោក និយាយអំពីនៅក្នុងទំព័រ -- នេះនៅទំព័រ១៤៩ នៃសៀវភៅរបស់លោក។ ERN គឺ 00639632, បារាំង 00639649។ សូមដកស្រង់ដូចតទៅ "បក្សកម្ពុជានៅពេលនេះ គឺនិយាយ គឺដើម្បីឱ្យចៀសផុតអំពីផលវិបាកមួយចំនួន។ សាឡុត ស មិនបានសួរថាតើខ្លួនបានធ្វើអ្វីខុសនោះទេ ប៉ុន្តែនៅក្នុងទម្រង់ដែរពួកគេមិនដែលជួបប្រទះនូវបរាជ័យនេះទេ។ នៅក្នុងឆ្នាំ១៩៦៥ ពួកគេបានថារោងចក្រ ហើយនិងកម្មករ គឺថាបានផ្លាស់ប្តូរទៅទី បណ្តាទីភ្នាក់ងារកម្មកររោងចក្រ គឺបានបដិសេធទទួលយកបញ្ចូលទៅក្នុងបក្ស"។ ខ្ញុំសូមឱ្យលោកពន្យល់ឱ្យបានទូលាយបន្តិចអំពីអភូតហេតុដែលនិយាយអំពីការដាក់បញ្ចូលរោងចក្រទៅក្នុងបក្ស ហើយនិងទស្សនៈយល់ឃើញរវាងជនបទ និងទីក្រុងនេះ?

[១០:១៣:២១]

**ឆ៖** ខ្ញុំយល់ឃើញថានៅក្នុងដំណាក់កាលនេះ ជាពិសេសទស្សនៈនៃវណ្ណៈកម្មករដែលបក្សកុម្មុយនីស្តកម្ពុជា គឺថាមិនមានការលើកលែងទេ។ ពួកគេបានជ្រើសរើសក្នុងចំណោមវណ្ណៈកម្មករ ហើយដែលជាវិធីសាស្ត្រលទ្ធិម៉ាក្សនិយមដែលធ្វើបែបនេះឯង។ ដោយយកទៅលើ គេហៅថាយកគោលការណ៍នៃបដិវត្តន៍ពីខាងផ្នែករោងចក្រនេះមកដាក់បញ្ចូល ហើយបក្សកុម្មុយនីស្តកម្ពុជាយល់ឃើញថាកម្មករ ពលករ -- ហើយក្រៅពីសួរខ្លួនឯងថាហេតុអីត្រូវធ្វើដូច្នេះនោះ? ដូចលោកបានអានអម្បាញ់មិញគឺថា ពួកគេបានយល់ឃើញថា ពួកគេបានមានគោលបំណងដាក់បញ្ចូលកម្មករនេះឯង។ នេះគឺជាវិធីមួយ។ ហើយក្រោយពីឆ្នាំ១៩៧៥ សួរថាតើគេបានធ្វើអ្វីខុសនៅតាមទីជនបទក្នុងប្រទេសកម្ពុជា? ហេតុអ្វីក៏គេមិន -- ហេតុអ្វីបានជាផលិតផលកសិកម្មមិនមានការកើនឡើង? គេធ្វើវិទ្ធង្សនាថាដោយសារតែភ្នាក់ងារវៀត-

ណាមមានការចូលធ្វើវិទ្ធង្សនានេះ។ ជាគោលការណ៍វាអាចត្រឹមត្រូវ។ ហេតុដូច្នេះឯង គេយល់ឃើញថាវាមានវិទ្ធង្សនាមកពីខាងក្រៅ។ នេះគឺអ្វីដែលបានកើតមានឡើងតាំងពីទសវត្សរ៍១៩៦០ ម្ល៉េះ។

[១០:១៤:៥៩]

**ស៖** សូមអរគុណ។ បាទ ខ្ញុំសូមបន្តទៅឆ្នាំ១៩៦៦វិញម្តង ហើយនិងការបោះឆ្នោតនៅក្នុងឆ្នាំ១៩៦៦។ ក្រោយពីលន់ នល់ បានបង្កើតរដ្ឋាភិបាលគណៈរដ្ឋមន្ត្រីមួយនោះ នេះគឺជា -- ទាក់ទងនឹងរដ្ឋាភិបាលនេះ គេបានសេចក្តី -- មជ្ឈិមបានធ្វើសេចក្តីសម្រេច។ សូមដកស្រង់, ខ្ញុំមានបំណងចង់សួរទៅលោក ថាតើនេះជាការវិវត្តមួយដែលមានការពាក់ព័ន្ធដែរ ឬក៏អត់នោះ? បាទ នៅត្រង់ទំព័រ១៦៤, ERN អង់គ្លេស 00396364, បារាំង 00639669។ បាទ ជីវប្រវត្តិនេះ គឺនិយាយអំពីនៅប្រទេសឥណ្ឌូនេស៊ី ហើយនិងជោគវាសនានៃបក្សកុម្មុយនីស្តឥណ្ឌូនេស៊ី។ ហើយថាតើគោលការណ៍ទាំងនោះ វាមានផលវិបាកយ៉ាងម៉េច ចំពោះបក្សកុម្មុយនីស្តកម្ពុជា? មេរៀនដែលសនេះ គឺថាពួកគហបតី គឺមិនអាចទុកចិត្តបានទេ ពួកគហបតីនេះ។ យុទ្ធសាស្ត្ររបស់វៀតណាមគឺមិនត្រឹមត្រូវទេ។ កុម្មុយនីស្តមិនអាចរស់នៅជាមួយសម្តេច សីហនុ ទេ ដោយសារតែទំនាស់ គឺវាជ្រាលជ្រៅណាស់។ ហេតុដូច្នេះហើយ ត្រូវតែមានការធ្វើម៉េច មានកំណែទម្រង់។

[១០:១៦:៣៦]

ជាទ្រឹស្តី គោលការណ៍ គឺត្រូវតែបង្រួបបង្រួមជាមួយអ្នកទាំងអស់ ដែលអាចបង្រួបបង្រួមជាមួយយើងបាន។ តែជាអនុវត្ត គឺថាចលនាបដិវត្តន៍នេះ គឺថាអ្នកដែលមិនមាននៅ -- អ្នកដែលមិននៅជាមួយយើង គឺប្រឆាំងនឹងយើងហើយ។ ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ គឺថាទទួលអាសនៈនៅក្នុងការបោះឆ្នោតខែកញ្ញា។ វាបញ្ជាក់អំពីគោលនយោបាយពេលនេះ ដែលសម្រាប់បក្សកម្ពុជានៅពេលនោះ។ ហើយចាប់ពីពេលនោះ គឺថាបក្សកុម្មុយនីស្តកម្ពុជាព្យាយាម គឺថាកំណត់ឲ្យច្បាស់រវាងយើង និងខ្មាំង។ ដូច គឺថាមានការបដិសេធ។

ឥឡូវនេះ យើងខ្ញុំសូមមើលទៅលើការវិវត្តថ្មីៗទៀត ទាក់ទងទៅនឹងអ្នកដែលនៅពីខាងក្រៅដែលត្រូវចាត់ទុកថាជាខ្មាំង។ តើនេះជាការវិវត្ត ហើយនិងមានការគំរាមកំហែងជាបន្តបន្ទាប់ នៅក្នុងឆ្នាំៗជាបន្តបន្ទាប់នោះ។ តើខ្ញុំយល់ឃើញដូច្នេះ ត្រឹមត្រូវទេ?

**ឆ៖** បាទ វាជាការត្រឹមត្រូវហើយ។ ចុះបើភាពប្រទូសរ៉ាយមួយ ពេលដែលលោកមើលទៅក្រោយបន្តិចនោះ របៀបដែលបក្សធ្វើការវិវត្តនោះ គឺថាវាមានភាពច្បាស់លាស់។ វាមានព្រឹត្តិការណ៍

មួយកើតឡើង បន្ទាប់មកព្រឹត្តិការណ៍មួយទៀត ប៉ុន្តែវាក្នុងទិសដៅតែមួយទេ។

[១០:១៨:១៣]

**ស៖** ហើយនៅក្នុងសៀវភៅរបស់លោកដដែលនេះ គឺថាបានរៀបរាប់លម្អិតណាស់។ ចូលមកដល់ខ្លឹមសារនេះដដែល លោកបាននិយាយថា ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម បានដកខ្លួនចេញពីសម្តេច។ នេះនៅក្នុងចុងឆ្នាំ -- ទសវត្សរ៍ឆ្នាំ១៩៦៦ ហើយថា ប៉ុល ពត ដែលជាផ្នែកមួយនៃថ្នាក់ដឹកនាំនោះបានចាកចេញពីភ្នំពេញ។ តើខ្ញុំត្រឹមត្រូវទេភាសាហ្នឹង គឺទំនាក់ទំនងកិច្ចសហប្រតិបត្តិការ -- លោកអាចប្រើពាក្យណាដែលលោកយល់ឃើញថា សមស្របទៅ គឺនិយាយពីសកម្មភាពរបស់លោក ខៀវ សំផន ដែលវាស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលលោករៀបរាប់នេះ?

**ឆ៖** ការថានិយាយពីភាពស៊ីសង្វាក់ ស៊ីគ្នានេះគឺថាការលំបាកមួយ នៅត្រង់ថា ការដែលដឹងឲ្យបានពិតប្រាកដ ថាតើមានការប្រឈមមុខយ៉ាងម៉េចដែរ រវាង ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ហើយនិងសមាជិកស្នូលនៃបក្សកុម្មុយនីស្តកម្ពុជា។ ប៉ុន្តែវាមានទំនាក់ទំនងក្នុងប្រតិបត្តិការរបស់ពួកគេនេះ គឺថាវាជាការប្រាកដហើយ។

**ស៖** សូមអរគុណ។ ខ្ញុំសូមនឹងត្រឡប់មក នឹងសួរទៅលើចំណុចនេះ បើសិនណាវាជាការស្មានៗសូមមេត្តាមិនបាច់ឆ្លើយទេ។ តាមដែលខ្ញុំយល់តាមចម្លើយលោកឆ្លើយពីមុនមករួចហើយមកនោះ គឺថាមានទំនាក់ទំនងរវាងអ្នកដែលនៅទីក្រុងភ្នំពេញ និងសមាជិកដែលនៅជនបទ។ បាទ មានន័យថា ដោយសារតែមានព្រឹត្តិការណ៍សំខាន់ៗកើតឡើង ហើយវាផ្តាច់ចេញពីគ្នា ពីព្រឹត្តិការណ៍មួយទៅព្រឹត្តិ-ការណ៍មួយ តើលោកយល់ថាម៉េច?

[១០:២០:២៨]

**ឆ៖** គឺថាមិនមានការដាច់ពីគ្នាទេ រវាងព្រឹត្តិការណ៍មួយទៅព្រឹត្តិការណ៍មួយ។ គឺថាវាមានទំនាក់ទំនងផ្ទាល់តែម្តង។ ខ្ញុំគិតថាប្រហែលជាត្រឹមត្រូវទេ ប៉ុន្តែវាអាចទស្សនៈមួយដែលគេអាចយល់ឃើញបែបនេះបាន។ សូមអរគុណ។

**ស៖** បាទ ខ្ញុំសូមផ្អាកបន្តិចអំពី និយាយអំពីការបះបោរនេះ ទុកវាមួយអន្លើ ដោយប្តូរប្រធានបទមួយផ្សេងទៅវិញ។ ខ្ញុំសូមឲ្យ -- សូមសួរលោកលឿនបន្តិច ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ក្នុងទសវត្សរ៍១៩៧០។ ដូចដែលយើងបានស្តាប់ឮហើយភស្តុតាងនៃ -- ដែលលោកបានរៀបរាប់អំពីការបង្កើតរណសិរ្សដោយមានសម្តេច សីហនុ ជាព្រះប្រមុខនោះ។ ខ្ញុំសូមផ្តោតទៅលើចំណុចមួយផ្សេងទៀត ប៉ុន្តែនៅក្នុង

អំឡុងពេលនុំងដដែល ហើយនិងព្រឹត្តិករណ៍សំខាន់ៗមួយចំនួនផងដែរ។

[១០:២១:៤១]

ហើយប្រសិនជាមើលទៅសៀវភៅរបស់លោក កន្លែងដែលទាក់ទងគឺទំព័រ២០២ រហូតទៅដល់ទំព័រ២០៥។ អ្វីដែលលោកបានសរសេររៀបរាប់នៅក្នុងទំព័រទាំងនេះ ជាចំណុចមួយដែលគេហៅថាមានភាពចម្រូងចម្រាសណាស់។ វាផ្ដើមចេញអំពីជ័យជម្នះខាងផ្នែកកងទ័ព ដែលទទួលបានដោយកងទ័ពវៀតណាមនោះ ដែលតាមការយល់ឃើញរបស់លោក គឺថាសម្រាប់ថ្នាក់ដឹកនាំកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា ហើយលោករៀបរាប់ថា វៀតណាម នៅក្នុងដំណាក់កាលនេះ គឺថាបានកាន់កាប់ប្រទេសកម្ពុជាបណ្ដាលខេត្តមួយចំនួន។

នៅទំព័រ២០៤, ERN ភាសាអង់គ្លេស 00396404, បារាំង 00639719 លោកបានសរសេរដូចតទៅ៖ សម្រាប់ សាឡុត ស និងសហការីរបស់គាត់ នេះគឺជាទ្វេគ្រោះហើយ នេះដោយសារតែវៀតណាមបានកាន់កាប់ទឹកដីមួយចំនួនតាមព្រំដែន ហើយនិងជាពិសេសភូមិភាគមួយចំនួនដែលត្រូវបានរំដោះនោះ។ ហើយម្យ៉ាងវិញទៀត មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានដឹងអំពីគ្រោះថ្នាក់នៃចំណុចនេះគេបានរៀបរាប់។ សូមដកស្រង់ “ពួកឈ្លានពានវៀតណាម បើសិនណាជាសមមិត្តបងប្អូនទាំងអស់ធ្វើលឿនពេក យើងមិនអាចទៅធ្វើបានទេ ចុងក្រោយគឺថាយើងនឹងមិនទទួលបានអីទេ”។

[១០:២៣:៥០]

នៅទំព័រ២០៥ ខ្ញុំសូមអានសង្ខេបទេ។ លោកបាននិយាយថា “ការត្រួតត្រាគ្រប់គ្រងរបស់វៀត-ណាម គឺថាបានកើតឡើងនៅក្នុងឆ្នាំ១៩៧០ ដោយមាន -- ដែលកើតចេញដោយសារកងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជា”។ លោកពន្យល់ពង្រីកបន្តិចទេ ត្រង់ចំណុចនេះ តើវាមានការពាក់ព័ន្ធគ្នាទេ? នៅក្នុងន័យថា ជ័យជម្នះខាងផ្នែកយោធារបស់វៀតណាម គឺថាបង្កើតឲ្យមានភាពភ័យខ្លាចយ៉ាងខ្លាំង ធ្វើឲ្យមានការភ័យខ្លាចខ្លាំងណាស់ដោយសារតែការគ្រប់គ្រងត្រួតត្រារបស់វៀតណាមនេះ។ សូមលោកពន្យល់ឲ្យបានក្បោះក្បាយបន្តិចបានទេ?

**ឆ៖** គឺថាវាមានការភ័យខ្លាចដោយសារតែការត្រួតត្រារបស់វៀតណាម ប៉ុន្តែត្រូវចងចាំថានៅពេលដែលមានរដ្ឋប្រហារ -- ពេលនោះប្រហែលជាមានគេហៅថា ចលនាតស៊ូប្រហែលជា ២០០០នាក់ទេ។ ចលនាទ័ពព្រៃហ្នឹងប្រហែលជា២០០០នាក់។ ដូច្នេះយើងឃើញថា កម្លាំងដែលមានតែ២០០០នាក់ទោះបីជាមានការជ្រើសរើសជាថ្មីៗបណ្ដុះបណ្ដាលហ្វឹកហ្វឺនក៏ដោយ។ ដូច្នេះ វាមិនមានតុល្យភាពរវាង

កងទ័ពខ្មែរដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ ដែលភ្ជាប់ខ្លួនទៅនឹងជាមួយវៀតណាម ដែលពួកវៀតណាមចូលមកក្នុងប្រទេសកម្ពុជា ហើយគ្រប់គ្រងដែនដីកម្ពុជាមួយចំនួននោះ មិនមានតុល្យភាពនឹងគ្នាទេ។ ខ្ញុំហៅថាមានការភ័យខ្លាចដោយសារតែការគ្រប់គ្រងរបស់វៀតណាមនេះ។ ប៉ុល ពត គឺថាមានបញ្ហា គាត់យល់ឃើញថាតើយើងត្រូវគ្រប់គ្រង យើងត្រូវលើកទង់យើងដោយរបៀបម៉េច បើសិនណាយើងច្រឡូលប្របល់ហើយ ដោយសារតែពួកគេមានកម្លាំងច្រើននៅក្នុងទីតាំងរបស់យើងបែបនេះ។ ដោយសារតែវៀតណាមបានធ្វើបង្កឲ្យមាការភ័យខ្លាចបែបហ្នឹង។ ជាពិសេសវាអាចមានការ -- គេហៅថាមានការ មានបញ្ហាការរួមគ្នាមួយ អាចមានមន្ត្រីកងទ័ពវៀតណាម ជាមួយនឹងមន្ត្រីកងទ័ពខ្មែរ បញ្ហាការរួមគ្នា ធ្វើឲ្យប៉ុល ពត មានការភ័យខ្លាច។ ដូច្នេះបញ្ហាពីរនេះ វាកើតមានឡើង។ ការអនុវត្តជាក់ស្តែងហើយនិងការភ័យខ្លាចដោយការជ្រៀតជ្រែកគ្រប់គ្រងរបស់វៀតណាម។

បើយើងមើលទៅឆ្នាំ១៩៥៤ គឺថាកិច្ចព្រមព្រៀងហ្សឺណែវ វៀតណាមគេដោះស្រាយរឿងរបស់គេបានត្រឹមត្រូវ។ ហើយយើងក្រោយមកក៏មានខ្មែរឥស្សរៈដែលពីមុនមិនធ្លាប់កើតមាននោះទេ។

[១០:២៦:៥២]

**ស៖** បាទ សូមអរគុណ។ ប្រហែលជាខ្ញុំនឹងត្រឡប់មកលើកបញ្ហាទំនាក់ទំនងជាមួយនឹងវៀត-ណាមនេះឡើងវិញ។ យើងខ្ញុំសូមបន្តទៅមុខ ប៉ុន្តែខ្ញុំនិយាយទៅតាមកាលប្បវត្តិរបស់វា។ លោករៀបរាប់អំពីហេតុការណ៍មួយចំនួន ឬក៏ការវិវត្តមួយចំនួន ត្រង់ទំព័រ២១០ គឺនៅទសវត្សរ៍ឆ្នាំ១៩៧០, ERN ជាភាសាអង់គ្លេស 00396410, បារាំង 00639726 ដល់ 27។ លោកបានសរសេរដូចតទៅ "ក្រៅពីហេតុផលដែលវានាំឲ្យបក្សមានបញ្ហានៅក្នុងទីក្រុងភ្នំពេញ។ បើសិនណារដ្ឋាភិបាល លន់ នល់ ដែលអ្នកទាំងអស់ជាកុម្មុយនីស្ត ហើយជាខ្មែរក្រហម ទាំងខ្មែរ ទាំងបរទេស នៅថ្ងៃទី២៦ កក្កដា អ្នកកាសែតបរទេសបានបាត់ខ្លួននៅក្នុងប្រទេសកម្ពុជាដោយសារវៀតកុង។ ហើយនេះគឺដោយសារតែការជឿនលឿនទៅមុខនៃខាងផ្នែកនយោបាយ។

[១០:២៨:០៨]

មានករណីលើកលែងបីនាក់ដែលចាប់បានក្នុងពេលសង្គ្រាម គឺចាប់ដោយខ្មែរក្រហម មេសាសនាក្តី ឬក៏អ្នកកាសែតក្តី ត្រូវបានសម្លាប់។ នេះគឺជាបញ្ហាបញ្ជាក់ឲ្យច្បាស់អំពីការកំណត់រវាងខ្មាំង ហើយនិងយើង"។ នេះគឺជាការវិវត្តជាក់ស្តែងដែលលោកបានរៀបរាប់រវាងខ្មាំង ហើយនិងខ្លួនយើងអ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** ទោះបីវាជាការវិវត្ត ឬក៏ជាបន្តដូចៗតែគ្នាក្តី។ ដូចខ្ញុំបាននិយាយខាងដើមហើយ ក្រោយពីឆ្នាំ១៩៦០ ក្រោយពីរដ្ឋាភិបាលលន់ នល់ ចូលកាន់អំណាច ខ្មែរក្រហមចូលកាន់អំណាច គឺថាគេបានវែកញែករវាងអ្នកដែលមិនមែន -- យើងគឺខ្មាំង ដោយកំណត់ខ្សែបន្ទាត់យ៉ាងច្បាស់រវាងខ្មាំង ហើយនិងខ្លួនយើង។ បាទនេះគឺជាគោលការណ៍ដែលគេកំណត់យ៉ាងដូច្នេះ។

[១០:២៩:១៧]

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណអ្នកជំនាញ។ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រងចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣០ នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥១:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាសការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ស្វូត ខ្ញុំនឹងសួរសំណួរបន្តទៅទៀតមួយចំនួន អំពីខ្លឹមសារចុងក្រោយដែលទាក់ទងទៅនឹងការសម្លាប់ជនបរទេស ដែលខ្មែរក្រហមបានចាប់ខ្លួននោះ ចាប់ពីឆ្នាំ៧០កន្លងមកនោះ។ ហើយខ្ញុំសួរបន្តទៅទៀត ទាក់ទងទៅនឹងសិក្សាស្រាវជ្រាវរបស់លោក តើនេះជាការប្រកាស ឬក៏ការទម្លាយឲ្យដឹងពីហេតុការណ៍ដំបូងជាព័ត៌មានដែលខ្មែរក្រហមបានប្រហារជីវិតមនុស្សបែបនោះទេ។ ជាលើកដំបូង ឬក៏យ៉ាងដូចម្ដេច?

**លោក ហ្វីលីព ស្វូត៖**

**ឆ៖** មិនមែនជាលើកទីដំបូងនោះទេ។ ចំណុចចាប់ផ្ដើមនោះ ខ្ញុំគិតថាប្រហែលជានៅ ខ្ញុំគិតថានៅរតនគិរីបន្ទាប់ពីមានការបះបោរនៅសំឡូត ហើយមានការប្រយុទ្ធគ្នានៅខេត្តផ្សេងៗទៀត។ ហើយក្នុងអំឡុងពេលនោះ នៅពេលដែលគេចាប់បានអ្នកទោសជាឈ្លើយសឹកហ្នឹង គឺថាអ្វីដែលខ្ញុំទទួលបានព័ត៌មាននោះ គឺថាប្រសិនបើពួកគេជាមនុស្សមូលដ្ឋាន ជាកងកម្លាំងប្រដាប់អាវុធរដ្ឋាភិបាលប្រឆាំងច្បាំងនឹងខ្មែរក្រហម ហើយបើសិនជាអ្នកមូលដ្ឋាន គេនឹងលែងមកវិញ។ ប្រសិនបើមិនមែនជាអ្នកមូលដ្ឋានទេ គឺថាឈ្លើយសឹងហ្នឹង គឺគេច្រើនតែសម្លាប់ចោលតាំងពីដំបូងមកម្ល៉េះ។

[១០:៥៣:២៧]

**ស៖** សូមអរគុណ។ សំណួរមួយចុងក្រោយទៀតអំពីប្រធានបទនេះ អំពីហេតុការណ៍នេះ អ៎! ព្រឹត្តិការណ៍នេះ។ ផ្អែកទៅលើការសិក្សាស្រាវជ្រាវរបស់លោកនោះ នយោបាយរបស់គេនោះគឺថា ឬក៏មាគ៌ារបស់គេនោះក្នុងសម័យកាលនោះ គឺត្រូវបានប្រកាសដោយបក្សជាមាគ៌ា ជាការណែនាំ ឬក៏ជាអ្វីដែលគេអនុម័តិសម្រេចនៅពេលនោះ។ គេហៅឈ្មោះនយោបាយនោះបែបណា?

**ឆ៖** នេះជាសំណួរដែលខ្ញុំសួរក្នុងសម្ភាសរបស់ខ្ញុំជាមួយមនុស្សមួយចំនួន។ ពួកគាត់ឆ្លើយថាមិនមានការណែនាំជាលាយលក្ខណ៍អក្សរទេ គេគ្រាន់តែថា "អ្វីដែលលោកធ្វើត្រូវតែធ្វើ អ្វីដែលអ្នកឯងដឹងថាត្រូវធ្វើតាមបក្សឲ្យធ្វើ"។ មិនមានការណែនាំទេ ប៉ុន្តែគេយល់ច្បាស់ថាត្រូវធ្វើបែបនោះ។

**ស៖** ខ្ញុំសួរសំណួរម្យ៉ាងវិញទៀត នៅក្នុងការសិក្សាស្រាវជ្រាវរបស់លោកទាក់ទងទៅនឹងឃើញថាមានភស្តុតាងអំពីៗការដាក់ទណ្ឌកម្មចំពោះអ្នកណាមិនធ្វើតាម ឬក៏គេណែនាំថា ត្រូវតែធ្វើបើមិនធ្វើមិនបាន។ តើឃើញភស្តុតាងបែបនោះដែរឬទេ?

[១០:៥៤:៥៩]

**ឆ៖** អត់ទេ។ មិនមានភស្តុតាងទេ ជាទូទៅនោះ គឺយើងមានករណីជាក់លាក់ ក្នុងករណីហ្វ្រង់ស្វ័រ ប៊ីហ្សូ ដែលក្រោយមកត្រូវបានគេដោះលែង ដោយផ្អែកតាមអនុសាសន៍ តាមសេចក្ដីសម្រេចរបស់ ប៉ុល ពត។ ប៉ុន្តែនេះ គឺជាករណីពិសេសណាស់ ជាទូទៅ គឺគ្មានទេ។ គ្មានដោះលែងអ្វីទេ។

**ស៖** ដូច្នេះ យើងស្ថិតនៅក្នុងដើមឆ្នាំ១៩៧០ សៀវភៅរបស់លោកបានរៀបរាប់អំពីមុខងារដំណើរការរបស់ថ្នាក់ដឹកនាំនៅកំពង់ធំជាដើមនោះ។ ខ្ញុំនឹងមានសំណួរមួយចំនួនអំពីព្រឹត្តិការណ៍នៅទីនោះ ហើយមានការប្រជុំសំខាន់ៗផងដែរនៅទីនោះ។

នៅទំព័រ២២៣ ក្នុងសៀវភៅរបស់លោក លោកបានសរសេរអំពីការបញ្ចូលសមាជិកទៅក្នុងបក្ស។ ពេលនោះ គឺថារណសិរ្សរួមរួបជាតិ គឺថាមានរួចហើយ។ អង់គ្លេស 00396423, បារាំង ERN 00639744។ លោកបាននិយាយដូច្នេះ “ចាប់ពីខែធ្នូ ឆ្នាំ១៩៧០ ក្រោយមក គឺថាជ្រើសតាំងយោធា គឺថាមិនប្រកាន់អំពីមូលដ្ឋាន មិនសួរសំណួរទេ អំពីគុណសម្បត្តិចូលបក្សនោះ គឺថាគេកំណត់ម៉ឺងម៉ាត់ជាង គឺថានិស្សិត ឬក៏ថាកសិករកណ្ដាល គឺថាអាចនឹងគេវិភាគ ប៉ុន្តែនៅទសវត្សរ៍ឆ្នាំ៦០ ត្រូវបានគេចាត់ទុកជាសមាជិកត្រៀមទេ។ ហើយយ៉ាងហោចណាស់ គឺថាគេឲ្យចូលរួមនៅក្នុងក្រុមយុវជន ហើយគេថា គេមានវណ្ណភាពដើមត្រឹមត្រូវទៅនឹងជួរបក្សបាន អ្នកជាកសិករក្រតែប៉ុណ្ណោះ”។

តើខ្លឹមសារនេះគឺថាមានសារៈសំខាន់អ្វីដែរទេ ទាក់ទងទៅនឹងការវិវត្តបក្សកុម្មុយនីស្តកម្ពុជា? ទាក់ទងទៅនឹងការបញ្ជ្រួញ ឬក៏ការរឹងបណ្ដឹងលក្ខខណ្ឌអ្នកដែលចូលជាសមាជិកបក្សនោះ?

[១០:៥៧:២៨]

**ឆ៖** ខ្ញុំគិតថាមានកត្តាពីរនៅទីនោះ។ ទី១ ដោយសារបក្សក្លាយទៅជាអង្គការ រួមជាមួយរណសិរ្សរួមរួបជាតិកម្ពុជានោះ គេពង្រឹងនូវចំណាំងនៅក្នុងបក្សខ្លួនឯង ដើម្បីធានាថា កុំឲ្យមាន វាមានការដួលរលំ ឬក៏ការបរាជ័យជាដើម។ ដើម្បីធានាឲ្យបក្សនោះ ក្លាយទៅជាមានវរជនរឹងមាំ ដែលថាកុំឲ្យមានអំពើពុករលួយ ឲ្យក្លាយទៅជាបក្សដ៏ធំ គេពង្រឹងសមត្ថភាពនៃការចូលបក្សហ្នឹង។ គេពិនិត្យលើវណ្ណភាពរបស់សមាជិក ដែលថាអ្នកណាដែលអាចចូលរួមបាន។ ប៉ុន្តែកត្តាផ្សេងទៀត ក្នុងទសវត្សរ៍ឆ្នាំ១៩៧០នោះ គឺថាវៀតណាម មានពួកវៀតកុង គឺថាមានកត្តាដើម្បីគេអនុវត្តផងដែរ ដែលថាកម្ពុជា គឺថាសមាជិករបស់បក្ស ត្រូវតែស្មោះត្រង់នឹងបក្សរបស់កម្ពុជានោះឯង។

**ស៖** នៅក្នុងផ្នែកមួយសៀវភៅនោះ គឺថា យើងនិយាយអំពីមន្ទីរ ដូចថា មន្ទីរ៧១ ជាតំបន់ដែលគេបង្កើតមន្ទីរ ដូចថាមន្ទីរស-៧១ ហើយមានមន្ទីរខាងព័ត៌មាន គឺ S-31។ នៅក្នុងបរិបទនេះ គឺខ្ញុំជឿថា

លោកបានរៀបរាប់អំពីវត្តមានរបស់ពួកបញ្ញាជនទៅកន្លែងនោះក្នុងសម័យកាលនោះផងដែរ។ បន្ទាប់មក លោកបាន -- មុននឹងសួរសំណួរ ខ្ញុំសួរសំណួរមួយនេះសិន។ តើយើអាចពន្យល់អំពីការបន្តការដាក់បញ្ចូលបញ្ញាជនទៅក្នុងបក្ស ដែលថាបន្ថែមទៅលើពួកវណ្ណៈកម្មករក្រីក្រជាដើមនោះ ថាតើលោកអាចពន្យល់អ្វីបន្ថែមបានទេ អំពីអ្នកដែលអាចចូលជាសមាជិកពេញសិទ្ធិនាកាលនោះ?

**ឆៈ** បញ្ញាជនគឺជាក្រុមសំខាន់ ដើម្បីឲ្យដឹកនាំក្បាលម៉ាស៊ីនឃោសនានៃ -- នៅក្នុងរណសិរ្សផងដែរ គឺថា -- ប៉ុន្តែក្រុមបញ្ញាជននោះគឺគេទុកមួយផ្នែក ដូចជា ហ៊ូ នឹម, ហ៊ូ យន់ ដែលធ្លាប់បានជាទំនាក់ទំនងធ្វើបក្សជាច្រើនឆ្នាំមកហើយ។ ប៉ុន្តែផ្ទុយទៅវិញត្រូវបានគេទុកឲ្យនៅកន្លែងដាច់មួយដោយឡែក ដើម្បីជូនជាឧទាហរណ៍ គឺថាគេបែងចែកដាច់ពីកន្លែងមួយគឺថា១ គេទុកឲ្យនៅក្នុងស-៧១ ប៉ុន្តែមិនឲ្យធ្វើដំណើរទៅកន្លែងណាផ្សេងទេ។ គឺត្រូវ -- បើថាត្រូវទៅណាមកណាត្រូវមានអ្នកយាម ឬក៏នីរសាររមជាមួយ។

[១១:០១:០១]

**សៈ** នៅក្នុងបរិបទនេះគឺថាទំព័របន្ទាប់មួយ គឺមានសេចក្ដីដកស្រង់ចុងក្រោយមួយ។ លោកនិយាយអំពី ស-៣១ ដែលនៅទីនោះមានតួអង្គសំខាន់ៗនៃចលនា លោកនិយាយថា "ខៀវ សំផន បានចំណាយពេលមួយចំនួននៅ ស-២១ អ៎! ស-៣១ (សូមកែតម្រូវ) ហើយក្រោយមក បន្ទាប់មកក៏ប្ដូរទៅមន្ទីរទួលពោធិ៍។ នៅទំព័រ ២២៦ ដល់ ២២៧ ដែលបុគ្គលបីរូបដែលគេស្គាល់ភាគច្រើន ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម បានវត្តមាននៅទីនោះ។ ថាតើលោកបានប្រភពព័ត៌មាននោះមកពីណា ដើម្បីឲ្យលោកអាចបញ្ជាក់ក្នុងសៀវភៅថា លោក ខៀវ សំផន បានប្ដូរមន្ទីរទៅជិត ប៉ុល ពត នោះ។ មិនមានហ្វូតណូត មិនមានលេខយោងទំព័រពន្យល់អ្វីទេ អំពីប្រភព។ ដូច្នេះ មានតែលោកទេដែលលោកអាចបញ្ជាក់តុលាការបាន?

**ឆៈ** ខ្ញុំអាចប្រាប់លោកថា ខ្ញុំបាននិយាយជាមួយបុគ្គលមួយចំនួនគឺថា ពឹង សយ ដែលខ្ញុំបានសួរគាត់ ជួបគាត់ដែលបានធ្វើការ។ ខ្ញុំសូមអានបន្តិច--

**សៈ** មានអាចយោងមួយចំនួនទាក់ទងទៅនឹងទំព័រនេះ គឺថាទំព័រ២២៥។ ប្រសិនបើលោកមិនអាចមើលឃើញទេ យើងអាចនឹងឆ្លងទៅចំណុចផ្សេងក៏បាន។

**ឆៈ** ខ្ញុំមើលឃើញថា ផ្នែកនៃព័ត៌មានដែលជាប្រភពនោះគឺថា ចម្លើយសារភាពរបស់ ទីវ អុល ហើយនិង ហ៊ូ នឹម ដែល ឌី.ស៊ី.ខេម គេបានរក្សាទុក គឺថាមជ្ឈមណ្ឌលឯកសារនោះ។ ពឹង សយ ដែល

បាន ខ្ញុំបានសម្ភាសពីរឿង ស-២១ ក៏មានឯកសារអំពីរឿងករណីព័ត៌មាននេះ គឺថាខ្ញុំបានសម្ភាសជាមួយ ពឹង សយ។ បាទ គឺភាគច្រើនគឺដឹងខ្លឹមសារមកពីចម្លើយសារភាព។

[១១:០៣:៤៨]

**ស៖** សូមលោកប្រាប់ពីវិធីដែលលោកអាចសន្និដ្ឋានថា ក្នុងចំណោមវីរជនទាំងបីនោះ គឺមានតែ លោក ខៀវ សំផន ទេដែលគេគោរព ទទួលស្គាល់ខ្លាំងនៅក្នុងបក្សនៃកាលនោះ?

**ឆ៖** អង្គហេតុដែលថាគាត់ត្រូវបានចូលទៅកាន់តែកៀកទៅ ប៉ុល ពត នោះគឺថា គាត់នៅតែ ជិតស្និទ្ធនឹង ប៉ុល ពត រីឯអ្នកផ្សេងទៀតមិនដូច្នោះទេ។ ពួកគាត់ទាំងអស់ហ្នឹងគឺមកពីភ្នំឱរ៉ាល់ ហើយ ទៅមូលដ្ឋានកំពង់ធំ ប៉ុន្តែលោក ខៀវ សំផន ត្រូវបានគេចុចយកចេញ។ នៅក្នុងអំឡុងពេលនោះលោក ប៉ុល ពត យល់ឃើញថា លោកខៀវ សំផន គប្បីត្រូវតែរៀបការ។ បន្ទាប់មកគាត់ក៏បានរៀបការនោះ មែន។ នេះហើយជាការចាប់អារម្មណ៍ក្នុងកម្រិតមួយខុសធម្មតាពី ប៉ុល ពត ទៅ ខៀវ សំផន រហូតដល់ គាត់ណែនាំឲ្យលោក ខៀវ សំផន រៀបការ គាត់ក៏រៀបការទៅតាមការណែនាំនោះផង។

[១១:០៥:០០]

**ស៖** ឥឡូវនេះទៅប្រធានបទខុសគ្នានេះបន្តិច បាទដោយសារខ្ញុំមានពេលវេលាខ្លី យើងមាន ព័ត៌មានច្រើនដែលត្រូវពិភាក្សាដេញដោលនោះ។ លោកបានពិភាក្សាអំពីសេចក្តីសម្រេចមួយចំនួនដែល គេបានធ្វើឡើងនៅខេត្តកំពង់ធំ ដែលគេ -- គណៈមជ្ឈិមគេបានប្រជុំសម្រេចនោះ។ ឥឡូវនេះទំព័រ២២៧ នៃសៀវភៅរបស់លោក ERN នោះគឺ 00396427 ភាសាអង់គ្លេស, បារាំង ERN 00639748។ លោកបាននិយាយដូចខាងក្រោមនេះ “ការប្រជុំភាគច្រើន គឺធ្វើឡើងដោយមានការរៀបចំ គឺថាគេបាន ឯកភាពលើព្រំប្រទល់ភូមិភាគ ដោយបញ្ជាក់ពីលេខកូដនីមួយៗទៅតាមឈ្មោះ។ បន្ទាប់មកភូមិភាគថ្មី ត្រូវបានបង្កើតនៅភ្នំពេញ គេហៅបង្កើតថា ភូមិភាគពិសេស ដូចជាតំបន់-- សម័យឥស្សរៈ គឺថា វន វ៉េត ទទួលបន្ទុក។ ហើយក្នុងភូមិភាគគេបែងចែកទៅជាតំបន់ ហើយនីមួយក៏ត្រូវមានលេខកូដដែរ”។ ឥឡូវយើងផ្តោះមួយកថាខណ្ឌ បន្ទាប់មកខាងក្រោមមួយទៀត “ការប្រជុំអនុម័តនៅការបង្កើតនូវកង កម្លាំងបី ដែលថាតាម -- ដែលពួកឈ្លប គឺថាមានកងល្បាតដែលធ្វើតួនាទីយោធា គឺកងទ័ពតំបន់ នៅថ្នាក់តំបន់ ថ្នាក់ស្រុក ហើយនិងកងកម្លាំងចម្បងដែលថា នៅតាមទ័ពស្រួចនៅថ្នាក់តំបន់”។ តើមាន ការវិវត្តអ្វីទេទាក់ទងទៅនឹងនិយាយអំពីរចនាសម្ព័ន្ធរដ្ឋបាលក្នុងការបង្កើតភូមិភាគ ហើយនិងតំបន់នៅ ខាងក្រោមភូមិភាគនេះ?

[១១:០៧:០០]

**ឆ៖** បាទ គឺមានដូច្នោះមែន។ យើងអាចត្រឡប់ទៅមើលក្រោយបន្តិចវិញ យើងមើលរចនាសម្ព័ន្ធជាគ្រោង គឺថាមានទ័ពព្រៃមួយចំនួនតូចដែលមានសាខាបក្សមួយចំនួនតូច បក្សមិនទាន់ខ្លាំងទេនៅជនបទនាកាលនោះ។ ហើយតាមពិតនៅជនបទក៏ -- នៅទីក្រុងក៏មិនសូវខ្លាំងប៉ុន្មានដែរ។ ឥឡូវនេះវៀតណាមបានចូលមក គឺថាតំបន់ភាគច្រើននោះ គឺថាកុម្មុយនីស្តត្រួតត្រា។ ដូច្នេះហើយបក្សកុម្មុយនីស្តកម្ពុជា គឺត្រូវតែពង្រឹងឲ្យលឿននៅពេលដែលវៀតណាមដកទៅខ្លួននឹងបន្តសកម្មភាពរបស់ខ្លួនបាន។

**ស៖** ឥឡូវនេះ ខ្ញុំនឹងបន្តទៅទំព័រដដែល២២៧។ នេះជាការពិភាក្សាអំពីសមាជ ឬក៏ការប្រជុំរបស់ -- នៅក្នុងខែសីហា ឬកញ្ញា ឆ្នាំ១៩៧១ តាមដែលសៀវភៅរបស់លោកបានសរសេរនោះ។ ERN ហ្នឹងគឺថាអង់គ្លេស 00396427, បារាំង ERN 00639748 រហូតដល់ 9 នៅខាងចុង។ នេះគឺជាខ្លឹមសារមួយដែលខ្ញុំចាប់អារម្មណ៍ខ្លាំង។

[១១:០៨:៣១]

"ប្រតិភូ៦០នាក់ គឺថា មកពីភូមិភាគ តំបន់ មេបញ្ជាការយោធា ដូច កែ ពក, គង់ សុផលតំណាងបញ្ញាជន, ដូចជា ហ៊ូ យន់, ហ៊ូ នឹម ហើយនិង ខៀវ សំផន ហើយនិងក្រុមមួយចំនួនដែលត្រឡប់មកពីហាណូយផង។ នៅពេលនោះដែលបញ្ចប់នៅក្នុងពាក់កណ្ដាលខែកញ្ញា គឺគេបានសម្រេចដើម្បីកែឈ្មោះបក្សកុម្មុយនីស្តកម្ពុជាដែលបានអនុម័តពី៥ឆ្នាំហើយ បញ្ជាក់ថា ប៉ុល ពត ជាលេខាបក្ស" បាទហើយបញ្ចប់សេចក្ដីដកស្រង់។ ហើយលោកបានរៀបរាប់គឺថា គណៈមជ្ឈិម ហើយសមាជិក ៣០នាក់ត្រូវបានជ្រើសតាំង មាន ជូ ជេត, កុយ ធួន, វី, ហើយនិង ខៀវ សំផន ហើយនិង ខៀវ ប៉ុណ្ណារីផង។ ហើយលោកបានបញ្ជាក់ថា ហ៊ូ យន់, ហ៊ូ នឹម មិនបានដាក់បញ្ចូលទេទាំងពីរនាក់នេះ។ នន់ សួនក៏មិនបានដាក់បញ្ចូលដែរ គឺនិយាយក្រុមមកពីហាណូយ គេមិនបញ្ចូលទេ។

ដើម្បីឲ្យលោកបំភ្លឺកាលពីម្សិលមិញនោះ គឺថាលោកមានការលំបាកក្នុងការបញ្ជាក់ពីការបរិច្ឆេទដែលគេចាត់តាំងលោក ខៀវ សំផន ឲ្យចូលក្នុងគណៈមជ្ឈិមនេះ តើនេះជាកាលបរិច្ឆេទត្រឹមត្រូវទេនៅក្នុងឆ្នាំ១៩៧១ មិនមែនជា -- មិនមែនមុននឹងទេ? ដូច្នេះសូមលោកបញ្ជាក់។

**ឆ៖** លោកបញ្ជាក់ត្រូវហើយ ខ្ញុំនិយាយខុសទេម្សិលមិញនោះ។ គឺកាលបរិច្ឆេទត្រឹមត្រូវឆ្នាំ១៩៧១។

**ស៖** អរគុណហើយដែលលោកថាពិបាក ព្រោះយើងមានកាលបរិច្ឆេទច្រើនដែលត្រូវនិយាយ។

លោកនិយាយថា "ហ៊ូ នឹម, ហ៊ូ យន់ មិនត្រូវបានចាត់តាំងទេ។ នន់ សួន ក៏គេមិនចាត់តាំងទេ ប៉ុន្តែនៅខាងដើមសៀវភៅ គឺថាអ្នកទាំងបីនេះជាសមាជិកក្នុងក្រុមប្រជាជន"។ តើមានកត្តាអ្វីសំខាន់ទេ ក្នុងការជ្រើសតាំងមនុស្សឲ្យចូលក្នុងគណៈមជ្ឈិមនាពេលនោះ នោះ?

[១១:១០:៣៣]

**ឆ៖** បាទមែន វាឆ្លុះបញ្ចាំងអំពីទស្សនៈអ្នកដែលមកពីកន្លែងផ្សេង មកចូលក្នុងបក្សកុម្មុយនីស្តកម្ពុជាគឺថាគេអត់ទុកចិត្តទេ ចំពោះអ្នកដែលមកពីហាណូយវិញ គឺពួកខ្មែរដែលផ្នែកនៃចលនាកុម្មុយនីស្តដែលវៀតណាម គេគ្រប់គ្រងពួកគេ ពួកខ្មែរនោះបានទៅវៀតណាមបន្ទាប់ពីចប់សង្គ្រាម បន្ទាប់មកពួកគេមកវិញ។ គេមិនទុកចិត្តអ្នកទាំងនេះទេ ខ្មែរក្រហមនោះ។ គ្រាន់តែគេយល់ថាអ្នកនេះគឺត្រូវបានបំពាក់បំប៉នដោយវៀតណាម។ ចំពោះក្រុមប្រជាជនវិញ គេជាចលនាផ្លូវច្បាប់ គេថាជាក្រុមជំទាស់។ ក្រុមនេះក៏បក្សកុម្មុយនីស្តកម្ពុជាមិនទុកចិត្តដែរ។ ដូច្នេះហើយគេចាត់ក្រុមនេះវាខុសពីក្រុមស្នូលរបស់ប៉ុល ពត។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងមើលបញ្ហាមនុស្សដែលលោកបានដាក់បញ្ចូលក្នុងសៀវភៅនេះ។ ខ្ញុំឃើញថា ភាគច្រើននៃអ្នកទាំងនោះគឺថាមកអំពីភូមិភាគតំបន់ លើកលែងតែ ខៀវ សំផន ហើយនិង ខៀវ ប៊ុណ្ណារី ទេដែលត្រូវបានគេជ្រើសតាំងជាសមាជិកត្រៀមនោះ។ តើបន្ថែមទៅអ្វីដែលលោកដឹងដែរឬទេ? តើលោកអាចជម្រាបអ្វីបន្ថែមដល់តុលាការបានទេ មានសមាជិកថ្មីពីរនេះ?

**ឆ៖** គណៈមជ្ឈិមរបស់បក្សនោះ គឺដែលនៅក្នុងការតស៊ូជាទ័ពព្រៃនោះ គឺថាវាត្រូវតែស្របទៅនឹង ហើយតំណាងហ្នឹងគឺថាត្រូវតែមានតំណាងមកពីភូមិភាគតំបន់នោះឯង។ ចំពោះបក្សកុម្មុយនីស្តកម្ពុជាជាក្រុមដែលមជ្ឈិមហ្នឹង គឺថាគេកំណត់ចំនួនតូចណាស់។

**ស៖** សូមអរគុណ។ ការប្រជុំមួយទៀតដែលសំខាន់នោះ គឺទាក់ទងទំព័រ២២៨ គឺថានិយាយថាឆ្នាំ១៩៧២ គណៈមជ្ឈិមបានប្រជុំ។ មូលហេតុដែលខ្ញុំចូលមកបញ្ហានេះ ដោយលោកថាជាចំណុចបត់របត់មួយរបស់បក្សនោះ។ ខ្ញុំនឹងអានខ្លឹមសារពាក់ព័ន្ធ។ អង់គ្លេស ERN 00396428, បារាំង ERN 00639749។ ខ្ញុំជឿថាលេខអឺចឹងបើខុស ចាំខ្ញុំកែនៅពេលក្រោយ។ លោកបាននិយាយដូចខាងក្រោមនេះ៖

[១១:១៣:៣០]

"នៅតាម -- តាមការជំរុញរបស់ ប៉ុល ពត គឺថាគណៈបានជំរុញក្នុងការពង្រឹងជំហរវណ្ណៈអធនហើយនិងមើលវណ្ណៈគាបសង្កត់នៅក្នុងរបបថ្មីនោះ។ ការចូលរួមក៏បានបោះពុម្ពផែនការសមូហភាវូប-

នីយកម្ម កសិកម្ម។ ហើយកាលណាស្ថានភាពអំណោយផលនោះ គឺជាចំណុចបត់មួយ”។ ខ្ញុំសួរចំណុចចុងក្រោយនេះ ប្រយោគចុងក្រោយលោកនិយាយថា ហេតុអីបានជាធ្វើបែបនេះបានជាចំណុចបត់មួយរបស់បក្សនៅពេលនោះ?

**ឆ៖** ដោយសារ ប៉ុល ពត គឺថាអាចនឹងបន្ទាប់ពីធ្វើការ អ៎! ធ្វើដំណើរបីខែទៅតាមខេត្តនោះ។ គាត់ត្រឡប់មកវិញដោយមានការចាប់អារម្មណ៍ ហើយគាត់គិតថាយើងដើរទៅនោះវាយឺតពេក។ គឺថាមិនត្រឹមតែយឺតទេ ប៉ុន្តែដំណាក់កាលហ្នឹងគឺថាយើងអាចឈានដល់ហើយ យើងអាចនឹងទៅមុខឲ្យលឿនជាងមុនទៀតដែលកងកម្លាំងកម្ពុជាឈានដល់កម្រិតមួយមិនអាចនឹង -- អាចនឹងប្រកាន់ជំហរដាច់ឯករាជ្យពីវៀតណាម។ ប៉ុន្តែគេថាគ្រប់គ្រាន់សម្រាប់ការតស៊ូរបស់បក្សបានហើយ។ អ៊ីចឹងហើយគេយល់ថា ចាប់ផ្តើមធ្វើសមូហភាវូបនីយកម្ម ហើយនិងបក្សកុម្មុយនីស្តកម្ពុជាចាប់ពង្រឹងពីពេលនេះទៅនោះ។

[១១:១៥:១១]

**ស៖** ខ្ញុំនឹងអានខ្លឹមសារមួយនៅក្នុងសៀវភៅនេះ គឺថាដើម្បីពីរទំព័រទៅខាងមុខទៀត។ លោកបាននិយាយដូចខាងក្រោមនេះ។ ឥឡូវយើងនិយាយអំពីសម័យកាលក្រោយពីការប្រជុំគណៈមជ្ឈិម។ សូមដកស្រង់ “ការជំទាស់បដិវត្តន៍ដោយពាក្យក្តី កាយវិការក៏ដោយ គឺត្រូវតែអ្នកនោះត្រូវតែស្លាប់។ ដូច្នេះគេនឹងកោះហៅអ្នកហ្នឹងទៅមន្ទីរស្រុក ហើយមិនដែលឃើញត្រឡប់មកវិញទេអ្នកដែលជំទាស់នឹងបក្ស។ អ៊ីចឹងហើយគឺទណ្ឌកម្មគេតែងដាក់ចំពោះអ្នកនោះ។ គឺថានៅ -- យើងមានការបះបោរ ហើយមានការសម្លាប់កម្មាភិបាលបីនាក់។ ហើយសមាជិកក្រុមគ្រួសារបីនាក់ ដែលថាជាខ្សែរបស់គេនោះរួមទាំងកូន ហើយនិងទារកផង ត្រូវបានគេវាយសម្លាប់”។ តើលោកចាត់ទុកថានេះជាការលើកលែងឬយ៉ាងដូចម្តេច?

[១១:១៦:១៩]

ហើយនៅខាងក្រោមបន្តិចលោកនិយាយថា “បន្ទាប់ពីកិច្ចប្រជុំរបស់គណៈមជ្ឈិម នៅខែឧសភាឆ្នាំ១៩៧២ អ្វីៗបានកែប្រែ”។ តើត្រឹមត្រូវដែរឬទេពីខ្លឹមសារនេះ គឺមានៗការពង្រឹងនូវវិធានការរបស់នោះ។ ខ្ញុំសូម -- ទាក់ទងទៅនឹងការពង្រឹងអនុវត្តគោលនយោបាយរបស់គេទាក់ទងទៅនឹងថា មានលក្ខណៈជ្រុលនិយម ឬដូចម្តេច? ឬក៏រឹងមាំជាងមុនបាទ?

**ឆ៖** បាទ នេះខ្ញុំសូមឆ្លើយសង្ខេប វាមានការពង្រឹង គឺមូលដ្ឋានជាគ្រឹះនោះគឺថាការកើនកំណើន

នៃកងទ័ពខ្មែរនោះ គឺឈានដល់កម្រិតមួយ គឺថាវាឈានដល់ចំណុចចាំបាច់ដើម្បីឲ្យទទួលបានការគាំទ្រពីវណ្ណៈកសិករនោះឲ្យបានគ្រប់គ្រាន់ ដោយភាពទន់ភ្លន់ដែលៗបក្សគេគិតថាចង់ឲ្យបានការជោគជ័យក្នុងការគាំទ្រនេះ ហើយពេលនោះឯងដែលគេគិតថាដល់ឆ្នាំ១៩៧២ រហូតដល់៧៥ គេយល់ថាគេមានការគាំទ្រគ្រប់គ្រាន់។

[១១:១៧:៥០]

**ស៖** សូមអរគុណ។ ហើយទាក់ទងនឹងខ្លឹមសារដែលខ្ញុំអាន ទាក់ទងទៅនឹងការណែនាំដែលបានសម្រេចនៅក្នុងកិច្ចប្រជុំនោះ លោកនិយាយថា មានពាក្យមួយដើម្បីពង្រឹងការតស៊ូប្រឆាំងនឹងវណ្ណៈៗបាទវណ្ណៈគាបសង្កត់នោះ។ គឺថាការតស៊ូប្រឆាំងនឹងវណ្ណៈផ្សេងទៀត វណ្ណៈជិះជាន់ ឬក៏វណ្ណៈគាបសង្កត់គេជាដើមហ្នឹង។ តើលោកអាចពន្យល់តុលាការអ្វីថែមទេ?

**ឆ៖** ខ្ញុំពិបាកនឹងវិនិច្ឆ័យណាស់ ពីព្រោះលោកនិយាយអំពីវណ្ណៈគាបសង្កត់នៅក្នុងតំបន់ដែលខ្មែរក្រហម គេមានប្រតិបត្តិការណ៍ ជាតំបន់រំដោះ គេហៅ។ ខ្ញុំអាចបកស្រាយថា មានន័យថាដូចជាពួកពាណិជ្ជករ ហើយគ្រួសារដែលមានធនធាន អ្នកដែលមានអំណាចជាមេភូមិជាដើមហ្នឹង ដែលមានទំនាក់ទំនងជាមួយ លន់ នល់។ អាហ្នឹងគេហៅថាពួកវណ្ណៈដែលគាបសង្កត់គេហើយ។ អាហ្នឹងតាមដែលខ្ញុំបកស្រាយន័យរបស់គេនោះ។

[១១:១៩:០១]

**ស៖** សូមអរគុណ។ ឥឡូវនេះ បាតុភូតមួយដែលលោកបានសរសេរដែរនោះ គឺថានៅក្នុងសម័យកាលនោះ គឺបញ្ហាអំពីការប្រជុំទិតៀន ស្វ័យទិតៀន។ ចាប់ផ្ដើមនៅទំព័រ២៣២ នៅទំព័រ ដើង -- ផ្នែកខាងក្រោមនៃទំព័រ ERN នោះគឺ 00396433, បារាំង ERN 00689756 ហើយនិងទំព័របន្ទាប់។ លោកបាននិយាយយោងទៅរកករណី ហ្វ្រង់ស្វ័រ ប៊ីហ្សូ ដែលថាមានការប្រជុំទិតៀន ស្វ័យទិតៀន នៅពេលដែលគេឃុំខ្លួនគាត់នោះ។ អ៊ីចឹងគឺថានៅក្នុងទំព័រ២៣៣ គឺថាក្នុងចំណោមខ្មែរក្រហមខ្លួនឯងហ្នឹង វិធីនៃការជ្រើសរើសគឺថាគេប្រើប្រព័ន្ធទិតៀន ស្វ័យទិតៀន ការងារពលកម្ម ហើយនិងការរៀនសូត្រ។ រៀនឲ្យចាំមាត់អំពី ទន្ទេញអំពីអត្ថបទបក្សកុម្មុយនីស្ត។ ការទិតៀន និងស្វ័យទិតៀន គេហៅថាស្ថិតនៅក្នុងប្រជុំជីវភាព នៅក្នុងក្រុមតូចៗ ពីរដងក្នុងមួយសប្ដាហ៍។ នៅខាងក្រោមបន្តិច លោកនិយាយថា “លោក ខៀវ សំផន និយាយថា ហៅថា ជាការទទួលខុសត្រូវចំពោះសកម្មភាពប្រឆាំងនឹងបដិវត្តន៍ការងារបែបនោះ”។ ខ្ញុំសួរដំបូង ទី១ តើអ្វីៗទាំងអស់នេះ សុទ្ធតែជាការអនុវត្តគ្រប់លំដាប់នៃចលនា

ទាំងអស់ទេ នៅសម័យកាលនោះ បាទ ដែលយើងនិយាយនេះ?

[១១:២១:០៨]

**ឆ៖** បាទ គឺថាគេអនុវត្តបែបនេះរហូតដល់ថ្នាក់មជ្ឈិមនោះ។

**ស៖** អ្វីដែលលោកដកស្រង់សម្ដី ខៀវ សំផន អំពីវគ្គទិតៀន ស្វ័យទិតៀន ដែលគាត់បានចូលរួមនោះ តើគាត់បានប្រាប់លោកអំពីក្រុមណាដែលគាត់បានចូលរួមជាមួយទេ នៅក្នុងវគ្គទិតៀន ស្វ័យទិតៀននោះ?

**ឆ៖** ទេ គាត់មិនបានបញ្ជាក់ទេ។ ខ្ញុំអាចនឹងមើលកំណត់ដៃរបស់ខ្ញុំវិញ។ ខ្ញុំគិតថាលោក ខៀវ សំផន រៀបរាប់ គឺថាមិនមែនគាត់ទេ ជាអ្នកផ្សេងទេដែលធ្វើ។ ហើយគាត់បានរៀបរាប់អំពីការប្រជុំរៀនសូត្រ គឺថាមុនពេលកិច្ចប្រជុំគណៈមជ្ឈិម គឺថាជាវិធីដែលគេឲ្យធ្វើចាំមាត់ ដូចសូត្រទន្ទេញអ៊ីចឹងអំពីទិតៀន ស្វ័យទិតៀននេះ។

**ស៖** ទាក់ទងទៅនឹងការទន្ទេញអត្ថបទ ទន្ទេញមេរៀនសូត្រ ហើយនិងការរៀនសូត្រនេះ អ្វីដែលការស្រាវជ្រាវរបស់លោករកឃើញនេះ ថាតើគេមានការពិភាក្សាទៅតាមគោលការណ៍ ដែលយើងបានពិភាក្សាទេ ដូចជាការតស៊ូវណ្ណៈ សមូហភាវូបនីយកម្ម ជាដើម ក៏ដូចថា ដូចជាការទិតៀន ស្វ័យទិតៀនហ្នឹង ថាតើគេត្រូវធ្វើបែបនេះ ដើម្បីលើកកម្ពស់គោលការណ៍របស់គេទេ?

[១១:២២:៤២]

**ឆ៖** អ្វីដែលខ្ញុំយល់អំពីការប្រជុំជីវភាព ឬក៏វគ្គសិក្សារបស់គេនោះ។ ជាសំខាន់នោះ គឺការពិនិត្យមើលខ្លួនឯង គឺទិតៀនខ្លួនឯង។ ប៉ុន្តែនិយាយពីគោលការណ៍ខាងក្រៅវិញ គឺថាវាមាន វាអាចនឹងគណៈមជ្ឈិម ឬក៏គេនិយាយនៅក្នុងសាខាបក្សជាដើម។

**ស៖** អំពីការវិវត្តមួយទៀត នៅក្នុងសម័យកាល នៅក្នុងឆ្នាំ១៩៧២។ បាទ នៅ៧២ ឆ្នាំ១៩៧២ នៅឡើយទេ។ ឥឡូវនេះ ទំព័រ២៣៦ ដល់ ២៣៧ លោកបានរៀបរាប់អំពីការដកខ្លួនជាបណ្ដើរៗរបស់ទ័ពវៀតណាមនៅកាលនោះ។ អ្វីដែលខ្ញុំចាប់អារម្មណ៍នោះ លោករៀបរាប់ថា គឺលោកនិយាយថាជាការជំទាស់ចំពោះនឹងចលនានោះ បើសិនជាខ្ញុំយល់ត្រឹមត្រូវ។ ERN ហ្នឹង គឺ 00366463 ហើយអង់គ្លេស, 00639761 ជាភាសាបារាំង។ នៅដើមឆ្នាំ១៩៧២ ទំនាក់ទំនងជាមួយវៀតណាម បានស្រុតចុះ ហ្វ៊ូ យន់ -- បាទ កំណត់នៅក្នុងដើមឆ្នាំមុន -- កត្តាសំខាន់នោះ គឺថាពង្រឹងកម្លាំងយោធាដោយខ្មែរក្រហម គឺថាមាន២៥.០០០នាក់ តែងតែកើនឡើងជាញឹកញាប់។ បាទ គឺថា៣៥.០០០នាក់ ហើយនៅពេលដែលគេ

មានសមត្ថភាពអាចនឹងធ្វើសង្គ្រាមដោយខ្លួនឯងបាន ហើយនិងពិនិត្យមើលកងទ័ពដែលមានខ្មែរវៀត-ណាម ហើយនិងពួកខ្មែររំដោះ ដែលនិយម សីហនុ ដែលហ្វឹកហ្វឺនដោយវៀតណាម ហើយក៏យកមកចូលក្រោមបញ្ជាខ្មែរក្រហមដែរ។

[១១:២៤:៥៣]

នៅទំព័របន្ទាប់ ខ្ញុំនឹងអានចំណុចនេះ ដែលវាមានខ្លឹមសារពាក់ព័ន្ធគ្នានៅក្នុងបរិបទ។ លោកបាននិយាយដូចខាងក្រោមនេះ៖ "នៅដើមឆ្នាំ១៩៧២ កងពលចម្បងរបស់វៀតណាមបានដកចេញពីកម្ពុជា ហើយក្រោយមកគេអះអាងថា ខ្មែរក្រហមបង្ខំឲ្យគេដកថយ ហើយការបណ្តេញគឺចេញពីថ្នាក់ខ្ពស់របស់ខ្មែរក្រហម។ ការណ៍នេះមិនពិតទេ គឺគេសម្រេចចិត្តដកចេញដោយខ្លួនឯងទេ គឺដោយសារមេដឹកនាំខ្មែរជំទាស់ ពីព្រោះពួកគេនោះត្រូវការការពារក្រុងសៃហ្គន ហើយខ្មែរក្រហមគេយល់ថាគេអាចគ្រប់គ្រងខ្លួនឯងបាន ចាត់ចែងខ្លួនឯងបាន"។ តើនេះជាការសង្ខេបត្រឹមត្រូវអំពីអ្វីដែលហេតុការណ៍កើតឡើងនៅហ្នឹងទេ ដែលថាអំពីការវិវត្តរបស់កងទ័ពខ្មែរក្រហម ការដកថយរបស់ទ័ពវៀតណាម ហើយនិងក្រោយមកវាការប៉ះទង្គិចដូចម្តេច? ថាតើបក្សកុម្មុយនីស្តកម្ពុជា ជាអ្នកបង្ខំឲ្យគេដកខ្លួនចេញ ឬដូចម្តេច?

[១១:២៦:០៤]

**ឆ៖** បាទ វាមានទិដ្ឋភាពពីរទាក់ទងទៅនឹងទំនាក់ទំនងនេះ។ មួយ ខាងបក្សកុម្មុយនីស្តកម្ពុជារីករាយដើម្បីឲ្យមានវៀតណាមនៅទីនោះ ដើម្បីជួយពួកគេនៅក្នុងការតស៊ូ ដើម្បីរំដោះប្រទេសកម្ពុជា។ ចំណុចមួយទៀត នេះជាចំណុចសំខាន់ បក្សកុម្មុយនីស្តកម្ពុជាក៏ចង់ទទួលបន្ទុកលើការតស៊ូដោយខ្លួនឯង។ ដូច្នេះអ្វីក៏ដោយដែលវៀតណាមបានធ្វើនោះ គឺបង្ហាញការចាប់អារម្មណ៍ឲ្យគេគិតថា វៀតណាមចង់ជាមេកើយរបស់ខ្មែរក្រហម។ នេះហើយខ្មែរក្រហមអត់ទទួលយកបានទេ។ នេះហើយគេចង់ឲ្យអ្វីស្ថិតក្នុងការត្រួតត្រារបស់ខ្លួនឯងនោះឯង។

**ស៖** នៅក្នុងផ្នែកមួយ លោកបាននិយាយយោងទៅរកកងទ័ពសីហនុនិយម ដែលហៅថា "ខ្មែររំដោះ"។ ខៀវ សំផន បាននិយាយអំពីទំនាក់ទំនងរវាងវៀតណាម ហើយនិងបក្សកុម្មុយនីស្តកម្ពុជា ហើយនិងតួនាទីរបស់កងទ័ពខ្មែររំដោះ។ មិនមានសរសេរនៅក្នុងសៀវភៅលោកទេ គឺឃើញនៅក្នុងសៀវភៅមួយបន្ទាប់ពីលោកបោះពុម្ពសៀវភៅ ហើយខ្ញុំនឹងជូនលោកនូវសេចក្តីដកស្រង់។

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមការអនុញ្ញាតពីលោកប្រធានផងដែរ។ លោកប្រធាននេះគឺជាសៀវភៅមួយដែលចៅក្រម

ខាតវ៉ាយថ៍ បានប្រើឃោងម្សិលមិញ គឺឆ្នាំ២០០៧។ យើងមានតែជំពូកទី៥ ជាភាសាអង់គ្លេសទេ។ ហើយនិងភាសាបារាំង និងភាសាខ្មែរ ហើយខ្ញុំសូមបញ្ជូនទៅឲ្យលោក ស្វ្យត ដើម្បីគាត់បានអាន។ សូមការអនុញ្ញាតពីតុលាការ ពីលោកប្រធាន ដើម្បីជូនឯកសារលើក្រដាស ដើម្បីគាត់បានពិនិត្យបាទ។

[១១:២៧:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនអ្នកជំនាញពិនិត្យ!

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនអ្នកជំនាញ)*

[១១:២៨:៤៣]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំសូមសួរថាតើលោកនៅចាំថាលោកធ្លាប់បានឃើញ បានទទួលឯកសារនេះទេពីមុនមក?

**លោក ហ្វីលីព ស្វ្យត៖**

**ឆ៖** ឥឡូវនេះ ខ្ញុំបានឯកសារនេះក្នុងដៃហើយ។

**ស៖** បាទ អរគុណ។ ខ្ញុំអានខ្លឹមសារសង្ខេប ខ្ញុំមានតែអត្ថបទអង់គ្លេស ERN តែប៉ុណ្ណោះ ខ្ញុំនឹងផ្ដល់អង់គ្លេសហ្នឹងគឺ 00498275, ទំព័រ៥៦ ដែលលោកមាន។ បារាំង 00643880 ខ្ញុំគិតថាយើងមានការជំទាស់ពីមេធាវី។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប លោកហ្វីលីព ស្វ្យត!

សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ អម្បាញ់មិញ ខ្ញុំស្ដាប់ចម្លើយរបស់អ្នកជំនាញលោក ហ្វីលីព ស្វ្យត ហើយនិងតំណាងសហព្រះរាជអាជ្ញា ហាក់ដូចជាមិនត្រូវនឹងសំណួរ។ លោកសហព្រះរាជអាជ្ញាសួរថាតើលោកបានស្គាល់ឯកសារនេះពីមុនមកទេ? ប៉ុន្តែលោក ហ្វីលីព ស្វ្យត ឆ្លើយថាលោកបានទទួលហើយឥឡូវនៅដៃ។ ដូច្នេះវាអត់ត្រូវនឹងសំណួរពីមុនរបស់តំណាងសហព្រះរាជអាជ្ញា។ សូមឲ្យលោក

ជួយបញ្ជាក់ បាទ សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំមិនទាន់យល់ច្បាស់ពីមតិរបស់លោកមេធាវីការពារទេ។ គឺថាខ្ញុំសូមអនុញ្ញាតពីតុលាការដើម្បីជូន ហើយគឺខ្ញុំបានបញ្ជូនឯកសារនេះទៅភាគីយូរហើយ ១ខែ ២ខែហើយ ហើយខ្ញុំបានឃើញឯកសារនេះនៅក្នុងសំណុំរឿង គឺថា E127/24/7 គឺជាសេចក្ដីណែនាំរបស់អង្គជំនុំជម្រះទៅលោក ហ្វីលីព ស្សត នៅក្នុងខែកញ្ញា ឆ្នាំ២០១២។ ដូច្នេះហើយយើងច្បាស់ហើយ គាត់មានឯកសារនេះពីមុនហើយ គាត់ធ្លាប់បានឃើញហើយ។ បាទ ដូច្នេះសូមលោកប្រធានមេត្តាសម្រេច។

[១១:៣១:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អនុញ្ញាត សូមអញ្ជើញ!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមអរគុណ។ ខ្លឹមសារសំខាន់ដែលខ្ញុំសូមអានជូនលោកនៅពេលនេះ, ចំពោះ ហ្វីលីព ស្សត គាត់បានបង្ហាញភស្តុតាងយ៉ាងច្បាស់ហើយ ដែលថាតាមពិតគឺវៀតណាម ដែលបង្កើតទ័ពខ្មែររំដោះ គឺខ្មែរទ័ពរំដោះនោះ គឺគាត់បានសរសេរដូចខាងក្រោមនេះ "តាមទ្រឹស្ដីគាត់ សម្ដេចសីហនុ ដឹកនាំខ្មែររំដោះដែលខុសពីខ្មែរក្រហម ដែលថាជាស្លៀកពាក់ជាឯកសណ្ឋានរបស់សម្ដេចសីហនុ ប៉ុន្តែខ្មែរ -- វៀតណាមជាអ្នកបង្កើត ប៉ុន្តែគេឃើញខ្សែបញ្ជាតាំងពីលើដល់ក្រោមពីប៉េកាំង។ កងទ័ព សីហនុ ទទួលបញ្ជាពីហាណូយទៅវិញ។ ប៉ុន្តែ ហ្វីលីព ស្សត និយាយថា ច្បាស់ថា ការដឹកនាំរបស់វៀតណាម គឺថាអាចចូលយ៉ាងជ្រៅដល់កិច្ចការផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា ចាប់តាំងពីឆ្នាំ១៩៧៣ គឺចាប់ពីហ្នឹងទៅ គេដកខ្លួនចេញមួយចំនួនហើយអំពីការត្រួតត្រានេះ"។ អ៊ីចឹងសួរទៅលោកជំនាញ ហ្វីលីព ស្សត ថាតើ -- ហើយថា វៀតណាមបានចូលលូកដៃយ៉ាងជ្រៅទៅក្នុងកិច្ចការផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជានេះយ៉ាងជ្រៅ។ តើលោកប្រកាន់ចម្លើយនេះដដែលដែរឬទេ?

[១១:៣២:៤៨]

**លោក ហ្វីលីព ស្សត៖**

**ឆ៖** ខ្ញុំសូមថាមិនយល់ស្របទៅនឹងការបញ្ជាក់របស់សហព្រះរាជអាជ្ញានេះទេ។ ខ្ញុំគិតថា លោកដូចជានិយាយពាក់ធ្ងន់ជាងអ្វីដែលខ្ញុំចង់និយាយទៅទៀត។ ហើយវៀតណាម គឺថាមានការចាប់អារម្មណ៍

ក្នុងការងាររបស់បក្សកុម្មុយនីស្តកម្ពុជា គឺពិតហើយ។ បើយើងនិយាយថា វៀតណាមទទួលខុសត្រូវធំទៅលើការបំពាក់អាវុធ ហ្វឹកហ្វឺនទាហានខ្មែររំដោះហ្នឹង គឺថាអាហ្នឹងមិនអាចប្រែកបានទេ។ ប៉ុន្តែហេតុការណ៍ដែលថាគេបណ្តុះបណ្តាល ហើយនិងបំពាក់អាវុធ មិនមែនជាភស្តុតាងដែលការលូកដៃជ្រៅទៅក្នុងកិច្ចការរបស់បក្សកុម្មុយនីស្តកម្ពុជាទេ។

[១១:៣៣:៣៨]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំតាមការណែនាំសៀវភៅរបស់លោកហ្នឹងទំព័រ២៤០។ ឥឡូវនេះលោកនិយាយអំពីទំនាក់ទំនងជាមួយសម្តេច សីហនុ ដែលគង់នៅប៉េកាំង ដូចដែលលោកនិយាយម្សិលមិញនេះ។ ERN អង់គ្លេស 00396440 ហើយបារាំង ERN 003964 -- ខ្ញុំអានម្តងទៀង បារាំង 00639765។ បាទ ទំព័រ២៤០ នៅក្នុងសៀវភៅ។ ខ្ញុំនឹងអានអំពីខ្លឹមសារសង្ខេបខ្លីទេ។ គឺថាផ្នែកក្នុងសារហ្នឹងគឺថា បក្សកុម្មុយនីស្តកម្ពុជាហៅថា គេត្រូវបានបញ្ជូនក្នុងនាមលោក ខៀវ សំផន គឺជាមេ -- អគ្គមេបញ្ជាការប្រដាប់អាវុធរបស់ -- ហើយបញ្ជូនពីក្រសួងការបរទេសចិន ជាលិខិតបញ្ជូនមកនោះ។ គាត់និយាយជាសម្ងាត់ពីដើមថា រណសិរ្សរួបរួមជាតិហ្នឹង ត្រូវបានបង្កើតដែលថា ខ្មែរក្រហមត្រូវការគាត់បានប្រាប់ញ៉ូវយ៉កថែមស៍ថា ដូចជាព្រះអង្គនិយាយថា “ខ្មែរក្រហមគេត្រូវការខ្ញុំតែពេលនេះទេ តែពេលដែលលែងត្រូវការគេនឹងខ្ជាក់ខ្ញុំចោល ដូចជាខ្ជាក់គ្រាប់ផ្លែឈើបន្ទាប់ពីហូបរួចដូច្នោះដែរ”។ តើបែបនេះ ថាតើនេះជាសម្តេច សីហនុ ទ្រង់បានឆ្វេងយល់មុនថា ឃើញថាពេលណាមួយការរួបរួមទ័ពនេះ គេលែងត្រូវការ គេនឹងធាក់ចោល។ តើលោកអាចពន្យល់ដូចម្តេចបានក្នុងខ្លឹមសារនេះ?

[១១:៣៥:៣៣]

**ឆ៖** ព្រះអង្គគឺយល់ ឆ្វេងយល់ហើយ គាត់ដឹងថាព្រះអង្គដឹងថា គឺថាប្រតិបត្តិការមកពីប៉េកាំងនោះ គឺថាជាមុខសាធារណៈជារបាំងមុខទេ គឺតាមពិត ព្រះអង្គគឺថាមិនមានការត្រួតត្រាអ្វីលើអ្វីដែលកើតឡើងនៅកម្ពុជាទេ។ ហ្នឹងគឺជាអ៊ីចឹងមែន។

**ស៖** ទំព័រ២៤២: លោកពន្យល់បន្ថែមលើបញ្ហានេះដល់ចំណុចមួយទាក់ទងទៅអ្វីដែលលោកដឹងអំពីប្រជាប្រិយភាពរបស់ព្រះអង្គក្នុងពេលនោះ។ ERN អង់គ្លេសគឺ 00396442, បារាំង ERN 00639768។ លោកបាននិយាយដូចតទៅនេះ “ខ្មែរក្រហមបានដឹងអំពីប្រជាប្រិយភាពរបស់សម្តេចគឺថាទ័ពរបស់គេមិនពាក់សញ្ញារបស់ព្រះអង្គទេ ហើយបក្សកុម្មុយនីស្តកម្ពុជាគេបានបញ្ជាក់នៅក្នុងការប្រជុំនៅក្នុងបក្ស នៅខាងក្រោយទ្វារនោះគឺ អ្នកទាំងនោះត្រូវបានគេថ្កោលទោសថាជាសក្តិភូមិ។ ដូច្នេះ

ហើយគេមិនបង្ហាញឲ្យមហាជនដឹងទេ។ ហើយអាចនឹងឲ្យដឹងតែក្នុងជួរបក្សតែប៉ុណ្ណោះ។ នេះគឺបក្សគេសម្រេចបែបនេះ តើលោកអាចពន្យល់បានម៉េចពីហេតុការណ៍នេះ ដែលថាគេមិនឲ្យមហាជនស្គាល់បក្ស ស្គាល់ក្រុមទ័ពដែលមកពីសម្ដេច -- ខ្មែររំដោះនោះទេ?

[១១:៣៧:០៥]

**ឆ៖** ជាថ្មីម្ដងទៀត ខ្មែរក្រហម ប៉ុល ពត ហើយថ្នាក់ដឹកនាំ គឺគេអាចធ្វើឲ្យតុល្យភាពរឿងពីរ។ មួយ គឺគេចង់ឲ្យសម្ដេចសីហនុ ព្រះអង្គនៅសព្វព្រះទ័យ សប្បាយរីករាយ កុំគិតថាឲ្យព្រះអង្គឆ្វេងយល់អនាគតរបស់ព្រះអង្គ គឺថាទោះជាលំបាកយ៉ាងណាក្ដី មិនពេញយ៉ាងណាក៏ដោយ ទំនាក់ទំនងរវាងព្រះអង្គនិងអនាគត ទៅអនាគតទៅនឹងត្រូវដឹកនាំដោយខ្មែរក្រហម។ ពួកគេចង់ឲ្យព្រះអង្គនៅជាមួយ។ ម្យ៉ាងទៀត ហើយសម្ដេច សីហនុ គឺទ្រង់មានប្រជាប្រិយភាពក្នុងចំណោមប្រជារាស្ត្រ ប្រជាជនខ្មែរខ្លាំងណាស់។ នេះហើយជាមូលហេតុមួយដែលខ្មែរក្រហមទទួលយកទ័ពដែលព្រះអង្គជ្រើសរើសនោះ ជ្រើសតាំង ពីព្រោះសម្ដេច សីហនុ ហ្នឹង ពលរដ្ឋគេយល់ថាជាសម្ព័ន្ធភាពជាមួយខ្មែរក្រហម។ នៅពេលដែលព្រះអង្គយាងត្រឡប់មកវិញ គឺគេផ្សាយទូលំទូលាយ។ ក៏ប៉ុន្តែហានិភ័យមួយដែលខ្មែរក្រហមមាននោះ គឺថាព្រះអង្គអាចនឹងយកអំណាចផ្ដាច់មុខ ខាងការគាំទ្រពីប្រជារាស្ត្រកម្ពុជា។ នោះហើយដែលឲ្យប្រជាជនគាំទ្រព្រះអង្គជាងខ្មែរក្រហម។ នេះហើយជាតុល្យភាពដែលគេគិតនោះ។

[១១:៣៨:៣៥]

**ស៖** សូមអរគុណ។ បាទ សូមចូលទៅអំពីនិយាយពីលក្ខណៈទូទៅនៅក្នុងសៀវភៅ លោកបានរៀបរាប់អំពីគោលនយោបាយនៅទំព័រ២៤៥ និងទំព័រខាងក្រោមបន្តបន្ទាប់រហូតដល់ទំព័រ២៤៨, ២៤៩។ លោកបានលើកឡើងពីម្សិលមិញឆ្លើយទៅនឹងសំណួរចៅក្រម ខាតវ៉ាយថ៍ និយាយអំពីមូលហេតុនៃសមូហភាវូបនីយកម្មនេះ។ ពីម្សិលមិញ យើងអត់ទាន់បានមើលចំណុចនេះនៅឡើយទេ។ ការវិវត្តនេះ គឺទំព័រ២៤៥ ដែលERN ខ្មែរ 00396446, បារាំង 00639772 ដល់ 73។ លោកនិយាយអំពី -- លោកតទៅ "សំខាន់បំផុតគឺថាវាផ្ដល់នូវស្ថានភាពមួយនៃការបញ្ច្រៀបគោលនយោបាយរបស់ខ្មែរក្រហមដែលវា -- ឥឡូវនេះគឺថាមើលទៅហាក់បីដូចជាលេចឡើងយ៉ាងឆាប់រហ័ស។ លទ្ធផលគឺថាការឈឺចាប់របស់ប្រជាជន គឺថាមានសារៈសំខាន់ណាស់"។ ហើយបន្ទាប់មកលោកនិយាយអំពីការដុតផ្ទះសម្បែងប្រជាជនតាំងពីម្សិលមិញម្ល៉េះ។ ខ្ញុំសូមសួរទៅលោកថា ការធ្វើឲ្យៗភាគីម្ខាងចុះទន់ខ្សោយ ដែលថាកើតចេញឡើងដោយសារតែការទម្លាក់គ្រាប់បែក។ សូមលោករៀបរាប់បន្តិចបានទេ?

[១១:៤០:៣៣]

**ឆ៖** ខ្ញុំថាវាច្បាស់ហើយ សេចក្ដីណែនាំត្រូវបានកំណត់ឡើងហើយ។ ផលប៉ះពាល់នៃការទម្លាក់គ្រាប់បែកនេះ គឺថាវាសំខាន់ណាស់ វៀតណាម សក្រូស ក៏បាននិយាយអំពីការទម្លាក់គ្រាប់បែកនៅតាមបណ្ដាភូមិនីមួយៗខេ្មចខ្ទីអស់។ នេះនិយាយអំពីធ្វើឲ្យមានការខឹងសម្បា។ អ៊ីចឹងហើយបានវាមានដូចជាសង្គ្រាមកូរ៉េ ក៏មានការឈានទៅមុខយ៉ាងលឿន ក៏ដូចជានៅចិនយ៉ាងដូច្នេះដែរ។

**ស៖** ខ្ញុំសូមផ្ដល់ ERN សៀវភៅ ខៀវ សំផន ដែលគឺសារនោះគឺនៅត្រង់ ERN 00380449 នេះ ERN ជាភាសាខ្មែរ។ ខ្ញុំសូមបន្តទៅទំព័រ២៤៨ គឺថាពីរទំព័រកន្លះបន្ទាប់ពីហ្នឹងលោកនិយាយដូចតទៅនេះ សូមដកស្រង់ "នៅក្នុងខួរក្បាលរបស់ ប៉ុល ពត ហ្នឹងគឺការបង្ហូរឈាមនេះ គឺជាចាំបាច់ គឺថាគាត់បង្ហាញអំពីភាពទន់ខ្សោយរបស់ខ្មាំងដែលត្រូវតែបង្ក្រាបខ្មាំងឲ្យទន់ខ្សោយ។ ខ្មែរក្រហម មេដឹកនាំខ្មែរក្រហមដទៃទៀតក៏មានការគិតឃើញដូចគ្នាដែរ។ សេចក្ដីនាំរបស់បក្សកុម្មុយនីស្ដកម្ពុជា គឺធ្វើឲ្យជួយបក្សនិយាយអំពីការតស៊ូដ៏ក្ដៅគគុកនេះ"។ ខ្ញុំសូមឲ្យលោកផ្ដល់គំនិតយោបល់អំពីរៀបរាប់នេះឲ្យបានទូលំទូលាយទាក់ទងទៅនឹងគោលនយោបាយ។ នេះបើខ្ញុំយល់មិនច្រឡំទេ គឺថាលោកបាននិយាយថាមានការដាក់បញ្ជូននូវមេដឹកនាំមួយក្រុមធំនោះ។

[១១:៤២:៤១]

**ឆ៖** មិនមែនតែមេដឹកនាំមួយក្រុមធំតែប៉ុណ្ណោះទេ ប៉ុន្តែក៏វាគឺថាមានការបញ្ចូលតាមឋានៈនៃសមាជិកបក្សទៅជួរក្រោមៗដែរ។ គឺថាត្រូវតែធ្វើឲ្យវាមានភាពច្បាស់លាស់ ក៏ប៉ុន្តែបក្សកុម្មុយនីស្ដកម្ពុជាគឺថាគឺៗនិយាយពាក់ព័ន្ធទៅនឹងបញ្ហាសម្ភារៈ ការលើកឡើងអំពីការត្រឹមតែចែករំលែកនូវការឈឺចាប់ការបរិច្ចាគ ការពលិការផ្សេងៗ។ គឺថាយើងត្រូវតែធ្វើពលិការផ្សេងៗដើម្បីបុព្វហេតុនេះ។ នេះគឺជាចំណុចគន្លឹះដែលពាក់ព័ន្ធទៅនឹងឥរិយាបថរបស់លោក ខៀវ សំផន ហើយ។

**ស៖** សូមអរគុណលោកសាក្សីជំនាញ។ ហើយតាមដែលខ្ញុំយល់ គឺថាលោកបានរៀបរាប់បន្តទៅទៀត ដែលនិយាយអំពីការប្រព្រឹត្តមកលើខ្មាំង ជាពិសេសអ្នកនៅខាងក្រៅជួរបក្ស នៅទំព័រ២៤៩ នៃសៀវភៅរបស់លោក។ ERN ជាភាសាអង់គ្លេស 00396449, បារាំង 00639776 ដល់ 777។ លោកនិយាយអំពីការសម្លាប់រង្គាលនៅក្នុងពេលសង្គ្រាមនោះ គឺកម្លាំងរបស់កងទ័ព លន់ នល់។ សូមដកស្រង់ "គឺថាកម្លាំងបក្សកុម្មុយនីស្ដកម្ពុជាមានអ្នក *(ឮមិនច្បាស់)* ប្រសើរឡើង គឺថាគេបានសម្លាប់អ្នកទោសពីរនាក់ ហើយខាងកុម្មុយនីស្ដវិញ គឺថាតែក្រោយឆ្នាំ១៩៧៣ ទេដែលថាការសម្លាប់បែបហ្នឹងគឺថាត្រូវ

បានសម្លាប់ជាប្រព័ន្ធតែម្តង។ កងទ័ពខ្មែរក្រហមនៅតាមមូលដ្ឋាន គឺថាក៏មានអារម្មណ៍បែបនេះដែរ។ គ្មានអ្នកណាអាចរត់គេចខ្លួនបានទេ។ បើថារត់គេចខ្លួន គឺថាត្រូវតែសម្លាប់ដែរហើយ"។ សូមឲ្យលោកពន្យល់ឲ្យបានទូលាយបន្តិចទេ និយាយអំពីការកាប់សម្លាប់ គឺថាពី៧៣ ទៅកាន់តែក្លាយទៅជាការកាប់សម្លាប់ជាប្រព័ន្ធនោះ?

[១១:៤៥:០៩]

**ឆ៖** វាមិនមែនគ្រាន់តែជាគំនិតយោបល់តែប៉ុណ្ណោះទេ អ្វីដែលខ្ញុំបានទទួលពីកម្មាភិបាលថ្នាក់ទាបៗនៅក្នុងជួរខ្មែរក្រហម និងអង្គាល់នោះ គឺថាពីដើមឡើយ មានអ្នកខ្លះរត់មកភូមិវិញ អត់បញ្ហាអីទេ។ ប៉ុន្តែក្រោយឆ្នាំ១៩៧៣នេះ គឺមានការប្រព្រឹត្តខុសៗគ្នា។ នេះយើងនិយាយអំពីការពិតតែម្តង មានការរឹតបន្តឹងវិន័យនៅក្នុងជួរបក្ស ជួរកងទ័ព គឺថាប្រព័ន្ធរបស់ខ្មែរក្រហមនេះទាំងមូលតែម្តង។ គឺថាត្រូវយល់ថាពេលណាដែលខ្លួនត្រូវបន្តដំណើរទៅដំណាក់កាលបន្ទាប់ទៀត រហូតដល់ឈានទទួលបានជ័យជម្នះ ហើយក៏ដូចជាបញ្ហាវៀតណាម។ ទាំងអស់នេះត្រូវរួមបញ្ចូលគ្នា។

**ស៖** សូមអរគុណ។ ហើយក្រោមនៃទំព័រនេះផងដែរ លោកបាននិយាយអំពីការវាយសម្រុកដោយកងទ័ពខ្មែរក្រហម។ នេះគឺជាខ្លឹមសារពាក់ព័ន្ធទៅនឹងអ្នក -- ខ្មែរដែលត្រឡប់មកពីហាណូយ។ សូមដកស្រង់ "ប៉ុល ពត បានដាក់បញ្ហាថា ខ្មែរត្រឡប់មកពីហាណូយដែលបានអះអាងអំពីការ -- ពីភាពស្មោះត្រង់របស់ខ្លួន ទៅដាក់ទៅមណ្ឌលអប់រំកែប្រែនៅឆ្លូង នៅមាត់ច្រាំងខាងលិច។ ខុសពីអ្នក -- ហើយនៅវគ្គបណ្តុះបណ្តាលនយោបាយកម្មាភិបាល គឺថាទី១ហើយដែលអាចនិយាយថា -- គឺស្តាប់ឮពាក្យថា ក្បាលយួន ខ្លួនខ្មែរ នោះ។ អ្នកដែលមានក្បាលយួនខ្លួនខ្មែរនេះ គឺត្រូវបានសម្លាប់ចោល"។ សូមលោកពន្យល់ឲ្យបានលម្អិតបន្តិច ថាតើអ្នកដែលត្រឡប់មកពីហាណូយមកហ្នឹងជាអ្នកណា? តើលោកអាចធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងអ្នកដែលត្រឡប់មកពីហាណូយនេះបានទេ?

[១១:៤៧:២២]

**ឆ៖** អ្នកដែលត្រឡប់មកពីហាណូយ គឺអ្នកដែលចូលរួមជាមួយខ្មែរវៀតមិញ សង្គ្រាមប្រឆាំងជាមួយនឹងបារាំង តាំងពីទសវត្សរ៍ឆ្នាំ១៩៥០ម្ល៉េះ។ ហើយនៅឆ្នាំ១៩៥៤ ដោយគឺថា ដោយមិនស្នាក់នៅកម្ពុជា ពួកគេបញ្ជូនទៅវៀតណាមខាងជើង គេដាក់នៅជំរំអប់រំកែប្រែ មានចំនួនដល់រាល់ពាន់ឯណោះ។ ហើយអ្នកទាំងនោះរស់នៅប្រទេសវៀតណាមរហូត ដល់ដើមទសវត្សរ៍១៩៧០ នៅពេលគេត្រឡប់មកវិញ។ អ្នកទាំងនោះជាច្រើនបានការប្រពន្ធជាវៀតណាម។ ហើយគេយល់ឃើញថាអ្នកទាំងនោះមាន

ភាពមេត្តាអនុគ្រោះចំពោះ យោគយល់ចំពោះវៀតណាម។ ដូច្នេះ គេគិតអំពីថាទំនាក់ទំនងរវាងវៀត-ណាម និងបក្សកុម្មុយនីស្តកម្ពុជាវាតឹងតែងឡើង។ ដូច្នេះ បក្សកុម្មុយនីស្តកម្ពុជា កងទ័ពរបស់ខ្លួនកាន់តែខ្លាំងឡើងៗ មានការសង្ស័យទៅលើអ្នកវិលត្រឡប់ពីហាណូយហ្នឹងវិញ ហើយអ្នកទាំងនោះស្ថិតនៅក្នុងជំរំកែប្រែ។ ដូច្នេះ ជាច្រើនត្រូវបានគេសម្លាប់។

**ស៖** តើខ្ញុំយល់បានត្រឹមត្រូវទេ អំពីគោលនយោបាយដែលយើងបាននិយាយពីខាងដើមនោះ ទាំងនៅក្នុងជួរបក្ស ទាំងនៅក្រៅជួរបក្ស។ បើសិនណាជាខ្ញុំយល់បញ្ហានេះមិនត្រឹមត្រូវទេ សូមកែតម្រូវ។ សូមអរគុណ។

[១១:៤៨:៥២]

**ឆ៖** បាទ លោកតំណាងសហព្រះរាជអាជ្ញាត្រឹមត្រូវហើយ។ ជាផ្នែកមួយនៃការរឹងបន្តឹងការត្រួតត្រា ដោយសារតែវាកៀកនឹងពេលឈានទៅទទួលជ័យជម្នះហើយ។

**ស៖** ហើយបន្ទាប់មកលោកពិភាក្សាអំឡុងពេលចាប់ពីចុងឆ្នាំ១៩៧៣ ដែលមានការបង្កើតទីបញ្ជាការដែល សុន សេន នៅវ៉ាស្នាច់ នៅ -- លោកបានរៀបរាប់អំពីការបង្កើតមន្ទីរសន្តិសុខនៅចន្លោះអំឡុងពេលហ្នឹង គឺនៅក្នុងភូមិភាគពិសេសតែម្តង។ ហើយពីម្សិលមិញនេះផងដែរ គឺថាលោកបានរៀបរាប់អំពីការសម្ភាសរបស់លោកជាមួយនឹងបុគ្គលម្នាក់ដែលត្រូវខ្មែរក្រហមចាប់ខ្លួន ហើយគាត់ស្លាប់បាត់ហើយ គាត់ត្រូវបានគេសម្លាប់បាត់ហើយ។ តើការបង្កើតមន្ទីរសន្តិសុខគុក -- តើវាឆ្លុះបញ្ចាំងអំពីការបង្កើត ការអនុវត្តគោលនយោបាយនេះជាប្រព័ន្ធដែរឬក៏យ៉ាងណា?

**ឆ៖** សញ្ញាណដំបូងបំផុតនៃការគ្រប់គ្រងចាត់ចែងរដ្ឋបាលនេះគឺ មន្ទីរកងទ័ពដែល ដួន ជឿន បានបង្កើតនៅជិតនោះៗ នេះគឺជាពេលចាប់ផ្តើមនៃការបង្កើតរដ្ឋបាលគ្រប់គ្រងនេះឯង។

**ស៖** នៅត្រង់ចំណុចនេះផងដែរ ខ្ញុំចង់បង្ហាញឯកសារមួយទៅលោក គឺចុះខែកក្កដា ១៩៧៣ គឺទង់បដិវត្តលេខចេញខែកក្កដា ៧៣ គឺបោះពុម្ពផ្សាយនៅភូមិភាគបូព៌ានៅខែមិថុនា ៧៤។ ខ្ញុំសូមសួរទៅលោក ថាតើលោកមានបានមើលទស្សនាវដ្តីទង់បដិវត្តនេះទេ?

**ឆ៖** ខ្ញុំអានឯកសារទាំងអស់ដែលលោកជូនមកខ្ញុំ រួមទាំងឯកសារទង់បដិវត្តនេះផងដែរ។

[១១:៥១:២២]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតដកស្រង់ បង្ហាញជូនអ្នកជំនាញ មិនមែនជាឯកសារដែលយើង

ខ្ញុំបានផ្ញើជូនគាត់នោះទេ តាមដែលខ្ញុំយល់ គឺជាឯកសារយោងការស្រាវជ្រាវរបស់គាត់ គឺកិច្ចសម្ភាសន៍របស់គាត់ជាមួយអ្នកណាម្នាក់នោះ។ ដូច្នេះខ្ញុំចង់សួរថា តើគាត់នឹងបានឃើញធ្លាប់បានឃើញឯកសារនេះ ខ្ញុំនឹងធ្វើតាមនីតិវិធី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនអ្នកជំនាញពិនិត្យ!

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនអ្នកជំនាញ)*

[១១:៥២:០៧]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** នេះគឺជាឯកសារដែលបានបកប្រែដោយតុលាការ។ មិនបាច់មើលអំពីទម្រង់របស់ឯកសារនេះគឺជាទង់បដិវត្តចុះខែកក្កដា ៧៣ ត្រូវបានបោះពុម្ពផ្សាយនៅភូមិភាគបូព៌ានៅខែមិថុនា ៧៤។ តើលោកធ្លាប់ឃើញឯកសារនេះទេ?

**លោក ហ្វីលីព ស្បូត៖**

**ឆ៖** ខ្ញុំគិតថា ខ្ញុំបានឃើញឯកសារនេះ ខ្ញុំជឿជាក់ថាខ្ញុំបានអានឯកសារទាំងអស់ គឺទង់បដិវត្តទាំងអស់។ ប្រហែល១២ឆ្នាំ ២០ឆ្នាំក្រោយពីព្រឹត្តិការណ៍ ខ្ញុំមិនអាចចាំវាច្បាស់ ប៉ុន្តែខ្ញុំជឿជាក់ថា ខ្ញុំអានខ្ញុំមានឯកសារនេះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន សូមការអនុញ្ញាតដើម្បីអានសម្រង់ខ្លីជូនអ្នកជំនាញ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** នេះឯកសារនេះគឺ E3/785 មានចំណងជើងថា "ការពង្រឹង និងការធ្វើឲ្យជំហរថ្នាក់ដឹកនាំកាន់តែប្រសើរឡើង"។ ខ្ញុំក៏សូមការអនុញ្ញាតដើម្បីដាក់បញ្ចាំងលើអេក្រង់កុំព្យូទ័រផងដែរ ដើម្បីឲ្យសាធារណជនបានជ្រាបផង។ នេះគឺជាឯកសារមួយ យើងបាននិយាយអំពីប្រវត្តិនៃរឿងរ៉ាវនៃការកាប់

សម្លាប់។ អ៊ីចឹងបានខ្ញុំបង្ហាញឯកសារហ្នឹង។ នៅផ្នែកខាងក្រោមនៃទំព័រទី២ លោក ហ្វីលីព ស្បត, ERN ជាភាសាខ្មែរនោះ 00442047 ដល់ 48, បារាំង 00741968, អង់គ្លេស 0071399 (*ស៊ីក*)។

[១១:៥៤:៥០]

បាទ ខ្ញុំសូមអាន សូមដកស្រង់៖ "នៅពេលជាមួយគ្នានោះដែរគឺ យើងត្រូវតែចូលរួមពង្រឹងភាពដឹកនាំដើម្បីធ្វើឱ្យប្រជាជនពេញចិត្ត ស្រឡាញ់ដល់យើងទាំងអស់គ្នា"។ ហើយខាងក្រោមនេះបន្តិច "ហើយពេលខ្លះវាជាជំហរមួយត្រឹមត្រូវហើយ ប៉ុន្តែដោយសារតែមិនមានការប្រុងប្រយ័ត្ន វាធ្វើឱ្យមានគុណវិបត្តិខាងផ្នែកនយោបាយ។ ឧទាហរណ៍ បើសិនណាជាគិញត្រូវបានចាប់ខ្លួនហើយសម្លាប់នៅក្នុងកិច្ចប្រជុំ ចំពោះមុខប្រជាជន ប្រជាជនខ្លះគាត់ខ្លាច គេគិតឃើញថា ពួកនេះគឺថាកាចសាហាវឃោរឃៅណាស់។ ជំហរនៃការកាប់សម្លាប់នេះត្រឹមត្រូវហើយ ប៉ុន្តែការសម្លាប់នៅមុខមហាជនអ៊ីចឹង គឺថាវាមិនល្អទេ។ ដូច្នេះវាហាក់បីដូចជាសេចក្តីណែនាំមួយដែលថា តើការកាប់សម្លាប់ត្រូវធ្វើដោយរបៀបណានោះ? តើលោកយល់ឃើញយ៉ាងម៉េចដែរចំពោះការវិវត្តនៃការកាប់សម្លាប់ជាប្រព័ន្ធ ឬក៏និយាយអំពីឥរិយាបថនៃការចាប់ខ្មាំង រួចហើយសម្លាប់បែបនេះនោះ?

[១១:៥៦:០១]

**ឆ៖** ខ្ញុំឆ្លើយសំណួររបស់លោក។ គឺថាគេដោះស្រាយទៅតាមពេលវេលាផ្សេងៗគ្នា។ ថាតើការសម្លាប់ ការប្រហារជីវិតត្រូវធ្វើរបៀបម៉េច? អ្នកណាមានសិទ្ធិអំណាចក្នុងការអនុញ្ញាតឱ្យមានការប្រហារជីវិតបែបនេះ។ គឺថាវាតែងតែមានការរំលោភបំពានហើយ ប៉ុន្តែគោលការណ៍ណែនាំខាងក្រោយការកាប់សម្លាប់នេះ គឺសម្លាប់អ្នកទាំងនោះជាការត្រឹមត្រូវហើយ នៅពេលណាគេប្រឆាំងជាមួយបដិវត្តន៍ ជំទាស់បដិវត្តន៍។ ប៉ុន្តែការកាប់សម្លាប់នេះ គឺកាប់សម្លាប់ក្នុងមធ្យោបាយមួយដែលមិនត្រូវឱ្យធ្វើឱ្យប៉ះពាល់ទៅដល់គោលបំណងរបស់បដិវត្តន៍ទេ។ មិនត្រូវសម្លាប់មនុស្សនៅចំពោះមុខដទៃទៀតនោះទេ។ នេះគេធ្វើជាទូទៅក្នុងអំឡុងនៃខ្មែរក្រហម មនុស្សត្រូវបានគេនាំខ្លួន បាត់ខ្លួន អត់ដែលឃើញមកវិញ។ គេ -- អ៊ីចឹងមានន័យថា គឺគេគោរពតាមថា មិនត្រូវសម្លាប់នឹងមុខមនុស្សនោះទេ។

[១១:៥៧:០០]

**ស៖** បាទ យើងនឹងបន្តទៅព្រឹត្តិការណ៍ឆ្នាំ១៩៧៥ ខ្លីទេ។ ប៉ុន្តែខ្ញុំបន្តព្រឹត្តិការណ៍ដែលកំពុងនិយាយនេះបន្តិចទៀត នៅទំព័រ២៥៤ លោកបាននិយាយអំពីអ្នកដែលរស់នៅក្នុងទីក្រុង។ នេះខ្ញុំចង់ គឺថាបន្តឱ្យលោកបង្ហាញភស្តុតាង ERN ជាភាសាអង់គ្លេស 0039454 (*ស៊ីក*), បារាំង 00639783 ដល់

84។ សូមដកស្រង់ "អ្នកដែលជាជនបដិវត្តន៍នោះ គឺថាត្រូវប្រព្រឹត្តឲ្យគេបានត្រឹមត្រូវគឺថា អ្នកទាំងនោះត្រូវតែមានឥរិយាបថចូលរួមជាមួយបដិវត្តន៍ រួមទាំងកសិករ កម្មករ ដែលរស់នៅក្នុងទីក្រុង។ ពួកគេបានជ្រើសរើសដើម្បីគេចចេញពីការទម្លាក់គ្រាប់បែក ដើម្បីសុវត្ថិភាព។ ហេតុដូច្នេះហើយគេមានការអាណិតអាសូរទោះបីការដាក់ទណ្ឌកម្មយ៉ាងម៉េចក៏ដោយ ត្រូវតែដាក់ពីខាងលើមកដល់ក្រោម។

នៅចុងឆ្នាំ៧៣ មានការទម្លាក់គ្រាប់បែក១៧០គ្រាប់ មានការរងរបួសរាប់រយរាប់ពាន់នាក់ ហើយនេះគឺថាចាប់បានការបាញ់គ្រាប់១០៥ ជាច្រើនរយគ្រាប់នោះ។ តើខ្ញុំយល់ត្រឹមត្រូវទេដែលថា លោកធ្វើការភ្ជាប់គ្នារវាងអ្នករស់នៅក្នុងទីក្រុងភ្នំពេញ ហើយនិងអ្នកដែលជ្រើសរើសនៅតាមទីជនបទនោះហើយក៏ដូចជាការវាយប្រហារទីក្រុងភ្នំពេញនោះ?

[១១:៥៩:00]

**ឆ៖** ការបាញ់ផ្លោងនេះ គឺជាសង្គ្រាមចិត្តសាស្ត្រ ដើម្បីបង្ហាញទាហាន លន់ នល់ ថាពួកគេមិនមានលទ្ធភាពតទល់បាននោះ។ ប៉ុន្តែការពិតនោះ គឺការបាញ់ផ្លោងនេះមានការរើសអើង។ ហេតុដូច្នេះបើនិយាយអំពីការបាញ់ផ្លោងកាំភ្លើងធំ គឺត្រូវបានប៉ះពាល់ទៅដល់អ្នកក្រីក្រនៅជាយក្រុង គឺអាចទទួល *(ឮមិនច្បាស់)* ដោយសារអ្នកទាំងអស់នោះជ្រើសរើសរស់នៅជាមួយ លន់ នល់ ជាជាងជ្រើសរើសនៅជាមួយបដិវត្តន៍ទៅវិញ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ គឺអ្វីដែលលោកទើបបានលើកឡើងគឺថា មិនមានចេតនាដើម្បីជៀសវាងកុំឲ្យមានការរងរបួសចំពោះប្រជាជនរស់ទីក្រុងទេ គឺគ្មានការគិតគូរបែបនេះទេ?

**ឆ៖** មិនមានទេ មិនមាន។ ប៉ុន្តែវាជាសង្គ្រាមៗ កាលណាសង្គ្រាមវាមានប្រជាជនស្លាប់ហើយ។ ខ្ញុំមិននិយាយថា គឺថាត្រូវតែទុកជីវិតប្រជាជនស៊ីវិល ប៉ុន្តែក្នុងពេលមានសង្គ្រាមអ៊ីចឹង គឺថាអាចនឹងមិនមានការជៀសផុតទេ។

[១២:00:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណអ្នកជំនាញ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី

និងអ្នកជំនាញ ដល់អ្នកជំណាញរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅរសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ចូលមករួមសវនាការនេះ នៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម តំណាងភាគីទាំងអស់ ហើយលោកសាក្សីជំនាញលោក ស្បូត។

**សួរដោយលោក អាប់ឌុលឡាក់ ចារីក៖**

**ស៖** ខ្ញុំនឹងសួរសំណួរពីរបីប្រធានបទទៀតល្ងាចនេះ។ ឥឡូវនេះ ខ្ញុំនឹងបន្តអំពីការណែនាំទូទៅ ហើយនិងអ្វីដែលលោកបានដឹងនៅក្នុងសៀវភៅរបស់លោក។ យើងបានពិនិត្យមើលបញ្ហាទស្សនៈថាពួកអ្នកក្រុងនៅពេលនោះ គឺថា ហើយនិងគេយល់ថាដូចម្ដេចខ្លាំង ហើយគេមានការផ្ដោងដាក់ទីក្រុងភ្នំពេញជាដើម។ បន្ទាប់ទៅទៀត ខ្ញុំនឹងពិភាក្សាផងដែរនៅក្នុងសៀវភៅរបស់លោក គឺថាពីម្សិលមិញបាននិយាយបន្តិចអំពីទំព័រ២៥២ ដែលលោកបានរៀបរាប់អំពីការជម្លៀសប្រជាជន ហើយនិងការដួលរលំទីក្រុងឧដុង្គនាកាលនោះ។ ហើយព្រឹត្តិការណ៍ដែលបានពិភាក្សាលម្អិតគួរសមដែរ ហើយខ្ញុំនឹងសួរចំណុចពិសេស

មួយដែលមិនទាន់ឆ្លើយ, នៅERN 00896455, បារាំង 00637734 ទៅដល់ 5។ ហើយសូមដកស្រង់ "ប្រជាជនទីក្រុងប្រហែលជា២០.០០០នាក់ត្រូវបានប្រមូលផ្តុំ ហើយនិងបណ្តើរទៅបាឡិល ហើយនិងទៅតំបន់មួយនៅក្បែរមូលដ្ឋានទ័ព គឺថាបង្កើតសហករណ៍នៅខាងភូមិភាគនិរតី។ មន្ត្រីដែលស្លៀកពាក់ឯកសណ្ឋានទាហានផងដែរ ត្រូវបានបំបែកចេញពីអ្នកដទៃទៀត ហើយយកទៅសម្លាប់ចោលនៅកន្លែងផ្សេង"។ ហើយខ្ញុំបានពិភាក្សាអំពីចំណុចនៅក្នុងទំព័រ២៥២ ដែលលោកចង្អុលបង្ហាញថា ប្រភពរបស់លោកហ្នឹងមានការសម្ភាសជាមួយ ភី ភួន សៀវភៅដែលសរសេរឡើងដោយ ឌៀក ដែលថាបានសន្ទនាជាមួយអ្នកភូមិនៅក្នុងឆ្នាំ២០០១ ហើយនិងមានឯកសារដែលលោកបានពិនិត្យឃើញថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៤។ បាទសំណួរខ្ញុំសួរថាតើប្រភពចម្បង ហើយប្រភពទៅនេះដែលនាំឲ្យលោកបានកត់ត្រានូវព្រឹត្តិការណ៍ទាំងអស់នេះ គឺទាំងអស់នេះឯង។ តើត្រូវដែរឬទេ?

[១៣:៣៦:៥៧]

**ផៈ** បាទ ត្រូវហើយ។ បទសម្ភាសជាមួយន៍ ភី ភួន, សន្ទនាជាមួយអ្នកភូមិ គឺប្រភព ភី សំខាន់ៗ ប៉ុន្តែប្រភពជាលាយលក្ខណ៍អក្សរនោះ គឺថាគឺ *វៀលីធី ខេមបូឌាន* គឺជាទិនានុប្បវត្តិប្រចាំសប្តាហ៍ ហើយសៀវភៅមួយរបស់អ្នកប្រវត្តិសាស្ត្រយោធារបស់សហរដ្ឋអាមេរិកផង។

**សៈ** សូមអរគុណ។ នៅពេលដែលលោកបាននិយាយជាមួយអ្នកភូមិ តើអ្នកភូមិដែលបានឃើញហេតុការណ៍ ឬក៏បានឆ្លងកាត់ហេតុការណ៍ហ្នឹងតាមដែលលោកដឹង?

**ផៈ** បាទ។

**សៈ** ខ្ញុំសូមសួរ ថាតើលោកបាននិយាយជាមួយអ្នកភូមិប៉ុន្មាននាក់ទាក់ទងទៅនឹងប្រជាជននៅតាមមូលដ្ឋាន នៅតាមកន្លែងដែលគេរស់នៅនោះ?

[១៣:៣៨:០៨]

**ផៈ** ខ្ញុំពិបាកនឹងឆ្លើយ ពីព្រោះខ្ញុំបាននិយាយជាមួយអ្នកភូមិជាច្រើនអំពីប្រធានបទផ្សេងៗ។ អ្នកខ្លះបានយោងទៅរកព័ត៌មាននេះ ប៉ុន្តែខ្ញុំជឿប្រាកដណាស់ថា មានប្រហែលជាពីរបីនាក់ដែលនិយាយអំពីឧដុង្គ។ ប្រហែលអាចមានលើសហ្នឹង។

**សៈ** សូមអរគុណ។ នៅក្នុងខ្លឹមសារមួយដែលលោកនិយាយថា មន្ត្រី ហើយនិងទាហាននៅក្នុងឯកសណ្ឋានត្រូវបានគេបំបែកចេញពីប្រជាជនយកទៅសម្លាប់នៅឆ្ងាយ ទីកន្លែងឆ្ងាយពីប្រជាជន។ តើលោកមើលបញ្ហានេះថាវាស្របជាមួយនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទេ វាស៊ីសង្វាក់

ទៅតាមអ្វីដែលគេចែងទេ?

**ឆ៖** នេះគឺវាស៊ីសង្វាក់ អ្វីដែលបានកើតឡើងពីមុន អ្វីដែលចាប់ផ្ដើមកើតឡើងនៅពេលនេះ ហើយអ្វីដែលកើតឡើងបន្ទាប់ពីនោះទៀត ក្រោយមកទៀតក៏អ៊ីចឹងដែរ។

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលទៅដល់ចំណុចមួយ។ យើងអាចនឹងនិយាយខដុង្គឡើងវិញ ប៉ុន្តែខ្ញុំសូមចូលទៅដល់ការប្រជុំដែលលោកបានពិភាក្សាជាមួយចៅក្រមពីម្សិលមិញ គឺនៅថ្ងៃ -- នៅឆ្នាំ ១៩៧៤ ជាកិច្ចប្រជុំរបស់គណៈមជ្ឈិមនៅកន្លែងមួយហៅឈ្មោះថា មាឃ។ ហើយតាមពិតនៅកន្លែងនោះលោករៀបរាប់ថា មានបញ្ហាសេចក្ដីសម្រេចបីសំខាន់ៗ ដែលលោកនិយាយថា ជាសេចក្ដីសម្រេចសំខាន់ៗនៅកន្លែងមួយឈ្មោះ មាឃ នោះ។ ខ្ញុំនឹងសួរសំណួរដំបូង អ្វីដែលខ្ញុំឃើញក្នុងកំណត់ត្រារបស់លោកថា ភី ភួន ក៏ជាប្រភពមួយផ្ដល់ព័ត៌មានអំពីការប្រជុំ។ តើលោកមានប្រភពផ្សេងទៀត ជាបង្អែកនៃការកំណត់យកព័ត៌មាននេះ? បាទ ក្រៅពីចម្លើយសារភាពដែលលោកបានទទួល លោកមិនបាច់យោងទៅរកនោះទេ។ បាទ ក្រៅពីហ្នឹង តើមានអ្វីទៀត?

[១៣:៤០:៣៨]

**ឆ៖** តាមដែលខ្ញុំចង់ចាំនោះ គឺថាការប្រជុំនោះ គឺ ភី ភួន ជាអ្នករៀបរាប់ប្រាប់ខ្ញុំ។ ប៉ុន្តែថាតើកំណត់ហេតុដែលលោកឃើញប្រភពផ្សេងទៀតនោះ ខ្ញុំអាចរកឃើញ។ ប៉ុន្តែខ្ញុំចង់ចាំនោះ គឺថា ភី ភួន ជាប្រភពចម្បងដែលផ្ដល់ព័ត៌មាននេះ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមបង្ហាញជូនលោកនូវឯកសារមួយ ដែលយើងបាន -- តុលាការបានជូនលោកនូវឯកសារ គឺ E3/11។ គឺឯកសារទស្សនាវដ្ដីទង់បដិវត្ត ខែកញ្ញា ឆ្នាំ១៩៧៧។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនឯកសារនេះ ជូនទៅអ្នកជំនាញជាឯកសារមួយដែលបានអង្គជំនុំជម្រះបញ្ជូនទៅគាត់ពីមុនមកហើយ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនអ្នកជំនាញពិនិត្យ។

[១៣:៤១:៥១]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** មុននឹងខ្ញុំអានខ្លឹមសារនៅលើនេះ ប្រហែលជាលោកបានដឹង ពីព្រោះតុលាការបានបញ្ជូន

ទៅលោកនូវប្រតិចារឹកនៃសក្ខីកម្មរបស់ ភី ភួន ដែលនិយាយអំពីកិច្ចប្រជុំរបស់គណៈមជ្ឈិមនៅមាយនោះ គឺថាចុះថ្ងៃទី មិថុនា ឬកក្កដា នៅក្នុងឆ្នាំនោះ។ មូលហេតុដែលខ្ញុំបង្ហាញជូនលោកនូវឯកសារនេះ គឺយើងនឹងទាក់ទងទៅនឹងសម័យកាលបរិច្ឆេទនេះ ហើយនិងដើម្បីឲ្យយល់ ថាតើហេតុការណ៍នោះជាហេតុការណ៍តែមួយ ឬក៏វាខុសគ្នា។ ឥឡូវនេះ យើងពិនិត្យមើលត្រង់ខ្មែរ ERN 00063162, អង់គ្លេស ERN 00486247, ទំព័រ៣៦ នៅលើឯកសារដែលលោកមាននេះ។ បារាំង ERN 00492836។ បាននិយាយដូចខាងក្រោមនេះ ពាក់កណ្តាលទំព័រឯណោះ។ សូមដកស្រង់ “នៅក្នុងស្ថានភាពនេះ ដែលគណៈមជ្ឈិមរបស់បក្សរបស់យើងក្នុងមហាសន្និបាតខែមិថុនា ឆ្នាំ៧៤ បានប្រកាសការវាយសម្រុកដណ្តើមទីក្រុងភ្នំពេញ និងទូទាំងប្រទេស”។

បើសិនជាលោកអ្នកជំនាញមិនសូវច្បាស់ សូមលោកកុំនិយាយដោយស្មាន គឺផ្អែកទៅលើការដឹងហើយនិងការស្រាវជ្រាវរបស់លោក ទើបជាចម្លើយដែលច្បាស់ជាង។

[១៣:៤៣:៤២]

**ឆ៖** នេះហើយជាព្រឹត្តិការណ៍តែមួយនោះឯង ពិតណាស់។ គឺថាយើងឃើញថា ប្រជាជននោះគេចាំហេតុការណ៍ហ្នឹងច្បាស់ ប៉ុន្តែកាលបរិច្ឆេទ គេអាចស្រពេចស្រពិល។ បាទ អ៊ីចឹងគឺថានៅទីនេះមិនមានការច្រឡំពីព្រឹត្តិការណ៍ទេ។ ប៉ុន្តែនៅពេលនោះ ខ្ញុំអានសៀវភៅឃើញថា ដូចជាមិនហៅចំឈ្មោះទង់បដិវត្តនោះទេ ប៉ុន្តែឯកសារនៅក្នុងសម័យកាលនោះ គឺថាជាឯកសារដែលគួរជឿជាក់បាន ដែលគេយកមកប្រើ។

**ស៖** សូមអរគុណ។ តាមពិត សេចក្តីសម្រេចមួយក្នុងចំណោមទាំងបីនោះ ដែលលោកបានរៀបរាប់ថា ជាសេចក្តីសម្រេចសំខាន់ដែលសម្រេចជាឯកច្ឆន្ទនោះ គឺថាត្រូវតែជម្លៀសទីក្រុងភ្នំពេញហើយនិងទីប្រជុំផ្សេងៗទៀត ទូទាំងប្រទេសនោះ។ ហើយលោកបានពិនិត្យសរសេរពីបញ្ហានេះ លោកក៏បានឆ្លើយខ្លះហើយដែរ។ ឥឡូវនេះ ខ្ញុំនឹងសួរបន្ថែម។ ខ្ញុំនឹងនិយាយអំពីសេចក្តីសម្រេចមួយក្នុងការដើម្បីប្រហារជីវិតសមាជិកឈ្មោះ ប្រសិទ្ធិ របស់ភូមិភាគកណ្តាល។ លោកបានបញ្ជាក់ថាមិនមែនជាកម្មាភិបាលទី១ ដែលត្រូវបានគេបោសសម្អាតនោះទេ ដែលថា តាម៉ុក បានបោសសម្អាតកម្មាភិបាលថ្នាក់ទាបមួយចំនួនរួចហើយ។ ហើយចំណុចដូចតទៅនេះ ទំព័រ២៦២, ERN នោះគឺថា 00396468 អង់គ្លេស, ហើយបារាំង 00639791 ជាភាសាបារាំង។ លោកនិយាយថា “នេះជាលើកដំបូងដែលថាអ្នកដែល -- បញ្ហានៅក្នុងជួរបក្ស -- ក្នុងកម្មាភិបាល និងជូនឲ្យបក្ស ហើយនិងថ្នាក់ដឹកនាំបានអនុញ្ញាត

ឬក៏បានឯកភាពឲ្យសម្លាប់កម្មាភិបាលក្នុងជួររបស់ខ្លួននៅក្នុងកិច្ចប្រជុំពេញអង្គនៅមាឃនោះ។

សូមលោកបំភ្លឺបន្ថែមអំពីសារៈសំខាន់ដែលថានេះជាហេតុការណ៍សំខាន់ ជាសេចក្ដីសម្រេចក្នុងការសម្រេចបោសសម្អាតសមាជិកមួយនៅក្នុងសមាជិកជាន់ខ្ពស់នៅក្នុងបក្សនោះ?

[១៣:៤៦:២៥]

**ឆ៖** តាមពិតយើងបាននិយាយរឿងនេះពីម្សិលមិញ នេះជាចំណុចសំខាន់ណាស់។ នៅក្នុងប្រព័ន្ធកុម្មុយនីស្ដណាមួយក៏ដោយ បក្សកុម្មុយនីស្ដណាមួយក៏ដោយ សេចក្ដីសម្រេចក្នុងការបោសសម្អាតនៅក្នុងជួរថ្នាក់ដឹកនាំនោះ ជាចំណុចខ្ពស់បំផុត ដូចជានៅសហភាពសូវៀត ដូចជានៅប្រទេសចិន ពីដំបូងៗនោះ ប្រសិទ្ធិ នេះជាករណីទី១ នៅកម្ពុជា។ នៅពេលដែលអ្នកណាម្នាក់ត្រូវបានទទួលស្គាល់ឲ្យចូលទៅជាបដិវត្តន៍កុម្មុយនីស្ដរបស់គេហើយ ដែលគេឈានទៅដល់ថ្នាក់ដឹកនាំហើយនោះ គឺ -- ហើយជាមនុស្សសំខាន់។ ពេលនោះ គឺថាអាចនឹងគេបញ្ចប់លទ្ធភាពដែលអាចបោសសម្អាតអ្នកហ្នឹងបានហើយ ប៉ុន្តែនៅករណី ប្រសិទ្ធិ នេះជាករណីពិសេស។

**ស៖** ក្នុងករណីដែលមានការសង្ស័យជាសេចក្ដីសម្រេចសមូហភាពដែលសមាជិកនៅក្នុងការពិភាក្សាក្នុងកិច្ចប្រជុំនោះបានសម្រេចជាឯកច្ឆ័ន្ទ ឬដូចម្ដេច?

**ឆ៖** ខ្ញុំយល់អ៊ីចឹង។ ជាពិសេសគឺថាតាមអត្ថន័យបកស្រាយ គេមានការពិភាក្សា ហើយក្រោយពីពិភាក្សាឡើងគឺថា គេបានសម្រេច។ អ៊ីចឹងន័យតាមការបកស្រាយគឺថា គេបានឯកភាពជាឯកច្ឆ័ន្ទ។

[១៣:៤៧:៥៩]

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់ទៅហេតុការណ៍នៅឧដុង្គដោយសង្ខេប។ ឥឡូវនេះ ខ្ញុំមានសេចក្ដីដកស្រង់មួយ ឯកសារមួយនឹងបង្ហាញជូនលោក ជាឯកសារទង់បដិវត្តដែរ នៅក្នុង -- ជាឯកសារនៅក្នុងពីខែធ្នូ ឆ្នាំ១៩៧៦ ដល់ ខែមករា ឆ្នាំ១៩៧៧ គឺឯកសារ E3/25។

សូមអនុញ្ញាតលោកប្រធាន ដើម្បីបង្ហាញជូនឯកសារនេះទៅលោកសាក្សីពិនិត្យផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនអ្នកជំនាញពិនិត្យ!

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនអ្នកជំនាញ)*

[១៣:៤៨:៤៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឥឡូវនេះពិនិត្យមើលឯកសារនេះ លោក ស្បូត ការបកប្រែភាសាអង់គ្លេស គឺថានៅទំព័រ ៣១ លោក យើងខ្ញុំនឹងបានឲ្យទៅលោកហើយ។ ERN នោះគឺខ្មែរ 00063039 ដល់ 40, បារាំង 00504049 ដល់ 50, ហើយអង់គ្លេស 00491424។ ខ្លឹមសារត្រង់នេះនិយាយជាសំខាន់នោះគឺថា គឺមានការផ្លាស់ប្តូរទីតាំងប្រជាជននៅមុនឆ្នាំ១៩៧៥។ ខ្ញុំនឹងអានពីរបីចំណុចជាសេចក្តីដកស្រង់ដើម្បីឲ្យលោកបំភ្លឺ។ ចាប់ផ្តើម "ការវាយខ្មាំងតាមនយោបាយ ជាឧទាហរណ៍នោះគឺ វាយប្រហារ ដើម្បីដកប្រជាជន មាគ៌ារបស់យើងគឺវាយដើម្បីយកប្រជាជន មួយ យើងយក១០០ យក១០០០ ហើយលើសពីហ្នឹងក៏យករហូតទាល់តែយើងដណ្តើមបានប្រជាជនទាំងអស់នៅទីក្រុងភ្នំពេញ។ ហើយគេពិភាក្សាឧទាហរណ៍ដូចជា បាណន់ -- បាណាន នៅក្នុងឆ្នាំ១៩៧៣ បាទ បាណន់ ហើយនិងជនជាតិចិន ហើយនិងនគរបាល ហើយនិងទាក់ទងទៅនឹងចេនឡាធូ – ជាសមរភូមិចេនឡាទី២។ បន្ទាប់មក ឧទាហរណ៍នៃទីក្រុងឧដុង្គនោះផងដែរបាទ។ តើលោកបានដឹងអំពីឃ្លាដែលថា ទង់បដិវត្តហ្នឹងយោងទៅរកថាការដក ការយកមនុស្សចេញពីតំបន់មួយទៅតំបន់មួយទេ ការរឹបអូសប្រជាជនពីខាងម្ខាងទៀតនោះ?

**ឆ៖** បាទ ខ្ញុំដឹងមាន គឺថាការត្រួតត្រាប្រជាជន គឺថាមិនត្រូវតែត្រួតត្រាលើទឹកដីទេ ប៉ុន្តែត្រួតត្រាលើប្រជាជន ហើយគេនិយាយ ហើយលោកទើបតែបានអាននេះ។ ទូទាំងប្រទេសគេមិនដែលបានវាយដណ្តើមយកគ្រប់គ្រងប្រជាជនទេ។ នេះហើយតាមពិតដែលបក្សកុម្មុយនីស្តចិន ជាតាក់ទិករបស់ចិនដែលបានធ្វើទូទាំងអាយុកាលនៃកុម្មុយនីស្តចិន ហើយខ្មែរក្រហមក៏បានប្រើវិធីស្រដៀងនោះដែរ។

[១៣:៥១:៣៦]

**ស៖** នៅក្នុងផ្នែកដំបូងដែលខ្ញុំអាននោះ គឺថាបង្ហាញពីហេតុការណ៍មួយចំនួនក្នុងការកៀរយកប្រជាជន ឬក៏ការដកយកប្រជាជនចេញពីតំបន់មួយ ចេញពីភ្នំពេញទៅគ្រប់គ្រង។ តើទំនាក់ទំនងនេះគឺថាវាបន្តនៅក្នុងការអនុវត្តគោលនយោបាយ ឬក៏អ្វីជាទម្លាប់របស់កុម្មុយនីស្តផ្សេងៗទៀតដែរឬទេ?

**ឆ៖** ខ្ញុំស្ទាក់ស្ទើរនឹងចូលជ្រៅទៅដល់រឿងនេះ លោកតែងតែបានឃើញនៅក្នុងឯកសារប្រភេទនេះ ដើម្បីពន្យល់អ្វីដែលគេព្យាយាមធ្វើនោះ។ គេយកចំណុចមួយតបន្តបន្ទាប់គ្នាទី១, ទី២ ជាហេតុ-

ការណ៍បន្តបន្ទាប់។

**ស៖** ម្សិលមិញលោកបាននិយាយថា “ឧដុង្គគេចាត់ទុកថា ជាឧទាហរណ៍ល្អរបស់គេ”។ ការជម្លៀសប្រជាជន ឬក៏ការដកយកប្រជាជនទៅគ្រប់គ្រងហ្នឹង គឺថាតើនេះជាការសាកល្បងពិសោធរបស់គេដើម្បីយកទៅអនុវត្តនៅពេលក្រោយដែរឬទេ បើតាមគំនិតលោកដែលបានដឹង បានឃើញ បានសិក្សាស្រាវជ្រាវឃើញនោះ?

**ឆ៖** ភី ភួន ដែលជាប្រភពសំខាន់របស់ខ្ញុំពីរឿងនេះ គាត់គឺថានិយាយគួរឲ្យជឿជាក់បានណាស់ គឺថា គេថាជាការជោគជ័យនៅឧដុង្គ ដែលធ្វើឲ្យមេដឹកនាំជឿថា គួរតែយកមកអនុវត្តចំពោះប្រជាជននៅភ្នំពេញដែរ ដូចជាដើមឆ្នាំ១៩៧៤ នៅឧដុង្គបន្ទាប់មកការប្រជុំនៅមាយហ្នឹង គេធ្វើសេចក្ដីសម្រេចគឺថា ស្របដូចទៅនឹងការអនុវត្តនៅឧដុង្គអ៊ីចឹងដែរ។

[១៣:៥៣:៣២]

**ស៖** សូមអរគុណ។ ដូច្នេះ ខ្ញុំនឹងព្យាយាមឆ្លងផុតពីព្រឹត្តិការណ៍មុនជម្លៀសហ្នឹង។ ឥឡូវនេះគឺថាហេតុការណ៍ឆ្នាំ១៩៧៤នោះ គឺទំព័រ២៦១ នៅក្នុងសៀវភៅរបស់លោក។ អង់គ្លេស ERN 00396496, បារាំង 00639792។ លោកបានរៀបរាប់ពីការធ្វើដំណើរទៅកាន់ប្រទេសចិន ជាដំណើររបស់ខៀវ សំផន ហើយលោកបាននិយាយដូចខាងក្រោមនេះ “ខៀវ សំផន បានទៅប្រទេសចិន ទៅជួប ម៉ៅ គឺជាកុម្មុយនីស្ត។ បាទ លើកទី១ ដែលបានធ្វើឡើងក្រោយពីឆ្នាំ១៩៦២ ហើយនៅក្នុងអាហ្វ្រិក ហើយនៅអឺរ៉ុបខាងកើត គោលបំណងគឺថា មិនទាមទារដើម្បីបានការគាំទ្រទេ ប៉ុន្តែសំខាន់ដើម្បីធានាការប្ដេជ្ញារបស់សម្ដេចនោះ គឺត្រូវតែនៅដដែល។ សូមឲ្យលោកពន្យល់ជម្រាបតុលាការថា តើលោកផ្អែកលើអ្វីដែលថាអាចសន្និដ្ឋានបែបនេះថា គេធ្វើអ៊ីចឹងដើម្បីកុំឲ្យព្រះអង្គ – សម្ដេច សីហនុ ហ្នឹងកែប្រែសេចក្ដីសម្រេចចិត្ត?

[១៣:៥៥:០១]

**ឆ៖** នេះជាការបន្តពីអ្វីដែលយើងបាននិយាយពីខាងដើមជាតុល្យ -- គេរក្សាតុល្យភាព។ គឺថាធ្វើឲ្យគេមានច្បាស់ដែលថា ដែលគេយាងព្រះអង្គឲ្យធ្វើទស្សនកិច្ចនៅ៧៣ នៅតំបន់រំដោះនោះ។ បាទ ហើយមួយទៀតដើម្បីកុំឲ្យព្រះអង្គហ្នឹងមានប្រជាប្រិយភាពពេកផងដែរ។ ប៉ុន្តែនៅកាលនោះ គេត្រូវការសម្ដេច សីហនុ ខ្លាំងណាស់ ដើម្បីបង្ហាញពីរូបភាពអន្តរជាតិ អំពីចលនារបស់គេ។ ហើយដំណើរទៅអាហ្វ្រិក ហើយនិងទៅអាស៊ីជាដើមហ្នឹង មួយផ្នែកហ្នឹងគឺដើម្បីបានការគាំទ្របន្ថែម ដើម្បីបញ្ជូនសារ

របស់គេទៅប្រទេសផ្សេងៗ។ ប៉ុន្តែវាខ្លាំងជាអ្វីផ្សេងៗទៀតនោះ គឺដើម្បីឲ្យសម្តេច សីហនុ នៅកៀកនឹងចលនា។ ហើយបើលោកសួរថា ខ្ញុំបានសេចក្តីសន្និដ្ឋានហ្នឹងមកពីណា ខ្ញុំត្រូវតែជម្រាបលោកថាអានេះជាការបកស្រាយផ្អែកតាមអ្វីដែលខ្ញុំយល់ដឹង។ នេះហើយគឺជាសេចក្តីពន្យល់ផ្អែកតាមអ្វីអង្គហេតុនោះ។

[១៣:៥៦:១២]

**ស៖** សូមអរគុណ។ នៅក្នុងដំណើរនេះ យើងមានឯកសាររបាយការណ៍អំពីដំណើរនេះនៅក្នុងសំណុំរឿង ហើយដោយសារពេលវេលាខ្លី ខ្ញុំនឹងចូលទៅរកប្រធានបទថ្មី។ ប៉ុន្តែឯកសារនៅក្នុងសំណុំរឿងនោះ គឺឯកសារលេខ 12.7 គឺថាព័ត៌មានដំណឹងកម្ពុជានៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៤។ របាយ-ការណ៍ហ្នឹងគឺគេនិយាយថា សុន្ទរកថារបស់ ខៀវ សំផន នៅពេលដែលគាត់នៅក្នុងកូរ៉េខាងជើងក្នុងឆ្នាំ១៩៧៤។ ជាសំខាន់នោះ គេនិយាយថាកងកម្លាំងប្រដាប់អាវុធ គឺថានៅសមរភូមិហ្នឹងបានរំដោះទីក្រុងឧដុង្គ។ ខ្ញុំចង់សួរលោកថា តើលោកបានដឹងអំពីសុន្ទរកថារបស់គាត់ហ្នឹងដែរឬទេ នៅក្នុងបរិបទដំណើររបស់គាត់នាកាលនោះ?

**ឆ៖** ខ្ញុំមិនគិតថា ខ្ញុំបានដឹងពីរឿងនេះទេ ពីសុន្ទរកថានេះទេ។

[១៣:៥៧:២២]

**ស៖** បាទសូមអរគុណ។ ឥឡូវនេះយើងចូលទៅដល់ផ្នែកមួយទៀត ដើមឆ្នាំ១៩៧៥។ គឺយើងនិយាយអំពីការត្រៀមរៀបចំសម្រាប់ការធ្វើជម្លៀសប្រជាជន។ ខ្ញុំនឹងសួរសំណួរមួយចំនួនអំពីហេតុ-ការណ៍នានានៅថ្ងៃទី១៧ ខែមេសា ហើយនិងបន្ទាប់មកហើយនិង-- យើងមិនមានពេលច្រើនទេ។ អ៊ីចឹងខ្ញុំនឹងរៀបចំសំណួរឲ្យបានច្បាស់នោះ។ ឥឡូវនេះយើងមើលសៀវភៅរបស់លោកទំព័រ២៦៩ ដល់២៧០។ លោកបានរៀបរាប់អំពីការចូលទៅក្នុងទីក្រុងភ្នំពេញ ដែលថាកងកម្លាំងខ្មែរក្រហមចូលទីក្រុងភ្នំពេញនោះ។ ខ្មែរ ERN -- សូមអភ័យទោសយើងអត់មានខ្មែរទេ យើងមានអង់គ្លេស គឺ00396477 ដល់ 78, បារាំង ERN 00639802 ដល់ 03។

មានចំណុចមួយចំនួនដែលខ្ញុំចាប់អារម្មណ៍នៅទីនេះ នៅខាងក្រោមទំព័រ២៦៩ លោកបាននិយាយអំពីបញ្ហាមួយចំនួនដូចដែលលោកបាននិយាយពីម្សិលមិញ អ្នកដែលចុះចាញ់នៅទីនោះ នៅទីនេះ។ ឥឡូវនេះគឺជាឈ្លើយសឹក គឺថាអ្វីៗដែលគេចាត់ទុកពួកនោះ គេហៅថាពួកនេះជាជ័យភណ្ឌ ជាឈ្លើយសង្គ្រាមដូចជាភូមិភាគពិសេស ភូមិភាគឧត្តរ គឺថាមិនត្រូវឲ្យលួចឆក់ប្លន់ ឬក៏សម្លាប់នោះទេ។ លើកលែងតែករណីចាំបាច់។ នោះគឺគេនិយាយអ៊ីចឹង។ តើលោកមានបានលទ្ធភាពសិក្សាអំពីបញ្ហានេះលម្អិតដែរឬទេ

ដែលថាការបញ្ជា ឬក៏ការណែនាំទាំងអស់នោះ ត្រូវបានគេសម្របសម្រួលអនុវត្តដូចម្ដេច? ថាតើលោកអាចបំភ្លឺជូនតុលាការអ្វីច្បាស់ជាងហ្នឹងបានដែរឬទេ?

[១៣:៥៩:៥៦]

**ឆ៖** សេចក្ដីរៀបរាប់អំពីការជម្លៀសទីក្រុងភ្នំពេញនោះ។ តាមពិតនោះប្រភពផ្សេងៗទៀត គឺទំនងជាយល់ស្របគ្នាថា បុគ្គលនីមួយៗមានអំណាចក្នុងអនុវត្តការជម្លៀសរបស់គេដាច់ដោយឡែក។ ដូចជាភូមិភាគបូព៌ាទំនងជាមានលក្ខណៈធូរស្រាលជាងភូមិភាគនិរតីរបស់ តាម៉ុក ជាដើម។ នេះហើយជាគំរូទាំងស្រុង គឺថាភូមិភាគនីមួយៗមានគោលនយោបាយខុសគ្នាបន្តិចបន្តួច ហើយបុគ្គលម្នាក់ៗជាកម្មាភិបាលជាន់ខ្ពស់នោះ គឺថាដូចជាកម្មាភិបាលយោធាថ្នាក់ក្រោមនោះ គឺថាគេមានផ្នត់គំនិតដឹកនាំ ឬក៏អនុវត្តខុសគ្នាបន្តិចបន្តួច ហើយនៅក្នុងគោលនយោបាយនោះគឺថាគេអាចនឹងងាកចេញបន្តិចបន្តួចបាន។

**ស៖** សូមអរគុណ។ ទំព័រ២៧៥ នៅត្រង់ពាក់កណ្ដាលទំព័រ។ អង់គ្លេស ERN 00396483, បារាំង ERN 00639810។ នេះគឺបន្ទាប់ពីការពិភាក្សាវិធានការរបស់កងកម្លាំងភូមិភាគ។ លោកបាននិយាយដូចខាងក្រោមនេះ "ប៉ុន្តែជាវិធីខុសគ្នានៃការអនុវត្ត មិនមែនជានយោបាយទេ កាលណាជម្លៀសការ -- ការបញ្ជាជម្លៀសនោះបានចេញហើយ គឺថាគេត្រូវធានាថា តំបន់ទីកន្លែងនោះត្រូវតែជម្លៀសឲ្យអស់"។ តើភាពខុសគ្នានៃការអនុវត្ត និងការបញ្ជាហ្នឹង លោកអាចបន្ថែមអ្វីបានដល់តុលាការទេ?

[១៤:០០:៥០]

**ឆ៖** គោលនយោបាយគឺដូចគ្នា តែការអនុវត្តគឺវាខុសគ្នា។ ដូច្នេះហើយគឺថាវាកើតឡើងគ្រប់ទីកន្លែង ប៉ុន្តែវាមានការខុសគ្នានៅក្នុងការអនុវត្តគោលនយោបាយនោះ។

**ស៖** ចំណុចមួយទៀតនៃការជម្លៀស ដែលលោកបានពណ៌នានៅក្នុងសៀវភៅរបស់លោក គឺការកាប់សម្លាប់មន្ត្រីរបស់ លន់ នល់ ហើយលោកបានរៀបរាប់អំពីការកើតឡើងនៅកន្លែងជាច្រើនដែលកើតនៅ -- ដែលមានទំព័រ២៧១ គឺមានលេខ ERN 00396479, បារាំងមានលេខ 00639804 ដល់ 5។ គឺលោកបាននិយាយដូចតទៅនេះ "នៅសណ្ឋាគារមនោរម្យ គឺពីរបីប្លុកពីខាងរទេះភ្លើង គឺមានលោក កុយ ធួន បានបង្កើតនូវស្នាក់ការរបស់លោក ហើយបង្កើតនូវគណៈកម្មាធិការមួយដើម្បីបោសសម្អាតខ្មាំង។ សកម្មភាពទី១ គឺធ្វើការសម្រេចទៅលើការសម្លាប់ ឡុង បូរ៉េត, លន់ នល់ -- លន់ ណុន ហើយនិងមន្ត្រីខ្ពស់ៗដទៃទៀត ដែលគេត្រូវយកមកសម្លាប់ដោយសារតែ -- ដែលការសម្លាប់ហ្នឹងមានទីតាំងមិនឆ្ងាយពីក្រសួងមហាផ្ទៃប៉ុន្មានទេ គឺមិនឆ្ងាយពីកន្លែងដែលគេឃុំខ្លួនប៉ុន្មានទេ"។ ដូច្នេះ ខ្ញុំចង់សួរលោក

ថាតើៗលោកបានព័ត៌មានពីណាពីការបង្កើតគណៈកម្មាធិការដែលត្រូវយកមកសម្លាប់នៅក្បែរក្រសួងព័ត៌មាននោះ?

[១៤:០៣:២៤]

**ឆ៖** ខ្ញុំមិនដឹងទេចំពោះបញ្ហានេះ។

**ស៖** តើលោកមានព័ត៌មានដែរឬទេ ថាតើអ្នកណាខ្លះនៅក្នុងគណៈកម្មាធិការនោះ ដែលមានទីតាំងនៅក្បែរស្នាក់ការរបស់ កុយ ធួន? ថាតើលោកដឹងអំពីបញ្ហាព័ត៌មានទាំងអស់នេះទេ?

**ឆ៖** អត់ទេ ខ្ញុំមិនដឹងទេ វាមានផ្នែកមួយចំនួនដែលយើងមិនមានឯកសារ ហើយមិនមានអ្នកណាដែលអាចប្រាប់ព័ត៌មានដល់ខ្ញុំបានអំពីបញ្ហានេះ។

**ស៖** ខ្ញុំសូមអាននូវឃ្លាមួយទៀត ដែលទាក់ទងទៅនឹងប្រជាជនដែលត្រូវបានជម្លៀសពីទីក្រុងភ្នំពេញ ហើយនិងការប្រព្រឹត្តចំពោះទាហាន លន់ នល់ គឺទំព័រ២៧៣។ មានលេខ ERN ដូចតទៅនេះ 00396481 ជាភាសាអង់គ្លេស, និងភាសាបារាំងមានលេខ 00639807។ ហើយនេះគឺជាឃ្លាមួយដែលមានការចាប់អារម្មណ៍ខ្ពស់ គឺនិយាយពីអ្នកដែលត្រូវជម្លៀសចេញពីភ្នំពេញ។ "នៅពេលដែល គង់មកដល់ចំណុចត្រួតពិនិត្យនៅព្រែកភ្នៅ មន្ត្រីមួយចំនួនត្រូវបានគេស្នើឲ្យមកបង្ហាញខ្លួន។ គេត្រូវបានប្រាប់ថាមន្ត្រីទាំងអស់នោះ ត្រូវគេនាំយកទៅទីក្រុងភ្នំពេញវិញដើម្បីជួយអង្គការ។ ហើយនៅក្នុងនោះគេកំណត់នូវមន្ត្រីជាន់ខ្ពស់ ដូចជា ឧបនាយករដ្ឋមន្ត្រី ហង់ ធុនហាក់ ត្រូវបានគេនាំទៅដល់ស្នាក់ការរបស់ កុយ ធួន នៅសណ្ឋាគារមនោរម្យ ហើយត្រូវបានគេសម្លាប់។ ចំណែកអ្នកដទៃទៀត ត្រូវបានគេនាំយកទៅវាលស្រែ ហើយបន្ទាប់មកត្រូវបានគេសម្លាប់ចោល។ អ្វីដែលខ្ញុំចង់សួរលោកនៅពេលនោះគឺថាខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលយើងនិយាយអំពីគណៈកម្មាធិការមួយរបស់ស្នាក់ការ កុយ ធួន ហើយបន្ទាប់មក មានការបញ្ជូនកម្លាំង ដូចដែលខ្ញុំនិយាយពេលនេះ តើវាមានលក្ខណៈយ៉ាងដូចម្ដេចដែរចំពោះបញ្ហានេះ?

[១៤:០៥:៤៦]

**ឆ៖** សេចក្ដីសម្រេចក្នុងការបញ្ជូន ហង់ ធុនហាក់ ហើយនិងមន្ត្រីម្នាក់ទៀតនោះ គឺថាត្រូវបានដាក់ចេញពីថ្នាក់ខាងលើ។ សេចក្ដីសម្រេចដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះ ក្នុងការសម្លាប់មន្ត្រីនៅក្នុងកម្រិត ឬក៏នៅក្នុងឋានៈមួយចំនួន ខ្ញុំសន្និដ្ឋានថា ប្រហែលជាសេចក្ដីណែនាំរបស់មជ្ឈិម។ ដូច្នេះមជ្ឈិមជាអ្នកសម្រេច ហើយចំពោះការសម្លាប់មន្ត្រីថ្នាក់បន្តបន្ទាប់ គឺសម្រេចដោយភូមិភាគ។ ដូច្នេះ

ហើយគឺថាវាមានស្ថានភាពខុសៗគ្នាក្នុងការដែលពួកគេអនុវត្តនូវការបង្គាប់បញ្ជានោះ។ ខ្ញុំមិនចង់និយាយលម្អិត ហើយខ្ញុំមិនចង់បញ្ជាក់ឲ្យបានស៊ីជម្រៅបន្ថែមនោះទេ។ ប៉ុន្តែខ្ញុំយល់អំពីអ្វីដែលចង់និយាយនេះ។ នេះគឺថាមិនមែនជាការបញ្ជារបស់ទាហានតូចទាបនោះទេ។ ដូច្នេះ គឺថាទាហានធម្មតាគ្រាន់តែទទួលបញ្ជាដើរមើលតាមផ្ទះ ដើម្បីធានាថា អត់មានអ្នកណាម្នាក់នៅក្នុងផ្ទះ អត់មានពួននៅក្នុងផ្ទះអីនោះទេ។ ចំពោះបញ្ហាថានៅពេលដែលគាត់ឃើញអ្នកនៅសល់ហ្នឹង គាត់សម្លាប់ហ្នឹង សួរថាតើមានបញ្ហាអត់ទេ? គេថាអត់មានបញ្ហាទេ។ ដូច្នេះហើយ អ្វីដែលខ្ញុំចង់និយាយ គឺថាការគិត ការយល់ឃើញ គឺថានៅពេលដែលឃើញមនុស្សហ្នឹង គឺគាត់ជាអ្នកសម្រេចសម្លាប់តែម្តង។

[១៤:០៧:១៤]

**ស៖** លោកបាននិយាយអំពីផ្សេងៗទៀត នៅទំព័របន្ទាប់ គឺនៅទំព័រ២៧៧។ ភាសាអង់គ្លេសមានលេខ 00396485, និងបារាំងមានលេខ 00639812 ដល់ 13។ ដើម្បីជាកំណត់ត្រាប្រតិចារឹក គឺលោកបានរៀបរាប់អំពីការកាប់សម្លាប់នៅបាត់ដំបង ហើយនិងប៉ៃលិន។ ហើយលោកបានរៀបរាប់ពីភាពខុសគ្នានៃការសម្លាប់ទាំងអស់នោះ។ ផ្អែកទៅតាមការស្រាវជ្រាវរបស់លោកនោះ ចំពោះតំបន់ដែលលោកគិតថា មានការកាប់សម្លាប់មនុស្សរបស់អតីតរបបជំនាន់មុន ឬក៏ថាតើវាមានការប្រែប្រួល ឬក៏វាមានការប្រហាក់ប្រហែលគ្នា។ តើលោកអាចជម្រាបបានដែរឬទេ ថាផ្អែកទៅលើអ្វីដែលលោកបាននិយាយថាជាការបង្គាប់ពីថ្នាក់មជ្ឈិមនោះ យ៉ាងម៉េចដែរ?

**ឆ៖** គឺមានគំរូរួមគ្នាមួយនៅទូទាំងប្រទេស គឺការកាប់សម្លាប់មន្ត្រី លន់ នល់។ ទោះបីថានៅក្នុងឋានៈណាក៏ដោយ។ ហើយចំពោះការសម្លាប់របស់មន្ត្រី លន់ នល់ នៅតាមឋានៈមួយចំនួនគឺថាមន្ត្រីយោធាគឺមានលក្ខណៈប្រហាក់ប្រហែល ចំណែកមន្ត្រីរាជការវិញគឺថា មានករណីជាច្រើនដែលថាមន្ត្រីរាជការមួយចំនួនគាត់អាចគេចខ្លួនបានរហូត ឬក៏គេចបានមួយរយៈពេល ឬមួយក៏អ្នកខ្លះទៀតគាត់អាចរស់រហូតនៅក្នុងខ្មែរក្រហមនោះ ដោយមិនត្រូវបានទទួលកាប់សម្លាប់។ ដូច្នេះ ទោះបីថាវាមានប្រព័ន្ធក៏ដោយ ក៏មាននៅចន្លោះប្រហោងនៃប្រព័ន្ធនោះផងដែរ។

[១៤:០៩:១៧]

**ស៖** ហើយនៅទំព័រ២៧៥ គឺលោកនិយាយអំពីចំនួននៃមនុស្សដែលបានសម្លាប់។ ហើយលោកនិយាយអំពីហេតុការណ៍មួយទៀតដែលកើតឡើងនៅក្នុងទីក្រុងដែលមានចំនួនច្រើនផងដែរ។ អង់គ្លេសមានលេខ 00396483, បារាំងមានលេខ 00639802 ដល់ 03។ គឺនៅនេះមានចំណុចមួយខ្លី ដែលខ្ញុំ

សូមដកស្រង់៖ លោកបានរៀបរាប់អំពីជនជាតិបារាំង ជាមួយជនជាតិអាល្លឺម៉ង់ ដែលត្រូវបានគេបណ្តេញចេញ ប៉ុន្តែនៅក្នុងប្រទេសបារាំង ការកាប់សម្លាប់ ការធ្វើបាបស្ត្រី ក៏ដូចជាការធ្វើបាបនានា គឺធ្វើឡើងជាបុគ្គល ឬក៏ជារួម។ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាគឺថា វាគឺជាលទ្ធផលនៃសេចក្តីសម្រេចគោលនយោបាយច្បាស់លាស់ ដែលធ្វើឡើងដោយអាជ្ញាធរជាន់ខ្ពស់របស់ប្រទេស គឺ ប៉ុល ពត ហើយនិងគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា។ តើលោកអាចបកស្រាយយ៉ាងម៉េចដែរ ចំពោះបញ្ហានេះ?

**ឆ៖** ខ្ញុំពិតជាបាននិយាយបែបនេះមែន ប៉ុន្តែដូចជាម្សិលមិញអ៊ីចឹងចៅក្រម ឡាវែន៍ គាត់បានសួរខ្ញុំថាតើមានអ្វីដែលខ្ញុំចង់បន្ថែមទៀតនោះ។ គឺថាតាមការប៉ាន់ស្មានចំនួនមនុស្សដែលបានសម្លាប់បន្ទាប់ពីសង្គ្រាមលោកលើកទី២ នៅប្រទេសបារាំងនោះ គឺត្រូវបានគេបង្កើនចំនួនដោយសារតែមានប្រភព ប៉ុន្តែអ្វីដែលខ្ញុំចង់និយាយគឺថា ខ្ញុំនិយាយថា១០០.០០០ ប៉ុន្តែវាអាចលើសពី១០០.០០០ ហ្នឹងទៅទៀត។ ដូច្នេះអានេះគឺជាអ្វីដែលខ្ញុំឆ្លើយបន្ថែមផងដែរទៅលើអ្វីដែលលោកចៅក្រម ឡាវែន៍ បានសួរកាលពីម្សិលមិញ។

[១៤:១១:០៥]

**ស៖** ចំណុចមួយទៀត ដែលនិយាយអំពីភាពប្រហាក់ប្រហែលគ្នា ដែលលោកបានសរសេរនៅក្នុងសៀវភៅរបស់លោកផងដែរនោះ គឺនិយាយអំពីការជម្លៀសប្រជាជន គឺនៅទំព័រ២៧៦ ដល់ ២៧៧, អង់គ្លេសមានលេខ 00396484 ដល់ 5 និងភាសាបារាំងមានលេខ 00639811 ដល់ 12។ គឺថាលោកបានរៀបរាប់អំពីហេតុការណ៍ដែលកើតឡើងនៅថ្ងៃបន្ទាប់ គឺនៅថ្ងៃ១៨ មេសា និងថ្ងៃបន្តបន្ទាប់ដែលបានកើតឡើងនៅទីក្រុង។ គឺលោករៀបរាប់អំពី សុន សេន ហើយនិងមេបញ្ជាការមកពីតំបន់នានាដើម្បីបញ្ជាក់ ដើម្បីកំណត់នូវតំបន់ ក៏ដូចជាកំណត់នូវភូមិភាគ។ ហើយចុះក្រោមបន្តិចនោះ គឺលោកបានរៀបរាប់ដូចតទៅនេះ “គោលការណ៍ថ្មីត្រូវបានគេចេញ ដើម្បីធ្វើឲ្យមានភាពស៊ីសង្វាក់គ្នានៅក្នុងនីតិវិធីនៃការជម្លៀសនៅក្នុងផ្នែកផ្សេងៗគ្នានៃប្រទេស គឺថាប្រជាជនមិនអាចជ្រើសរើសថា តើត្រូវទៅណាទៀតនោះទេ។ អ្នកណាដែលទៅខាងត្បូងគឺទៅខាងត្បូង គឺទៅតាមផ្លូវជាតិលេខ៥ ទោះបីថាភូមិរបស់គាត់គឺនៅក្នុងទិសដៅខុសគ្នាក៏ដោយ។ ដូច្នេះអ្នកដែលត្រូវទៅខាងលិច គឺត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ៣ ឬលេខ៤ ទៅកំពត កំពង់ស្ពឺ ចំណែកអ្នកដែលខាងត្បូង គឺទៅតាកែវ ឬស្វាយរៀង។ ចំពោះបញ្ហាប្តីប្រពន្ធ ឬក៏ពុកម្តាយ គឺត្រូវបានកើតឡើងដូចគ្នា ហើយពេលខ្លះគេនៅផ្សេងពីគ្នាមែន ក៏គេមិនយកចិត្តទុកដាក់ដែរ គឺថានេះគឺជាអ្វីដែលបានកើតឡើង។ ចំពោះអ្នកដែលឈឺ ឬក៏អ្នកចាស់ហ្នឹងត្រូវបានគេសម្លាប់។ ហេតុការណ៍ប្រហាក់ប្រហែលគ្នាហ្នឹងដែលមានការប្រែប្រួលបន្តិចបន្តួចកើតឡើងនៅទូទាំងផ្ទៃប្រទេស

កម្ពុជាទាំងមូល"។

[១៤:១៣:០៨]

ដូច្នេះគឺលោករៀបរាប់ហាក់ដូចជាវាមានភាពស៊ីសង្វាក់គ្នា ឬក៏ភាពដូចគ្នា ឬក៏ខ្ញុំអាចនិយាយម៉្យាងទៀតថា វាជាប្រព័ន្ធមួយនៃ -- ដែលមានលក្ខណៈជានីតិវិធី ដែលគេធ្វើការសម្រេចនៅថ្នាក់មជ្ឈិមបន្ទាប់គឺគេបានបញ្ជាមកឲ្យអនុវត្ត។ ថាតើការស្រាវជ្រាវរបស់លោកបញ្ជាក់បែបនេះបានដែរឬទេ? តើលោកអាចបង្ហាញនូវការពិតទៅលើបញ្ហានេះបានដែរឬទេ?

**ឆ៖** បញ្ហាមួយដែលកើតឡើង គឺថាមេបញ្ជាការភូមិភាគផ្សេងៗគ្នា គឺគាត់មិនដែលធ្វើការងារជាមួយគ្នាពីមុនឡើយ ព្រោះថាភូមិភាគរបស់គាត់ដាច់ពីគ្នា ហើយគាត់ធ្វើការរៀងៗខ្លួន នៅពេលដែលពួកគាត់មកជួបគ្នានៅទីក្រុងភ្នំពេញហ្នឹង គឺថាពេលខ្លះ គឺទាហានគាត់ហ្នឹងគឺវាដូចជាមិនអាចធ្វើការជាមួយគ្នាបាន។ ដូច្នេះគេចាំបាច់ត្រូវចេញនូវវិធាន ឬក៏ច្បាប់មួយដើម្បីឲ្យពួកគាត់ធ្វើការជាមួយគ្នាបានដោយស៊ីសង្វាក់គ្នា។ ដូច្នេះនៅពេលដំបូងគឺយើងឃើញថាវាជាការបន្ស៊ីចូលគ្នា ហើយវាជាការកំណត់ជាលក្ខណៈរួមមួយទាក់ទងទៅនឹងគោលនយោបាយនៃការជម្លៀសប្រជាជន។

[១៤:១៤:៣៥]

**ស៖** អង្គហេតុមួយដែលលោកបានពិភាក្សាពីម្សិលមិញ ជាពិសេសគឺមូលហេតុនៃការជម្លៀសនោះ គឺលោកបាននិយាយអំពីបញ្ហាដែលថា ប្រជាជនត្រូវបានគេប្រាប់ថា មិនឲ្យយកអីវ៉ាន់ច្រើនតាមខ្លួននោះទេ ខ្ញុំចង់និយាយអំពីបញ្ហានេះ។ នៅចុងនៃទំព័រ២៨៧ ភាសាអង់គ្លេសមានលេខ 00396495, បារាំងមានលេខ 00639825 ដល់26។ លោកបានរៀបរាប់អំពីស្ថានភាពរបស់អ្នកដែលត្រូវបានគេបណ្តេញចេញ ភាគច្រើននៃអ្នកត្រូវបានគេជម្លៀសត្រូវបានមកដល់ទីក្រុង -- មកដល់ជនបទ ដោយដៃទទេ ហើយ ខៀវ សំផន ពន្យល់ថា ដោយជាមួយនឹងភស្តុតាងនៃការពេញចិត្តដោយសារតែមានទ្រព្យសម្បត្តិបន្តិចបន្តួច ដែលពួកគេអាចយកតាមខ្លួនហ្នឹង គឺយើងអាចកាត់បន្ថយបាននៅក្នុងរយៈពេល២ ឬក៏៣ឆ្នាំ។ តាមពិតទៅ គឺមានការកម្រិតកំណត់ចំនួនដែលពួកគេត្រូវយកតាមខ្លួនដើម្បីឲ្យប្រជាជនដែលត្រូវបានបញ្ជាឲ្យចាកចេញក្នុងរយៈពេលចាប់ -- ក្នុងពេលខ្លីហ្នឹង គឺគាត់អាចទទួលយកបាន។ ប៉ុន្តែនៅក្នុងការប្រកាសជាផ្លូវការ យុទ្ធសាស្ត្រនេះគឺត្រូវបានគេធ្វើចេញដោយស្ងៀមស្ងាត់។ ដូច្នេះអ្វីដែល -- ថាតើលោកអាចប្រាប់បានដែរឬទេ ថាតើឃ្លាដែល ខៀវ សំផន បានប្រកាសហ្នឹងគឺវាបញ្ជាក់ពីគោលនយោបាយ ឬក៏មាគ៌ាដែលយើងបានពិភាក្សាពីម្សិលមិញ ទាក់ទងទៅនឹងការដែលបង្គាប់បញ្ជាមិនឲ្យ

ប្រជាជនយកអីវ៉ាន់ច្រើនតាមខ្លួននោះដែរឬទេ?

[១៤:១៦:២៥]

**ឆ៖** ផ្នែកនេះគឺបានរៀបរាប់ថា ប្រជាជនដែលត្រូវបានគេជម្លៀសចេញ គឺថាមកដោយដៃទទេហើយ ខៀវ សំផន បានបញ្ជាក់ថាវាមានភស្តុតាងនៃការពេញចិត្ត ហើយដោយសារតែអ្វីដែលគេយកមកតិចតួចហ្នឹង គឺទៅប្រើប្រាស់អស់ក្នុងរយៈពេល២ ឬ៣ឆ្នាំ។ ដូច្នេះប្រសិនបើយើងយកអីវ៉ាន់តិចតួចតាមខ្លួន គឺអីវ៉ាន់ហ្នឹងវានឹងអស់ឆាប់ អស់ក្នុងរយៈពេលឆាប់។ ដូច្នេះនៅពេលនុ៎ងគឺ មនុស្សស្មើគ្នាទាំងអស់គឺអត់ដូចគ្នា។ វាគឺជាវិធីសាស្ត្រមួយ ឬក៏កម្មវិធីមួយដែលថា គេធ្វើឲ្យមនុស្សគ្មានអីវ៉ាន់ទាំងអស់គ្នា។ បានន័យថា នៅពេលដែលយើងគ្មានទ្រព្យសម្បត្តិដូចគ្នា គឺមនុស្សទាំងអស់ហ្នឹងស្មើគ្នាហើយ។ ដូច្នេះនៅពេលដែលពួកគាត់អត់មានអីវ៉ាន់ទាំងអស់ អត់មានទ្រព្យសម្បត្តិអីទាំងអស់ គឺថា គឺស្មើគ្នា។ ដូច្នេះដោយសារតែមាការជូនដំណឹងឆាប់រហ័សទៀតផងហ្នឹង គឺថាគាត់មិនអាចយកអ្វីតាមខ្លួនបានដូច្នេះឯង។

**ស៖** បន្តមកទៀត នៅក្នុងឃ្លាបន្ទាប់ទៀត។ ខ្ញុំសូមដកស្រង់ "ទោះបីថារបបថ្មីចាប់ផ្ដើមដោយមានការកុហក ប៉ុន្តែលក្ខណៈសំខាន់មួយរបស់ពួកគេ គឺថាបន្ទាប់ពីឆ្នាំ១៩៧៥ គឺថាអ្វីៗដែលមេដឹកនាំខ្មែរនិយាយ គឺមិនអាចទុកចិត្តបានទេ ពួកគេព្យាយាមលាក់លៀមរបៀបនិយាយកុហកព្រោះថា ពួកគេមិនអាចចាំថាតើមានអ្វីដែលបានកើតឡើង គេ ពេលខ្លះគេកុហកដោយសារតែការយល់ខុស ដោយសារបញ្ហា ឬក៏ដោយសារតែខ្ជិលតែម្ដង។ ដូច្នេះការកុហកហ្នឹង គឺក្លាយទៅជាមធ្យោបាយក្នុងការគ្រប់គ្រងក្នុងការលុបបំបាត់ ក៏ដូចជាបិទបាំងនៅព័ត៌មាន ឬក៏គោលនយោបាយដែលមានភាពមិនច្បាស់លាស់នានា"។ ខ្ញុំចង់សួរលោកអំពីការកុហករបស់របបកម្ពុជាប្រជាធិបតេយ្យ តើយ៉ាងដូចម្ដេចដែរ?

[១៤:១៨:២៤]

**ឆ៖** ខ្ញុំគិតថានេះគឺជាការវាយតម្លៃដែលមានលក្ខណៈធ្ងន់ធ្ងរ ប៉ុន្តែខ្ញុំនៅគាំទ្រការវាយតម្លៃរបស់ខ្ញុំនោះ។ វាជាសេចក្ដីសម្រេចចិត្ត គឺជាការសម្រេចចិត្តដោយច្បាស់លាស់ ដើម្បីបង្ហាញទៅដល់ពិភពលោកថារាល់របបកម្ពុជាប្រជាធិបតេយ្យ គឺថាវាមានករណីជាច្រើននៅពេលដែល ប៉ុល ពត ទៅប៉េកាំងប្រទេសចិន សម្រាប់ជាការទស្សនកិច្ចផ្លូវការ គាត់បានថ្លែងសុន្ទរកថាវែងមួយនិយាយអំពីប្រទេសកម្ពុជាហើយខ្ញុំចាំថា គាត់និយាយថា "មនុស្សទាំងអស់នៅក្នុងប្រទេសកម្ពុជាមាន -- ទទួលបានស្រូវ២៥០ -- ៣៥០គីឡូក្នុងមួយឆ្នាំ"។ ដូច្នេះអាហ្នឹងគឺគាត់រៀបរាប់បែបនេះឯង។ គឺគាត់និយាយកុហក ដូចដែលខ្ញុំបញ្ជាក់អីចឹង គឺថាពេលខ្លះគឺថាការកុហកហ្នឹង គឺកុហកដោយមិនមានហេតុផលទេ ប៉ុន្តែគឺជាទម្លាប់

ដែលគេកុហក ដូចជា ប៉ុល ពត កុហកថា បានអង្ករ៣៥០គីឡូក្នុងមួយឆ្នាំជាដើមនោះឯង។

[១៤:១៩:៣៦]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅលើបញ្ហាគោលនយោបាយ គឺក្រោយការជម្លៀសភ្លាមៗ ចំណុចចាប់ផ្ដើមដែលខ្ញុំចង់សួរទាក់ទងទៅនឹងបញ្ហានេះ គឺយើងមើលទៅលើទំព័រ២៨០។ ERN គឺមានលេខអង់គ្លេស 00396488, ភាសាបារាំងមានលេខ 00639817។ ហើយលោករៀបរាប់ដូចតទៅនេះ "ការជម្លៀសចេញពីទីក្រុងភ្នំពេញគឺមានផលប៉ះពាល់ភ្លាមៗ ការបញ្ជូនប្រជាជនទៅទីជនបទ ការសម្លាប់នៅកម្មាភិបាលចាស់ មន្ត្រីចាស់ ក៏ដូចជាការប្រព្រឹត្តចំពោះប្រជាជន គឺមានលក្ខណៈសាហាវធ្ងន់ធ្ងរ គឺវាហាក់ដូចជាអ្វីមួយដែលបណ្ដាលឲ្យមានហេតុការណ៍ដ៏អាក្រក់ក្នុងរយៈពេល៣ឆ្នាំ ៨ខែ និង ២០ថ្ងៃនោះឯង គឺជាគំរូដ៏អាក្រក់មួយ។ អ្នករស់នៅទីក្រុងភាគច្រើនគាត់មានការភ្ញាក់ផ្អើល ហើយចំពោះប្រជាជនដែលនៅខាងក្រៅប្រទេសវិញ គឺគេចាប់អារម្មណ៍ពីប្រទេសកម្ពុជា។ អ្វីដែលកើតឡើងនៅថ្ងៃ ១៧ មេសា ឆ្នាំ៧៥ហ្នឹង គឺជាគោលនយោបាយដែលបន្តពីឆ្នាំ៦០។ ហើយពេលខ្លះ វាហាក់ដូចជាលក្ខណៈដំបូងដូច្នេះដែរ។ នេះគឺជាចំណុចមួយដែលគេបញ្ជាក់។ ដូច្នេះ ខ្ញុំចង់សួរលោកបន្ថែមថា សូមលោកមេត្តាពន្យល់បង្ហាញអំពីគោលគំនិតទាំងអស់នេះ គឺគោលគំនិតនៃការជម្លៀសប្រជាជន ក៏ដូចជាផលវិបាកនៃការជម្លៀស ហើយនិងគំរូដែលកើតឡើងនៅក្នុងរយៈពេលបន្តបន្ទាប់មកនៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ?

[១៤:២១:៣៧]

**ឆ៖** ខ្ញុំគិតថាមូលដ្ឋាននៃការបង្កើតនូវគំនិតទាំងអស់នេះ គឺការមិនអាណិតអាសូរ ហើយនិងការមិនយកចិត្តទុកដាក់ ឬក៏ការមិនផ្ដល់តម្លៃទៅដល់មនុស្សដែលបង្ហាញទាំងអស់នេះគឺកើតឡើងនៅក្នុងពេលជម្លៀសប្រជាជន។ ហើយក្រោយមកទៀតនៅក្នុងសហករណ៍ គឺដូចគ្នាគឺមានលក្ខណៈដូចគ្នាដែលគេប្រព្រឹត្តចំពោះប្រជាជន គឺថាខ្មែរក្រហមចង់ទទួលបាននូវគោលដៅមួយដែលគេចង់បាន គឺការបណ្ដេញប្រជាជនរាប់លាននាក់ចេញពីទីក្រុងទៅជនបទ ហើយបង្កើតនូវសហករណ៍កសិកម្មជាសមូហភាពដើម្បីឲ្យពួកគាត់អាចផលិតស្រូវទៅតាមផែនការកំណត់ ការបង្កើតប្រព័ន្ធធារាសាស្ត្រ និងការបង្កើតបញ្ហាប្រព័ន្ធផ្សេងៗហ្នឹង គឺថាបណ្ដាលឲ្យមានការស្លាប់ប្រជាជនជាច្រើននៅពេលអនុវត្តផែនការទាំងអស់នេះ។ ដូច្នេះយើងកំណត់អំពីបញ្ហាទាំងអស់នេះ ប៉ុន្តែអ្វីដែលយើងឃើញនៅពេលដំបូងគឺការជម្លៀសប្រជាជនចេញពីទីក្រុងនោះ។

**សៈ** ប្រសិនបើយើងព្យាយាមគិតអំពីទស្សនៈនេះជាមួយនឹងអត្ថបទដកស្រង់មួយទៀត ដែលវាមានលក្ខណៈប្រហាក់ប្រហែលគ្នាហ្នឹងគឺនៅទំព័រ៣៩៩ នៅចុងសៀវភៅរបស់លោក គឺនិយាយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ និងការរត់គេចចេញពីទីក្រុងភ្នំពេញរបស់ ប៉ុល ពត, នួន ជា, ខៀវ សំផន និងអ្នកដទៃទៀតនោះ។ នេះគឺជាផ្នែកដែលខ្ញុំចាប់អារម្មណ៍គឺភាសាអង់គ្លេសមានលេខ 00396670, បារាំងមានលេខ 00639976។ ហើយខ្ញុំចាប់អារម្មណ៍ទៅលើឃ្លាដូចតទៅនេះ គោលនយោបាយរបស់ខ្មែរក្រហមគឺត្រូវបានអនុវត្តរហូតទៅដល់នាទីចុងក្រោយដូចដែលបានធ្វើពីមុនមក។ ការអាទិភាព គឺដើម្បីបញ្ជូនឲ្យសម្តេចសីហនុទៅដល់កន្លែងមានសុវត្ថិភាព ហើយការពារ ប៉ុល ពត ហើយនិងជួយដល់ នួន ជា។ ប្រសិនបើបាត់បង់សមាជិក មិនបញ្ហាទេ ប៉ុន្តែប្រសិនបើយើងរក្សាឲ្យបាននូវមេដឹកនាំ គឺយើងអាចបន្តទៅមុខទៀតបាន។

[១៤:២៤:១១]

ដូច្នេះហើយ ការអនុវត្តចំពោះប្រជាជន គឺធ្វើដូចគ្នាតាំងពីពេលជម្លៀសដំបូងរហូតមកដល់ពេលដែលខ្មែរក្រហមដួលរលំនេះ។ ដូច្នេះ ខ្ញុំចង់ដឹងថាតើលោកទទួលបាននូវការសន្និដ្ឋានដូចគ្នា ឬមួយក៏យ៉ាងម៉េចដែរ?

**ឆៈ** បញ្ហាសំខាន់គឺថា គឺគេមិនខ្វល់ពីប្រជាជនទេ គឺប្រជាជនមានអីកើតឡើងក៏កើតទៅ។ ប៉ុន្តែបញ្ហាសំខាន់គឺថា គឺធ្វើយ៉ាងណាដើម្បីកៀរប្រជាជនឲ្យផុតពីការគ្រប់គ្រងរបស់ខ្មាំង។ ដូច្នេះ វាហាក់ដូចជាមានបញ្ហាមួយបន្តិចទៅលើចំណុចនេះ។ គឺថានៅត្រង់ចំណុចនេះ គឺនៅពេលដែលគេព្យាយាមដណ្តើមអំណាចឆ្នាំ៧៣-៧៤ ពេលនោះគេដឹងថាពួកគេត្រូវការប្រជាជន។ ប៉ុន្តែចំពោះហេតុផលដ៏ពិបាកយល់ គឺថានៅពេលដែលពួកខ្មែរក្រហម គេទទួលបានអំណាច គឺគេលែងចាប់អារម្មណ៍ពីការទុកប្រជាជនទៀតហើយ គឺថាគេអាចបោះចោលប្រជាជន ឬក៏យកប្រជាជនទៅធ្វើអីក៏បានតាមចិត្ត។ បានន័យថារដ្ឋាភិបាល ឬក៏របបនោះ គេលែងខ្វល់ពីប្រជាជនទៀតហើយ។

**សៈ** ខ្ញុំចង់លើកយកនូវចំណុចមួយទៀត គឺពាក់ព័ន្ធទៅនឹងហេតុការណ៍ឆ្នាំ៧៥ ដែលជាលទ្ធផលនៃការបង្កើតគោលនយោបាយនោះ។ ខ្ញុំចង់ឲ្យលោកពន្យល់ ឬក៏ពង្រីកបន្ថែមទៅលើបញ្ហាទាំងអស់នេះ គឺពាក់ព័ន្ធទៅលើអ្វីដែលយើងបានពិភាក្សាពីព្រឹកមិញ ទាក់ទងទៅនឹងការវិវត្ត ឬក៏ការីកចម្រើនទៅមុខរបស់គោលនយោបាយនោះ។

[១៤:២៥:៥៦]

**ឆ៖** គឺថាវាមាននូវនិន្នាការពីរដែលយើងបានពិភាក្សាគឺនិន្នាការឥស្សរៈ ហើយនិងក្រុមនិស្សិតមកពីបរទេស។ ខ្ញុំគិតថាប្រភពដើមគឺវាកើតឡើងមុន គឺនៅក្រុមឥស្សរៈ ហើយវាមានការដូចគ្នា ឬក៏មានលក្ខណៈប្រហាក់ប្រហែលគ្នារវាងការដំណើរការរបស់ក្រុមខ្មែរឥស្សរៈ ហើយនិងក្រុមខ្មែរក្រហមនោះ។ ចាប់តាំងពីឆ្នាំ១៩៦០មក គឺមានក្រុមនិស្សិតមកពីបរទេស ដែលគេចាប់ផ្តើមទទួលការគ្រប់គ្រងអំណាច ហើយវាមានការរីកចម្រើនទៅមុខ ដូចដែលយើងបានពិភាក្សាពីមុនរួចមកហើយ។

**ស៖** លោកបានពិភាក្សារួចមកហើយអំពីរដ្ឋទាសករនោះ។ ដូច្នេះ ខ្ញុំចង់និយាយអំពីរដ្ឋជាទាសករនេះដែរ។ គឺនៅទំព័រ២៩១ ហើយមានលេខ ERN ភាសាអង់គ្លេសមានលេខ 00396499, ភាសាបារាំងមានលេខ 00639831។ “មានលក្ខណៈជាទាសករពិតប្រាកដអ៊ីចឹង គឺថាប្រជាជនដែលរស់នៅក្នុងរបបខ្មែរក្រហមត្រូវបានគេដកចេញនូវសិទ្ធិទាំងអស់ គឺប្រជាជនមិនអាចមានសិទ្ធិសម្រេចថាតើត្រូវហូបអីរស់នៅបែបណា រៀបការជាមួយអ្នកណានោះទេ”។ ហើយនៅខាងក្រោមបន្តិច លោកបាននិយាយដូចតទៅនេះ “វាជាការពិតផងដែរ ដែលថាប្រព័ន្ធថ្មីហ្នឹង គឺថាត្រូវបានបកស្រាយផ្សេងៗគ្នានៅតាមតំបន់និងនៅតាមភូមិភាគខុសៗគ្នា។ ហើយនៅតាមតំបន់មួយចំនួន កម្មាភិបាលខ្លះគាត់មានលក្ខណៈធូររលុងចំណែកនៅតំបន់ខ្លះកម្មាភិបាលមានលក្ខណៈតឹងតែង។ ដូច្នេះ ប្រជាជនដែលរស់នៅក្នុងភូមិភាគ ឬក៏តំបន់នីមួយៗត្រូវតែទ្រាំទទួលរងទាំងការតឹងរ៉ឹង ក៏ដូចជាការធូររលុងរបស់កម្មាភិបាល។

[១៤:២៨:១៧]

ដូច្នេះហើយយើងគិតជាលក្ខណៈជារួម ទោះបីថាវាមានភាពខុសគ្នាក៏ដោយ ប៉ុន្តែលោកហាក់ដូចជារៀបរាប់ផងដែរថា វាមានជាប្រព័ន្ធមួយដែលគេបញ្ជូន ឬក៏ដោយគេបញ្ជាពីខាងលើ ហើយត្រូវអនុវត្តនៅថ្នាក់ក្រោម”។ តើលោកអាចពន្យល់ខ្ញុំបានទេ អំពីបញ្ហានេះ?

**ឆ៖** គឺអាចថាមានការបញ្ជា ឬក៏ចេញពីខាងលើ ប៉ុន្តែយ៉ាងណាក៏ដោយ វាមានគោលការណ៍ជារួមដែលត្រូវអនុវត្តនៅគ្រប់ទីកន្លែង។ គឺថាភាគច្រើនបំផុតនៃប្រជាជន វាអាចមានករណីលើកលែងខ្លះចំពោះក្រុមមួយចំនួនតូច ប៉ុន្តែការលើកលែងហ្នឹង គឺក្រុមតូចតាចទេ។ គឺថាអាចថាមានក្រុមមួយចំនួនតូចដែលគាត់មានសិទ្ធិ មានអាទិភាពអីផ្សេងៗនេះ ប៉ុន្តែ៩៩ភាគរយនៃប្រជាជនគឺមានស្ថានភាពដូចគ្នា។ ត្រូវបានគេចាត់ទុកថាជាទាសករ។ គឺថាជាទាសករដែលមិនមានសេរីភាពអ្វីទាំងអស់ ទាំងនៅក្នុងការរស់នៅ ក៏ដូចជាការងារផ្សេងៗ។

[១៤:២៩:២២]

ប្រសិនបើមនុស្សទាំងអស់គ្នាជាទាសករ ប្រហែលជាចាំបាច់ត្រូវតែមានម្ចាស់ទាសករ អាចថាម្ចាស់ទាសករខ្លះ គាត់តឹងតែង ម្ចាស់ទាសករខ្លះគាត់មានលក្ខណៈធូររលុងបន្តិចបន្តួចអ៊ីចឹងទៅ។ ដូច្នេះវាអាចថាប្រែប្រួលទៅតាមភូមិ ឬក៏ទៅតាមតំបន់។ ប៉ុន្តែយើងមិនអាចនិយាយបានថា នៅក្នុងសហករណ៍ដែលឆ្ងាយពីគ្នាប្អូនប្រាំគីឡូនៅក្នុងតំបន់ នៅក្នុងភូមិភាគតែមួយហ្នឹងមានលក្ខណៈខុសគ្នា គឺវាមិនអាចទៅរួចនោះទេ។ ប៉ុន្តែទោះបីថាមេដឹកនាំ ឬក៏មេទាសករហ្នឹងគាត់តឹងតែង ឬក៏ធូររលុងទៅហើយក៏ដោយ ក៏ប្រជាជននៅតែមានលក្ខណៈជាទាសករដូចគ្នា។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងមើលទៅរកអ្វីដែលលោករៀបរាប់ថាជាវិធីសាស្ត្រ ដើម្បីឈានបានសេដ្ឋកិច្ចមួយ ដែលជាផ្នែកមួយនៃនយោបាយរបស់គេ ដែលលោកពិភាក្សានោះ។ ផ្នែកនេះចាប់ផ្ដើមទំព័រ២៩៣ បន្តដល់ ២៩៤។ ERN អង់គ្លេសនោះ គឺ 00396501 ដល់ 02, បារាំង ERN 00639833 ដល់ 85។ លោកបាននិយាយដូចខាងក្រោមនេះ សូមដកស្រង់ "ជំហានដំបូង ការបំផ្លាញពួកសក្តិភូមិគឺជាសំខាន់ណាស់ តាមទស្សនៈបដិវត្ត ហើយគឺត្រូវបានសម្រេចដោយបក្សកុម្មុយនីស្ត និងការជម្លៀសទីក្រុង។ ជំហានទីពីរ និងទីបី គឺដើម្បីកសាង ការពារ ហើយនិងកៀងគរ គឺថាប្រមូលប្រជាជនទូទាំងប្រទេស ដើម្បីឈានឲ្យបានលឿនទៅមុខ ដើម្បីកម្ចាត់ខ្មាំងផ្ទៃក្នុង ហើយនិងថៃ និងប្រទេសវៀតណាម"។ ជាការពិចារណាចុងក្រោយ នេះជាចំណុចសំខាន់។

[១៤:៣១:៤៨]

នៅលើទំព័រនេះ គឺជាសេចក្ដីដកស្រង់មួយ ដែលចាប់ផ្ដើមនិយាយថា "ទីមួយ ជាសេចក្ដីផ្ដើមបន្ទាប់មកគឺនិយាយអំពី ប៉ុល ពត។ សេដ្ឋកិច្ច ជាសមរភូមិមួយដែលត្រូវឲ្យមានផ្តែផ្កា"។ សូមបញ្ចប់សេចក្ដីដកស្រង់។

"តើយើងត្រូវធ្វើសកម្មភាពដូចម្ដេច? ដូចសង្គ្រាមដែរយើងលើកឡើងពីការវាយប្រហារនៅពេលខ្មាំងខ្សោយ។ បើយើងនិយាយពីសេដ្ឋកិច្ច ការវាយប្រហារ កាលណាមានឱកាស យើងត្រូវតែធ្វើការវាយសម្រុកទូទាំងប្រទេស។ យើងរៀនពីសង្គ្រាម ប្រសិនបើយើងបញ្ជាខ្លាំង យើងឈ្នះ។ ប្រសិនបើការបញ្ជាខ្សោយ យើងមិនឈ្នះទេ។ ដូចគ្នា នឹងការកសាងសេដ្ឋកិច្ចដែរ"។ ខ្ញុំឲ្យលោកពន្យល់បន្ថែមពីរឿងនេះ គឺថាសេចក្ដីរៀបរាប់របស់លោកនេះ ដូចជាមានវិធានការ ការរៀបរាប់ជាពាក្យយោធា។ ប៉ុន្តែការប្រើពាក្យថា "ផ្តែផ្កា" ទាក់ទងទៅនឹងកម្លាំងសំខាន់នេះ សេដ្ឋកិច្ចនេះ តើវាមានន័យដូចម្ដេចកម្លាំងរុញច្រាននេះ?

[១៤:៣២:៥៥]

**ឆៈ** ខ្ញុំមិនប្រាកដថា ខ្ញុំអាចបំភ្លឺឲ្យលើសពីហ្នឹង ច្រើនប៉ុនណានោះទេ។ ដំណាក់កាលដំបូងនៃសហភាពសូវៀត អំពីសង្គ្រាម ហើយនិងលិទ្ធកុម្មុយនីស្តនោះគឺថាវាមានវិធីសាស្ត្រស្រដៀងគ្នា។ ពួកគេព្យាយាមឲ្យលឿនបំផុត ស្តាលីន គាត់មានកម្មវិធីឧស្សាហកម្មរបស់គាត់នោះ គឺថាស្រដៀងនោះដែរ។ ប៉ុន្តែមានអ្វីពីមុន ដែលគេអាចយកជាគំរូ ដូចជា មានសម្ពាធពីក្នុង នៅក្នុងរបបរបស់គេ ដូចជា បក្សកុម្មុយនីស្តកម្ពុជាក៏ឃើញដូច្នោះដែរ វាមានសម្ពាធ ហើយដូចជា ពិសេសមកពីវៀតណាមជាជាងនៅប្រទេសថៃ។ ហើយក៏គេមានការភ័យខ្លាច ហើយគឺថាលទ្ធផលវាបង្ហាញអំពីវិធី ហើយវិធីនេះហើយដែលអាចធ្វើឲ្យគេសម្រេចផលបានឆាប់បំផុតនោះ។ នេះហើយ គឺមានសម្ពាធពីខាងក្រៅ។ បន្ទាប់ពីជោគជ័យរបស់គេនោះ គឺថាដោយមានភាពអំនួត ដូចដែល អៀង សារី និយាយថា យើងបានធ្វើល្អណាស់ដែលប្រទេសណាផ្សេងៗមិនបានធ្វើអ៊ីចឹងទេ។ ហើយការជឿជាក់បែបនេះ គេអាចធ្វើអ្វីៗ ដែលគេមិនអាចធ្វើបាន។ ដូច្នេះហើយ គេយល់ថា គេអាចជំរុញប្រជាជនឲ្យធ្វើអ្វីដែលគេមិនអាចធ្វើ ដែលថាអាចធ្វើឲ្យមានការបាត់បង់ជីវិត១លានប្រាំពីរសែនអីជាដើម។ ហ្នឹង ជាលទ្ធផល។

[១៤:៣៤:៣៥]

**សៈ** សូមលោកសម្តែងយោបល់ទាក់ទងទៅនឹងបញ្ហានេះ ថាតើការភ័យខ្លាចរបស់វៀតណាមតើជាកត្តាធ្វើឲ្យធ្វើការពិចារណា ដើម្បីធ្វើសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ដែលថាគេខ្លាចវៀតណាម បានជាគេសម្រេចបែបនេះ បែបនោះ?

**ឆៈ** ខ្ញុំគិតថានេះជាកត្តាសំខាន់គឺថា តាមពិតទៅគឺគេមានយុត្តិកម្ម ដែលថាគេត្រូវតែដើរឲ្យលឿនបំផុតដែលគេអាចធ្វើទៅបាន ដែលថាដើម្បីកុំឲ្យវៀតណាមតាមទាន់។ បាទ ដែលខ្ញុំគិតថានេះជាចំណុចសំខាន់ណាស់ វាផ្អែកទៅលើបរិបទដែលថា មិនមាននរណាម្នាក់អាចនឹងជំទាស់តវ៉ា មិនមាននរណាហ៊ាននិយាយតវ៉ាបានទេ ប៉ុន្តែគេអាចមានដំណោះស្រាយដែលថាគេគ្រប់គ្នា គេចង់ដើរឲ្យលឿនមហាលោតផ្លោះរបស់គេនោះឯង។

**សៈ** ផ្នែកមួយទៀតដែលខ្ញុំចង់អានសៀវភៅរបស់ ខៀវ សំផន ដែលយើងបានមើលពីខាងដើមជំពូកទី៥ ដែលបកស្រាយទៅជាភាសាបារាំង និងខ្មែរ E3/16 ជាលេខឯកសារ។ នៅអង់គ្លេស ERN 00498302, ខ្មែរ ERN 00380497 ដល់ 500 ហើយបារាំង ERN 00643909។

[១៤:៣៦:២០]

ដំបូងថា តើបញ្ហានេះនិយាយអំពីបញ្ហាមួយចំនួនដែលលោកសរសេរជាមួយក្នុងសៀវភៅរបស់លោក គឺថាវាមានការប្រណាំងប្រជែងរហូតមកដល់ឆ្នាំ១៩៧៥ ដូចជាការដណ្តើមយកទីក្រុងសៃហ្គនហើយនិងការដណ្តើមយកទីក្រុងភ្នំពេញរវាងបក្សកុម្មុយនីស្តទាំងពីរនេះ។ អ្វីដែល ខៀវ សំផន និយាយនេះសូមដកស្រង់ "ប្រសិនបើវៀតណាមរំដោះនៅខាងត្បូង មុនពេលភ្នំពេញរំដោះនោះ វៀតណាមបានរំដោះនៅខាងត្បូងមុនពេលភ្នំពេញរំដោះនោះ វាជាអាចគ្រោះថ្នាក់មួយធំ។ បន្ទាប់ពីការរំដោះ គឺថាយើងត្រូវតែរត់ម្តងទៀត គឺគ្មានការសង្ស័យទេ នេះហើយជាមូលហេតុដែល ប៉ុល ពត ត្រូវតែពង្រីកសហ-ករណ៍ទូទាំងប្រទេសដែលធ្វើឲ្យបដិវត្តន៍កម្ពុជា ៣០ឆ្នាំលឿនជាងសហករណ៍នៅចិន, នៅកូរ៉េខាងជើង និងនៅវៀតណាម"។

ដំណាក់កាលមួយទៀត សូមដកស្រង់សង្ខេប "យើងមិន -- បើមិនបានរៀបចំសហករណ៍ទេ យើងនឹងរងគ្រោះអំពីផលវិបាក អំពីស្ថានភាពផ្សេងៗដូចវៀតណាម ដូចជាការគោរពកិច្ចព្រមព្រៀងទីក្រុងប៉ារីសរវាងវៀតណាម និងអាមេរិកាំងក្នុងឆ្នាំ៦០"។ តើចំណុចទាំងអស់នេះវាឆ្លុះបញ្ចាំងពីអ្វីដែលលោករកឃើញពីការពិភាក្សាករណីវៀតណាម និងបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

[១៤:៣៧:៤៨]

**ឆ៖** ផ្នែកមួយគឺពិតហើយវាឆ្លុះបញ្ចាំងពីរឿងហ្នឹង។ ការព្រួយបារម្ភខ្លាចខាងវៀតណាមនោះអ៊ីចឹងការពិតដែលគេដណ្តើមកាន់កាប់យកភ្នំពេញមុនសៃហ្គននោះ នោះគឺថាគេត្រូវហើយ គេត្រូវតែរត់ឲ្យបានលឿន ដើម្បីប្រណាំងជាមួយវៀតណាម គេខ្លាចវៀតណាមនោះឯង។ ប៉ុន្តែមានកិច្ចព្រមព្រៀងឆ្នាំ១៩៧៣ គឺថាអាមេរិកាំងគឺថា ឃីស៊ីងហ្គ័រ ហើយនិងអ្នកផ្សេងទៀតដែលព្យាយាមជំរុញវៀតណាមខ្លាំងណាស់ដើម្បីឲ្យដកខ្លួនពីការគាំទ្រ។ ដូច្នេះហើយបើគេការបង្កើតសហករណ៍នោះគឺថា គេមានកម្លាំងទ័ពគ្រប់គ្រាន់ដើម្បីបន្តទៅហើយ។ គេអាចធ្វើសង្គ្រាមប្រឆាំង លន់ នល់ បានយោធានោះ ដោយមិនគិតប្រៀបធៀបទៅករណីដែលគេធ្វើនៅវៀតណាមនោះទេ។

**ប្រធានអង្គជំនុំ៖**

អរគុណអ្នកជំនាញ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី។ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់អ្នកជំនាញរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងអញ្ជើញគាត់មកកាន់កន្លែងផ្តល់

សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ អញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ស្សួត មុនពេលដែលយើងបន្តដំណើរការទៅមុខទៀត ដើម្បីពិនិត្យមើលទៅលើការប្រព្រឹត្តចំពោះក្រុមមនុស្សផ្សេងៗគ្នានេះ។ ខ្ញុំចង់ឲ្យលោកពិនិត្យទៅលើសេចក្តីសម្រេចមួយដែលធ្វើឡើងនៅដើមឆ្នាំ៧៥ ហើយសេចក្តីសម្រេចនេះវាអាចមានផលប៉ះពាល់ដល់ហេតុការណ៍នៅក្នុងឆ្នាំ៧៥។ គឺថា គឺជាសេចក្តីសម្រេចដែលនិយាយអំពីមន្ត្រីជាន់ខ្ពស់របស់របបសាធារណរដ្ឋ ដែលត្រឡប់មកប្រទេសកម្ពុជាវិញ គឺជាសេចក្តីសម្រេចរបស់ថ្នាក់លើ។

[១៥:០១:៤៤]

ខ្ញុំចង់ឲ្យលោកពិនិត្យមើលឯកសារដែលមាន ដែលចុះខែកុម្ភៈ ឆ្នាំ៧៥។ នេះគឺជាឯកសារដែលយើងបានបញ្ជូនទៅលោករួចទៅហើយ គឺជាឯកសារដែលបានដកចេញពីការផ្សព្វផ្សាយរបស់ ហ្វីប៊ីស គឺខែមេសា ឆ្នាំ៧៥ ឯកសារមានលេខ E3/117។ ប្រសិនបើលោកមិនទាន់មានឯកសារនេះទេ ខ្ញុំអាចបញ្ជូន -- ខ្ញុំអាចផ្តល់ឯកសារនេះជូនលោកបាន។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់នូវឯកសារនេះជូនទៅដល់លោកសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនអ្នកជំនាញ!

[១៥:០២:៣៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឯកសារមួយនេះ គឺខ្ញុំបញ្ជាក់ថា ដោយសារតែឯកសារនេះវាសរសេរមិនច្បាស់ ហើយវាមានអក្សរតូចៗទៀតផង ដូច្នេះខ្ញុំអានជូនលោកស្តាប់។ ឯកសារនេះមានលេខ 00242308 ដល់09, បារាំងមានលេខ 00281432 ហើយឯកសារមួយនេះគឺ មានចំណងជើងថា គឺចំណងជើងគេសរសេរថា “ខៀវ សំផន ធ្វើជាអធិបតីសម័យប្រជុំសមាជរបស់រណសិរ្សរួបរួមជាតិនៃកម្ពុជា” គឺជាវិទ្យុផ្សាយសំឡេងរណសិរ្សរួបរួមជាតិកម្ពុជានៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ៧៥។ ហើយខ្ញុំពិនិត្យមើលទៅលើកថាខណ្ឌមួយដែលដកស្រង់ចេញពីអត្ថបទនេះ។ ខ្ញុំសូមធ្វើការដកស្រង់ “ពាក់ព័ន្ធទៅនឹងជនក្បត់ជាតិទាំងប្រាំពីររូប គឺថាសភាបានសម្រេចដូចតទៅនេះ សមាជជាតិបានសម្រេចដូចតទៅ៖ ក្បត់ជាតិ លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង សូស្ទែន ហ្វែណង់ដែស គឺជាប្រមុខពួកក្បត់ និងជាប្រធានក្រុមធ្វើរដ្ឋប្រហារប្រឆាំងជាតិដ៏ទុរយស ដែលបានផ្តួលរំលំឯករាជ្យ សន្តិភាព និងអព្យាក្រឹត-ភាពរបស់កម្ពុជា” ហើយខ្ញុំសូមរំលងមួយកថាខណ្ឌ “ក្នុងនាមរណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា សមាជជាតិបានប្រកាសថា វាជាការចាំបាច់ជាដាច់ខាតត្រូវសម្លាប់ជនក្បត់ទាំងប្រាំពីរនាក់នេះ ចំពោះអំពើក្បត់ជាតិរបស់វា ដែលប្រឆាំងនឹងប្រជាជន និងអំពើហ្វាស៊ីសពុករលួយ ឧក្រិដ្ឋកម្មដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា”។

[១៥:០៤:៥០]

ហើយមុននឹងខ្ញុំសួរសំណួរមួយចំនួន ខ្ញុំសូមបញ្ជាក់ជាកំណត់ត្រាថា ឯកសារនេះគឺមាននៅក្នុងឯកសារមានលេខ E3/118 គឺជាលិខិតដែលបានបញ្ជូនទៅអង្គការសហប្រជាជាតិផងដែរ។ ហើយខ្ញុំសូមសង្ឃឹមថាលោកបានពិនិត្យមើលឯកសារនេះ។

ខ្ញុំគិតថានៅក្នុងសៀវភៅរបស់លោកក៏បានរៀបរាប់អំពីសមាជជាតិមួយនេះផងដែរ ដែលសមាជ

ជាតិនេះវាកើតឡើងនៅពេលនោះ។ ហេតុដូច្នេះសំណួរដែលខ្ញុំចង់សួរលោកនៅពេលនេះ គឺថាតើស្ថាប័នណាមួយ គឺស្ថាប័ននៅក្នុងចរនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា ឬក៏របស់ ហ្វូង ដែលអ្នកទទួលខុសត្រូវក្នុងការធ្វើការសម្រេចបែបនេះ។ តើលោកអាចធ្វើការសន្និដ្ឋានទៅលើបញ្ហានេះបានដែរឬទេ?

**ឆ៖** មិនមានភស្តុតាងណាមួយក្រៅពីសេចក្តីផ្សព្វផ្សាយព័ត៌មានដែលនិយាយអំពីសមាជជាតិបែបនេះទេ។ ចំពោះខ្ញុំៗគិតថាវាហាក់ដូចជាការអំពាវនាវ ឬក៏ជាការផ្ញើសារឲ្យមានការគាំទ្រដែលធ្វើឡើងដោយ ហ៊ូ នឹម, ហ៊ូ យន់, ខៀវ សំផន ដែលបញ្ជូនទៅទីក្រុងប៉េកាំង ដែលនៅទីនោះសម្តេច សីហនុបានស្នាក់នៅទីនោះ។ ដូច្នេះ នេះគឺជាឯកសារដែលអានដោយអ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះថាតើអ្នកណានៅក្នុងឋានៈថ្នាក់ហ្នឹង ថាតើឯកសារហ្នឹងរៀបចំដោយលោក ខៀវ សំផន ឬក៏អ្នកណានោះគឺវាជាការឆ្លុះបញ្ចាំងអំពីសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ឬមួយក៏ជារបស់ ប៉ុល ពត។ ធ្វើដូច្នេះដើម្បីធានាដល់អ្នកដទៃថា មានតែជនទាំងប្រាំពីររូប ដូចដែលខ្ញុំបានបញ្ជាក់នេះអ៊ីចឹងគឺថា គឺគេកម្រិតកំណត់ចំនួនមនុស្សតិចតួចប៉ុណ្ណោះ ដែលត្រូវទទួលទោសប្រហារជីវិតនោះ។ នេះគឺជាការបញ្ជាក់អំពីការដែលត្រូវសម្លាប់តែមនុស្សមួយចំនួនតូច ប្រសិនបើខ្មែរក្រហមបានឡើងកាន់អំណាច។

[១៥:០៧:១២]

**ស៖** ពីដើម គឺយើងបានឃើញនៅក្នុងសៀវភៅរបស់លោកដែលបានសរសេររៀបរាប់ ដែលនិយាយយោងទៅដល់ការសម្លាប់ ឡុង បូរ៉េត។ ឯកសារនោះ គឺជាសេចក្តីប្រកាសដែលចុះហត្ថលេខាដោយ ខៀវ សំផន។ លោកដឹងដែរឬទេថា មានសេចក្តីសម្រេចដែលមានលក្ខណៈផ្លូវការមួយដែលជាការទំនាក់ទំនងនៅក្នុងឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា។ ថាតើលោកអាចបង្ហាញបានដែរទេ ថាធ្លាប់មានឯកសារផ្លូវការណាមួយតាមការស្រាវជ្រាវរបស់លោក?

**ឆ៖** ការដែលថាឯកសារនេះត្រូវបានផ្សព្វផ្សាយដោយស្ថានីយ៍វិទ្យុ វាគឺជាការផ្សព្វផ្សាយព័ត៌មានរួចទៅហើយ។ ដូច្នេះហើយវាជាការផ្សព្វផ្សាយឲ្យដឹង។ ប៉ុន្តែយើងមិនដឹងថាតើអ្នកណាជាអ្នកសម្រេច? ថាតើអ្នកណាជាអ្នកអនុម័តទៅលើឯកសារនេះ? ហើយយើងក៏មិនដឹងផងដែរ ថាតើលោក ខៀវ សំផនគ្រាន់តែត្រូវបានគេយកឈ្មោះមកប្រើប្រាស់មួយ ឬមួយក៏គាត់ជាអ្នកផ្តួចផ្តើម ឬមួយក៏គ្រាន់តែជាអ្នកដែលជានិមិត្តរូបរបស់មេដឹកនាំនោះ យើងមិនដឹងច្បាស់នោះទេ។

[១៥:០៨:៤២]

**ស៖** ខ្ញុំមានសំណួរមួយទាក់ទងទៅនឹង ខៀវ សំផន ដោយផ្ទាល់។ នៅក្នុងការស្រាវជ្រាវរបស់

លោក តើលោកធ្លាប់ជួបប្រទះនូវភស្តុតាងណាមួយដែលបង្ហាញថា គាត់ធ្លាប់មានការខ្វែងយោបល់ ឬក៏ធ្លាប់មានការមិនឯកភាព ការដកខ្លួនចេញពីការសម្រេចណាមួយដែរឬទេ?

**ឆ៖** អត់ទេ អត់ដែលមានទេ។ ហើយខ្ញុំប្រាកដថាគាត់មិនដែលដកខ្លួនចេញ ឬក៏មិនដែលខ្វែងយោបល់ជាមួយនឹងអ្នកណាម្នាក់នោះទេនៅក្នុងការធ្វើសេចក្តីសម្រេច ក៏ដូចជាការទាក់ទងគ្នានានា។

[១៥:០៩:១៩]

**ស៖** សូមអរគុណលោកសាក្សី។ ឯកសារទំនាក់ទំនងនេះក៏បានបង្ហាញផងដែរថា មន្ត្រីជាន់ទាបមួយនានាទៀត គឺត្រូវបានស្វាគមន៍ ហើយទទួលបានសិទ្ធិពេញលេញក្នុងការចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ប្រសិនបើគេបញ្ឈប់ការសហការជាមួយនឹងជនក្បត់ទាំងប្រាំពីររូបនោះ។ ថាតើមានការរារាំង ឬក៏ការជំទាស់ទៅនឹងការអនុវត្តគោលនយោបាយបែបនេះដែរឬទេ គឺថានៅចំពោះខាងខ្មែរក្រហម តើមានការជំទាស់រារាំងការអនុវត្តគោលនយោបាយបែបនេះដែរឬទេ?

**ឆ៖** តាមដែលខ្ញុំដឹង គឺថាមិនមានភស្តុតាងបង្ហាញថា អត់មានជំទាស់ ឬក៏អត់មានការខ្វែងយោបល់គ្នាកើតឡើងនោះទេ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់ធ្វើការពិនិត្យទៅលើឯកសារមួយ ដែលជាការបំបែកពួកសក្តិភូមិ ហើយយើងអាចនឹងពិភាក្សាគ្នាអំពីបញ្ហាពួកសក្តិភូមិនេះ ដោយយើងពិនិត្យមើលទៅលើឯកសារមួយចំនួន។ ឯកសារទីមួយគឺជាទស្សនាវដ្តីទង់បដិវត្ត ដែលចុះផ្សាយនៅខែ៨ ឆ្នាំ៧៥។ ប៉ុន្តែលោកអាចពិនិត្យមើលឯកសារនោះបាន ប៉ុន្តែតាមដែលខ្ញុំដឹង គឺលោកបានដកស្រង់ឯកសារនេះ នៅក្នុងសៀវភៅរបស់លោក គឺនៅក្នុងទំព័រ៣៤១ នៃសៀវភៅរបស់លោក លោកក៏បានដកស្រង់។ ខ្ញុំមានឯកសារទង់បដិវត្តនេះសម្រាប់លោក។

ដូច្នេះ លោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រគល់ឯកសារនេះ គឺឯកសារ E3/5 ដែលជាទស្សនាវដ្តីទង់បដិវត្ត ចុះខែ៨ ឆ្នាំ៧៥។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតដើម្បីប្រគល់ឯកសារនេះ ជូនទៅអ្នកជំនាញ។

[១៥:១១:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនអ្នកជំនាញពិនិត្យ!

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** ឥឡូវនេះ យើងពិនិត្យទៅលើទស្សនៈនៃទស្សនាវដ្ដីទង់បដិវត្តបាននិយាយយោងទាក់ទងទៅនឹងអ្នកដែលគេចាត់ទុកថាជាអធន ឬក៏ពួកសក្ដិភូមិនោះ។ ឯកសារមានលេខ 00063321, បារាំងមានលេខ 00538961, អង់គ្លេស 00401486។ គឺទំព័រ១១ នៃឯកសារជាភាសាអង់គ្លេស សូមលោកពិនិត្យមើល។ នេះគឺជាឃ្លាមួយដែលវែង ហើយខ្ញុំសូមអាននូវការដកស្រង់មួយចំនួន។ នៅទំព័រទី៣ គឺយើងនិយាយអំពីប្រភេទនៃកម្មសិទ្ធឯកជន។ ហើយការ -- ឯកសារបានបញ្ជាក់ថា ត្រូវឲ្យដកហូតមកជាកម្មសិទ្ធរបស់រដ្ឋ ហើយនិងត្រូវបានដកហូតមកជាកម្មសិទ្ធរបស់សមូហភាព។

[១៥:១៣:០៧]

"ដោយសារតែមិនមានកម្លាំង ដោយសារតែមិនមានអំណាច ដូច្នេះប្រជាជនមិនអាចជំទាស់បាននោះទេ។ ដោយសារតែយើងមិនផ្ដល់ឱកាសឲ្យមានការចំណាយ។ ដូច្នេះ គឺយើងធ្វើឡើងដោយមិនមានបរាជ័យនោះឡើយ នៅពេលដែលពួកចាកចេញពីទីក្រុងភ្នំពេញ គឺគេបានបាត់បង់នូវអំណាចរបស់គេអស់ទៅហើយ"។ ហើយនៅចំណុចទី៤ បាននិយាយថា អំពីឋានៈ ឬក៏អំពីក្រុមនៅក្នុងប្រទេសកម្ពុជា ហើយនិងការផ្ដួលរំលំ ដែលវាស្របទៅនឹងអ្វីដែលលោកបានប្រាប់យើងរួចមកហើយ ហើយនៅក្រោមបន្តិចទៀតនោះ "ឥឡូវនេះ គឺពួកសក្ដិភូមិ ពួកអាណានិគមត្រូវបានផ្ដួលរំលំ ហើយពួកម្ចាស់ដី ក៏ដូចជាពួកសក្ដិភូមិ ពួកអនុធន ត្រូវបានគេបំបាត់ចោល ហើយពួកគេត្រូវបានកែប្រែទៅជាកសិករ។ បុគ្គលទាំងអស់នេះ គឺជាកសិករថ្មីដែលមកពីវណ្ណៈអធន ហើយនិងមកពីវណ្ណៈសក្ដិភូមិ។ ក្រុមរបស់ពួកគេត្រូវបានលុបបំបាត់ចោល ហើយមូលដ្ឋានសេដ្ឋកិច្ចត្រូវបានផ្ដួលរំលំចោល ប៉ុន្តែការចង់បាន និងការប៉ងប្រាថ្នារបស់ពួកគេ នៅតែដូចគ្នា។ ពួកគេមិនមានការជំទាស់ជាមួយនឹងបដិវត្តន៍នោះទេ"។

ខ្ញុំចាប់អារម្មណ៍ទៅលើបញ្ហាចុងក្រោយ អំពីការដួលរំលំនៃវណ្ណៈទាំងអស់នេះ។ តើលោកអាចពន្យល់បន្ថែមអំពីចំណុចនេះបានទេ?

[១៥:១៤:៤៥]

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** ហេតុដូច្នេះហើយ នេះគឺជាមូលហេតុដែលគេត្រូវបញ្ជូនប្រជាជន ឬក៏ជម្លៀសប្រជាជន

ទៅតាមទីជនបទ ដើម្បីធ្វើការអប់រំ ឬដូចធ្វើការកែប្រែផ្នត់គំនិតរបស់ពួកគេ។ នេះគឺជាគោលគំនិតមួយដែលធ្វើឡើងនៅប្រទេសចិន មិនមែនជាគោលគំនិតថ្មីនោះទេ។ គឺនៅចិនក៏គេបញ្ជូនប្រជាជនទៅជំរំកសិកម្ម ឬក៏ជំរំប្រមូលផ្តុំទៅតាមទីជនបទផងដែរ។ ប៉ុន្តែអ្វីដែលលោកបានអានហ្នឹង គឺវាបានបញ្ជាក់ច្បាស់អំពីការបំបែក ឬក៏ការលុបបំបាត់នូវបណ្តាញទំនាក់ទំនងរបស់ប្រជាជននៅក្នុងទីក្រុង ក៏ដូចជារបបជំនាន់របបចាស់ផងដែរ។ ដូច្នេះ ចំណុចសំខាន់គឺការលុបបំបាត់ចោលនូវកម្មសិទ្ធិឯកជន នូវបញ្ហាឯកជនទាំងអស់នេះ។ ខ្ញុំគិតថាអ្វីដែលយើងបានពិភាក្សា គឺវាបានឆ្លើយនៅក្នុងចម្លើយមុនរួចមកហើយ។

ទោះបីថាសេចក្តីសម្រេចត្រូវបានប្រកាសថាមានតែជនក្បត់ប្រាំពីររូបត្រូវបានសម្លាប់ ចំណែកអ្នកដទៃមិនត្រូវបានសម្លាប់ ដែលការប្រកាសនេះជាការធានាក៏ដោយ ក៏ប៉ុន្តែនៅឃ្លាចុងក្រោយ វាមានលក្ខខណ្ឌមួយដែលបាននិយាយថា "អ្នកដទៃទៀតគឺត្រូវបានស្វាគមន៍លុះត្រាតែពួកគាត់ហ្នឹងបញ្ឈប់នូវការសហការ ឬក៏ការជួយទៅដល់អ្នកក្បត់ទាំងប្រាំពីររូបនោះ"។

[១៥:១៦:១៤]

**ស៖** សូមអរគុណលោកអ្នកជំនាញដែលបានផ្តល់នូវការបញ្ជាក់បំភ្លឺនេះ។ ហើយចំពោះបញ្ហានៃវណ្ណៈមួយនេះផងដែរ ឥឡូវនេះយើងមើលទៅលើទស្សនាវដ្តីទង់បដិវត្តខែកក្កដា ឆ្នាំ៧៦ E3/4 នេះគឺជាឯកសារដែលខ្ញុំបញ្ជូនទៅលោករួចមកហើយ។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រគល់ឯកសារនេះជូនទៅដល់លោក ហ្វីលីព ស្សូត ដើម្បីឲ្យគាត់ពិនិត្យ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការប្រគល់ឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនអ្នកជំនាញពិនិត្យ!

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនអ្នកជំនាញ)*

[១៥:១៧:០៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឯកសារនេះមានលេខ 00062911 ដល់ 12, ភាសាបារាំងមានលេខ 00349973 និងភាសាអង់គ្លេសមានលេខ 00268918 “ដើម្បីក្លាយជាសង្គមនិយមបានទាល់តែតស៊ូវណ្ណៈ រវាងវណ្ណៈកម្មករ និងវណ្ណៈដទៃទៀត។ ប្រសិនបើគ្មានផ្តាច់ការវណ្ណៈកម្មករលើវណ្ណៈផ្សេងទៀតទេ សង្គមនិយមកសាងមិនបានទេ។ បើមិនផ្តាច់ការវណ្ណៈទេ ខ្មាំងវាវាយយើង”។ ហើយក្រោមនេះបន្តិច គឺគេលើកឧទាហរណ៍។ “ឧទាហរណ៍ យើងកំពុងកសាងសង្គមនិយមនៅក្នុងសហករណ៍ បើកាលណាយើងប្រហែស បើកាលណាយើងធូររលុងអំពីបដិវត្តន៍សង្គមនិយម បើកាលណាយើងធូររលុងអំពីផ្តាច់ការវណ្ណៈអធន វាមុខតែវាយយើង។ បើយើងឲ្យសេរីភាពទៅវា វាមុខតែវាយយើងបាន”។ ហើយក៏បានរៀបរាប់បន្តបន្ទាប់ទៅមុខទៀត ខ្ញុំនឹងមិនអានទេដោយសារយើងមិនមានពេលវេលាគ្រប់គ្រាន់។ តើលោកអាចបញ្ជាក់អំពីការ -- អំពីសេចក្តីសន្និដ្ឋានមួយ ថាតើហេតុអ្វីបានជាគោលនយោបាយហ្នឹងហាក់ដូចជាផ្តោតតែទៅលើខ្មាំង វាយតម្លៃ ក៏ដូចជាការដែលតស៊ូវណ្ណៈរវាងវណ្ណៈកម្មករ និងវណ្ណៈដទៃទៀតហ្នឹង។ តើលោកអាចពន្យល់បានដែរឬទេអំពីបញ្ហានេះ?

[១៥:១៩:០២]

**ឆ៖** នេះគឺមិនមែនជាលក្ខណៈមួយដែលមានតែពិសេសចំពោះកម្ពុជាប្រជាធិបតេយ្យនោះទេ សូម្បីតែរបប ម៉ៅ សេទុង នៅប្រទេសចិន នៅក្នុងរបបទាំងអស់នោះគឺចាប់តាំងពីឆ្នាំ៤៩ បន្តមក គឺថារហូតដល់ពេលដែល ម៉ៅ សេទុង ស្លាប់ក៏ដោយក៏គំនិតនៃការតស៊ូវណ្ណៈវានៅតែមាន ដែលថាវណ្ណៈអធនបានកើនឡើង ហើយចំណែកវណ្ណៈសក្តិភូមិវាបន្តធ្លាក់ចុះជាដើម។ នេះគឺជាបញ្ហាដែលកើតឡើងនៅប្រទេសចិន។ ហើយបញ្ហាដូចគ្នាគឺថា ប៉ុល ពត គាត់ទទួលបានគំនិតទាំងអស់នៅពេលដែលគាត់សិក្សានៅប្រទេសបារាំង ហើយក៏គាត់ទទួលបានគោលគំនិតនេះពីស្តាលីនផងដែរ។ គឺបានន័យថា បញ្ហាសំខាន់គឺដែលគេនិយាយអំពីថា “ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង” នោះគឺពួកកុម្មុយនីស្តក៏តែងតែព្រួយបារម្ភថាអាចដោយសារតែមានការពុករលួយអំពីថ្នាក់ដឹកនាំនៅក្នុងបក្សកុម្មុយនីស្តតែម្តង។ ប៉ុន្តែអ្វីដែលយើងឃើញថាជាលក្ខណៈពិសេសរបស់កម្ពុជានៅពេលនោះ គឺថាគេលើតម្កើងវណ្ណៈកម្មករ គឺឲ្យវណ្ណៈកម្មករហ្នឹងវាខ្ពស់ជាងវណ្ណៈដទៃទៀត។ ខ្ញុំចាំថាខ្ញុំធ្លាប់ពិភាក្សាជាមួយលោក ខៀវ សំផន។ ប៉ុន្តែខ្ញុំគិតថាប្រហែលជាតុលាការមិនចង់ស្តាប់អំពីបញ្ហានេះទេ ប៉ុន្តែអ្វីដែលចង់និយាយគឺវណ្ណៈអធន។ គាត់មិនអាចបញ្ចុះបញ្ចូលខ្ញុំបាន ហើយខ្ញុំក៏មិនអាចបញ្ចុះបញ្ចូលលោក ខៀវ សំផន បានដែរនៅពេលនោះ។ ប៉ុន្តែគឺ

យើងចង់និយាយថា ការសហការរវាងបញ្ញាជន និងកសិករ ដែលពួកគាត់តែងតែចាត់ទុកថាពួកវណ្ណៈពួកបញ្ញវន្តហ្នឹង គឺយល់អំពីកម្មករ ពីកសិករ ហើយជាការជួយដល់អ្នកដទៃទៀតនោះ។ ទោះបីថាវណ្ណៈអធន គាត់មានការកើនឡើងក៏ដោយ ធម្មតាក៏មានការបន្ថយទៅវិញដែរ។

[១៥:២១:០៩]

**សៈ** សូមអរគុណលោក។ ឥឡូវនេះយើងពិនិត្យមើលទៅលើទំព័រ៣២១ និង៣២២ នៃសៀវភៅដែលលោកនិពន្ធវិញ គឺថានៅក្នុងបញ្ហានោះ គឺនិយាយអំពីឋានានុក្រមនៃកម្មាភិបាលដែលប្រជាជនតាមមូលដ្ឋាន ក៏ដូចជាកម្មាភិបាលតាមមូលដ្ឋានត្រូវគោរព។ ឯកសារមានលេខ 00396529 ដល់ 30, ភាសាបារាំងមានលេខ 00639877។

ដូច្នេះ គឺថានៅក្នុងសៀវភៅរបស់លោក ជាដំបូងលោកបានរៀបរាប់អំពីឋានានុក្រម ហើយបន្ទាប់មកលោកនិយាយអំពីការអត់ឃ្លានដែលជាអាវុធតស៊ូមួយដ៏សំខាន់។ លោកបានរៀបរាប់ដូចតទៅនេះ៖ "ការសម្លាប់មន្ត្រីយោធា ក៏ដូចជាមន្ត្រីរាជការជាន់ខ្ពស់របស់របបសាធារណរដ្ឋ គឺជាការចាប់ផ្ដើមមួយ ហើយវាបានបញ្ជាក់អំពីការបញ្ចប់។ ប៉ុន្តែនៅក្នុងសហករណ៍ក៏ដូចជានៅក្នុង បញ្ហានៅក្នុងទីកន្លែងនានា គឺថានៅតែមានការសម្លាប់ប្រជាជនដែលបានល្មើសទៅនឹងបទបញ្ជា ក៏ដូចជាល្មើសទៅនឹងគោល-ការណ៍នានា។ ដូច្នេះហេតុទាំងអស់នេះគឺវាបង្ហាញអំពីនិន្នាការវណ្ណៈ ឬក៏ការកាប់សម្លាប់ទៅលើសមាសភាពមិនល្អ ឬក៏សមាសភាពដែលរំលោភទៅលើគោលការណ៍ច្បាប់ ច្បាប់នានា?

[១៥:២២:៥៤]

**ឆៈ** ចំណុចទី១ ដែលជាយុត្តិកម្មសម្រាប់ការធ្វើនេះ គឺថាអ្នកដែលធ្វើមិនល្អនៅក្នុងសហករណ៍។ ឧទាហរណ៍ដូចជា លួចស្វាយ ឬក៏លួច -- រើសផ្លែឈើទោះបីថា ផ្លែឈើហ្នឹងវាជ្រុះទៅលើដីក៏ដោយ ក៏គេចាត់ទុកជាការគិតខ្លួនឯង ដែលមិនគិតទៅដល់សហករណ៍។ នេះគឺជានិន្នាការរបស់អធន ដែលថាតម្រូវឲ្យប្រជាជនសហការគ្នា ហើយប្រព័ន្ធនេះ គឺវាខុសពីប្រព័ន្ធកុម្មុយនីស្តដទៃទៀត។ អ្វីដែលយើងចង់និយាយគឺថា ប្រសិនបើធ្វើខុសនៅពេលហ្នឹងគឺត្រូវគេសម្លាប់ ប៉ុន្តែចំពោះប្រទេសចិននិងប្រទេសដទៃទៀត គឺគេនឹងយកទៅរៀនសូត្រដោយសារ -- ដោយការឲ្យរៀន ឲ្យធ្វើការ ដោយចូលទៅក្នុងជំរំពលកម្មជាដើម។

**សៈ** សូមអរគុណលោក។ តើលោកអាចបញ្ជាក់ច្បាស់ដែរឬទេថា នៅពេលមួយ គឺនៅចន្លោះនៅក្រោយឆ្នាំ៧៥ ខែមេសា ឆ្នាំ៧៥ ថាតើមានការវិវត្ត ឬក៏មានការប្រែប្រួលបែបណាដែរឬទេទាក់ទង

ទៅនឹងគោលនយោបាយពីមុននេះ? តើលោកអាចបញ្ចេញមតិយោបល់ផ្ទាល់ខ្លួនរបស់លោកបានដែរឬទេ?

**ឆ៖** ខ្ញុំពិបាកក្នុងការបញ្ជាក់ឲ្យច្បាស់លាស់ ប៉ុន្តែយ៉ាងណាក៏ដោយ គឺវាមានឫសគល់ចេញពីសេចក្ដីសម្រេចពីមុន គឺសេចក្ដីសម្រេចដែលបានធ្វើឡើងនៅមុនឆ្នាំ៧៥។ ខ្ញុំគិតថាប្រសិនបើយើងពិនិត្យមើលនៅពេលដែលមានសម្ពាធកាន់ធ្ងន់ទៅលើកម្មាភិបាល ហើយកម្មាភិបាលត្រូវគោរពទៅតាមគោល-ការណ៍នយោបាយដែលរឹតបន្តឹងកាន់តែខ្លាំង វាអាចមានពេលខ្លះទៀតវាមានភាពងាយស្រួលផងដែរ។ ហេតុដូច្នេះហើយ គឺថានៅតាមទីតាំង ឬក៏ទីកន្លែងខុសៗគ្នា មានលក្ខណៈខុសៗគ្នា។

[១៥:២៤:៥៧]

**ស៖** សូមអរគុណលោក។ ឥឡូវនេះយើងបន្តទៅមុខទៀត។ ចំណុចមួយទៀតដែលលោករៀបរាប់អំពីរបបកម្ពុជាប្រជាធិបតេយ្យ និងសៀវភៅរបស់លោកផងដែរ គឺនិយាយអំពីបទដ្ឋានពីរ។ ប្រសិនបើខ្ញុំនិយាយច្រើនពេកសូមលោកបញ្ជាក់ខ្ញុំ គឺឯកសារនៅទំព័រ៣៤៦ ហើយនិងមានទំព័រ៣៤៨ ភាសាអង់គ្លេសមានលេខ 00639890, អង់គ្លេសមានលេខ 00396554 ហើយនិងបន្តបន្ទាប់ទៅមុខទៀត។ នៅទំព័រ៣៤៦ លោកនិយាយថា "មេដឹកនាំទាំងអស់ គឺតែងតែមានបង្ហាញរូបថតរបស់ ប៉ុល ពត, នួន ជា, ហើយនិង ខៀវ សំផន ដែលបង្ហាញអំពីរូបភាពផាត់ ហើយម្យ៉ាងទៀតវាជាការបង្ហាញអំពីរូបថតនៅតាមជនបទ នៅតាមទីស្រែចម្ការជាដើម"។ ហើយឃ្លាមួយទៀត នៅទំព័រ៣៤៨ គឺបានរៀបរាប់ថា "ប៉ុន្តែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺថាភាពខុសគ្នា គឺខុសគ្នាយ៉ាងខ្លាំង។ មិនត្រឹមតែឲ្យមានការគ្រប់គ្រងដោយក្រុមអ្នកដឹកនាំមួយចំនួនតូចទៅលើប្រជាជនភាគច្រើនប៉ុណ្ណោះទេ ប៉ុន្តែមានទាំងការប្រកាសមានទាំងការអប់រំ អំពីមនោគមន៍វិជ្ជា ក៏ដូចជាមូលដ្ឋានរបស់គោលនយោបាយជាតិ ក៏ដូចជាការពិចារ-ណានានា។ ការហាមប្រហាជាជនមិនឲ្យមាន ហើយឲ្យរករបស់ហូបជាដើមហ្នឹង គឺកើតឡើងនៅទូទាំងប្រទេស"។

តើលោកអាចពន្យល់ ឬក៏លោកអាចបញ្ជាក់បានច្បាស់នោះទេ នៅពេលដែលខ្ញុំប្រើពាក្យថា "ជាបទដ្ឋានពីរបែបនេះ" តើលោកអាចពន្យល់បានដែរឬទេ អំពីភាពខុសគ្នាបែបនេះ?

[១៥:២៧:២២]

**ឆ៖** ខ្ញុំមិនគិតថា លោកទៅឆ្ងាយនោះទេ គឺថាការប្រើវិធានខុសៗគ្នានោះ គឺថាយើងគួរឲ្យរន្ធត់ណាស់ គឺថាបើយើងមើលទៅវាមានលក្ខណៈដាច់ខាតនៅក្នុងតំបន់នានានោះ។ ប្រជាជននៃកម្ពុជាប្រជាធិបតេយ្យមិនមានអ្វីទេ គឺ ប៉ុន្តែកុម្មុយនីស្តផ្សេងៗទៀត ប្រព័ន្ធស្រដៀងដូចគ្នាហ្នឹង គឺនិយាយថា វរជន

គឺថាគេមានទទួលបានសេវា ប៉ុន្តែមហាជនមិនទទួលបាន។ ប៉ុន្តែប្រជាជនអាចទទួលបាននូវអ្វីៗខ្លះដែរ ដូចជានៅប្រទេសចិន សភាព អ៎! សហភាពសូវៀត។ ប៉ុន្តែគម្លាតនោះ គឺរវាងទាំងពីរនេះ គឺវាមានលក្ខណៈខុសគ្នា ប៉ុន្តែកម្ពុជាប្រជាធិបតេយ្យ គឺថាខុសពីគេទេ អ្វីៗដែលគេមាន គឺថាស្រដៀងទៅនឹងកុម្មុយនីស្តរបស់ប្រទេសផ្សេងៗដែរ។ ប៉ុន្តែប្រទេសកុម្មុយនីស្តផ្សេងៗទៀត គឺថាប្រជាជនគេមានអ្វីៗច្រើនជាង ប៉ុន្តែនៅកម្ពុជាប្រជាជនមិនមានអ្វីទេ មានតិចតួចណាស់របស់ទ្រព្យជាកម្មសិទ្ធិនោះ។

យើងមើលឧទាហរណ៍នៅក្នុងប្រព័ន្ធប្រវត្តិ គឺថានៅក្នុងស្តេចរបស់ប្រព័ន្ធកាតូលិកជាដើមហ្នឹង គឺថានៅក្នុងសម័យយុគសម័យនៅមុនសតវត្សរ៍ទី២០នោះ យើងមើល។

[១៥:២៨:៤៤]

**ស៖** សូមអរគុណ។ លើទំព័រនេះគឺមានខ្លឹមសារមួយដែលខ្ញុំចាប់អារម្មណ៍នៅខាងក្រោមនេះ ដែលលោកពិនិត្យមើលពីការព្រួយបារម្ភដែលលោកនិយាយថា ប៉ុល ពត ជាអ្នកជានិយាយទាក់ទងទៅនឹងប្រជាជនហ្នឹងទទួលបានអាហារគ្រប់គ្រាន់ សុខភាពល្អ អីជាដើម។ ហើយនិយាយការព្រួយបារម្ភរបស់គាត់នោះ គឺថាមិនសហករណ៍នោះ គឺថាមិនបរាជ័យទេ ប៉ុន្តែបុគ្គលនិយម គឺថាអាចនឹងងើបឡើង។ ហើយយើងបានដឹង ហើយគាត់ក៏បានយល់របាយការណ៍លម្អិតពីមេដឹកនាំហ្នឹង គឺផ្តល់ទៅគាត់រៀងរាល់សប្តាហ៍។ គាត់មិនគិតពីរឿងហ្នឹង ឬក៏គាត់ចាត់ទុកថារបាយការណ៍នោះមិនសំខាន់។ នេះមិនមែនជាការលើកលែងទេ នេះជាវិធាន។ ថាគោលការណ៍មនោគមន៍វិជ្ជា មនោគមន៍វិជ្ជាហើយនិងគោលការណ៍ហ្នឹង គឺថាត្រូវតែអនុវត្តមិនទាក់ទងថាត្រូវចំណាយអ្វី អាយុជីវិតអ្វីទេ។ សូមឲ្យលោកបំភ្លឺបន្ថែមជូនតុលាការអ្វីដែលលោករកឃើញ ទាក់ទងទៅនឹងយន្តការនៃធ្វើការរាយការណ៍ដែលថាគេបញ្ជូនព័ត៌មានទៅថ្នាក់មជ្ឈិម ឬក៏មេដឹកនាំកំពូលនោះ តើលោកអាចពន្យល់អ្វីបានបន្ថែមទេ?

**ឆ៖** មានសារទូរលេខមួយចំនួនបញ្ជូនពីភូមិភាគទៅមជ្ឈិម ដែលថាគេមិននិយាយពីការលំបាកដែលថាគេនិយាយអំពីវិទ្ធង្សនា គេនិយាយអំពីការលំបាកបង្កដោយធម្មជាតិ ប៉ុន្តែធ្វើឲ្យច្បាស់ ប៉ុន្តែថ្នាក់ដឹកនាំអាចនឹងដឹងច្បាស់ហើយថានៅតំបន់នោះមិនល្អទេ។ អៀង ធីរិទ្ធ, អៀង សារី ជាប្រពន្ធរបស់អៀង សារី បានធ្វើការទស្សនាសិក្សានៅភូមិភាគឧត្តរ ហើយត្រូវត្រឡប់មកវិញ ហើយនិយាយពីអ្វីដែលគាត់បានឃើញថាស្ថានភាពអាក្រក់ណាស់។ ហើយគេពន្យល់ថាជាវិទ្ធង្សនារបស់វៀតណាម ប៉ុន្តែគេបានឃើញពីស្ថានភាពអាក្រក់នៅតាមមូលដ្ឋាននោះហើយ។

[១៥:៣០:៥២]

**ស៖** សូមលោកពន្យល់បន្ថែមពីគំនិតនេះ អំពីការទទួលបានព័ត៌មានហ្នឹង។ លោកហាក់ដូចជាសន្និដ្ឋានថា មេដឹកនាំហ្នឹង គឺប្រកាន់ជាគោលការណ៍ ទោះបីជាការអនុវត្តខាងសម្ភារនិយមមិនត្រូវបានក៏ដោយ គឺគេប្រកាន់តែគោលការណ៍មនោគមន៍វិជ្ជាតែប៉ុណ្ណោះ គេមិនគិតថា លំបាក ឬក៏មានការបាត់បង់នោះទេ។ តើណាមួយមានប្រៀបជាង?

**ឆ៖** ឧទាហរណ៍ការដែលរកអ្វីៗហូបនោះ គឺជាការល្អ។ បើសិនជាគេអនុញ្ញាតឲ្យប្រជាជនរកអ្វីហូបតាមព្រៃ តាមអ្វីដែលគេរកបានហ្នឹង ដូចជា ដំណាំដែលគេដាំជិតៗផ្ទះនោះ ពេលនោះ គឺថាអាចហ្នឹងសុខភាព ហើយនិងមរណភាព អត្រាហ្នឹងទាបជាងអ្វីដែលកើតឡើង។ ប៉ុន្តែយើងមើលឃើញច្បាស់ហើយថា ឧទាហរណ៍ដូចជាប្រទេសចិន គេបង្ហាញច្បាស់ គេមិនហាមប្រជាជនមិនឲ្យរកអ្វីហូបទេ។ ប៉ុន្តែវិធីការតឹងតែងនោះ គេមិនចូលដល់ដាច់ខាតដូចខ្មែរក្រហមនេះទេ។ នៅទីនេះគឺកម្ពុជាមិនអនុញ្ញាតឲ្យប្រជាជនរកអ្វីហូបទាល់តែសោះ។ ពីព្រោះតែគោលនយោបាយខាងមនោគមន៍វិជ្ជា ពីព្រោះថាមានលក្ខណ:ស្រដៀងគ្នា។ របបនេះគឺថាដែលគេអនុវត្តទៅគឺថា គេអនុវត្តមិនឲ្យខុសពីគោលការណ៍ទេ។ គេគោរពទៅតាមគោលការណ៍របៀបដែកថែបរឹងមាំមិនអាចបត់បែនបាន។

[១៥:៣២:២៦]

**ស៖** សូមអរគុណ។ ខ្ញុំសូមអនុញ្ញាតទៅរកព្រឹត្តិការណ៍មួយ នៅទំព័រ៣០៨ ដល់ ៣០៩ ក្នុងសៀវភៅ ERN នោះ គឺបារាំង 00639853 ដល់ 854, អង់គ្លេស 00396516 ដល់ 7។ លោកបានរៀបរាប់ពីទស្សនកិច្ចទៅភូមិភាគនិរតីក្នុងខែសីហា ហើយធ្វើឲ្យមានការយល់ដឹងដល់ ប៉ុល ពត អំពីអ្វីៗដែលកម្មាភិបាលគ្រប់គ្រងនោះ រាយការណ៍ថា ខ្វះថ្នាំសង្កូវ ធ្វើឲ្យ -- ស្បៀងធ្វើឲ្យខ្វះកម្លាំងពលកម្ម។ លោកនិយាយថា "មិនមែនជាការឈឺចាប់របស់សមមិត្ត ប៉ុល ទេ។ ការខ្វះខាត់នូវស្បៀងអាហារពីលទ្ធភាពធ្វើការងារជាជាងយកស្រូវអង្ករមានកន្លែងផ្សេងទៀត។ ដំណោះស្រាយល្អបំផុតដែលគាត់សម្រេចនោះ គឺការបែងចែកពលកម្មឲ្យមានតុល្យភាព ស្របទៅតាមតម្រូវផលិតកម្មនៅក្នុងតំបន់។ នេះជាសញ្ញានៃចលនាជម្លៀសប្រជាជនទាំងមូល"។ ខាងក្រោមបន្តិច ឬក៏ខាងលើទំព័រ លោកនិយាយថា "ឥឡូវនេះដោយសារផលដំណាំកំពុងតែរីកដុះដាលទៅមុខហ្នឹង គឺថានៅក្នុងតំបន់ផ្សេងទៀតនោះ គឺថាមានតម្រូវការកម្លាំងជាច្រើន ហើយតែងតែរបបនេះ គឺប្រកាន់ទៅរកចេតនាក្នុងការកុហក" ហើយលោកនិយាយថា "ប្រហែលជាមនុស្ស១លានជាង ដែលត្រូវបានគេជម្លៀស"។

[១៥:៣៤:២៥]

ខ្ញុំមើលឯកសារចំនួនដែលលោកយោងទៅរក។ ឯកសារដែលយើងមានសំណុំរឿងហ្នឹង គឺ E3/216 ជាឯកសារមួយក្នុងចំណោមឯកសារដែលខ្ញុំបញ្ជូនទៅលោកគឺ E3/126 ដែលបញ្ជូនទៅគណៈ -- អចិន្ត្រៃយ៍បញ្ជូនទៅភូមិភាគឧត្តរនោះ គឺជាកំណត់ត្រាពីគណៈមជ្ឈិម ទស្សនកិច្ចទៅភូមិភាគពាយ័ព្យ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បីបង្ហាញឯកសារជូនអ្នកជំនាញ ដើម្បីឲ្យគាត់បានពិនិត្យមើល បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនអ្នកជំនាញពិនិត្យ!

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនអ្នកជំនាញ)*

[១៥:៣៥:២៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឥឡូវនេះ ខ្ញុំចង់បំភ្លឺអំពីទីតាំងនៃទស្សនកិច្ច។ បើខ្ញុំនិយាយខុសសូមកែតម្រូវខ្ញុំ។ លោកអាចពិនិត្យមើលឯកសារបកស្រាយរបស់ ឌី.ស៊ី.ខេម គឺថាគឺយើងបកប្រែឡើងវិញ ពីព្រោះគាត់បកប្រែខុស គឺថាដំណើរទស្សនកិច្ចមិនមែនទៅភូមិភាគនិរតីទេ គឺទៅភូមិភាគពាយ័ព្យ។ បាទ អ៊ីចឹងហើយសេចក្ដីសម្រេចនៅទីនោះ ឃើញថា ខ្ញុំសូមបំភ្លឺលោកពីលោកពីរឿងនេះ ដើម្បីឲ្យយើងថា យើងមើលឯកសារនេះតែមួយទេមិនមែនពីរខុសគ្នាទេ។

**លោក ហ្វីលីព ស្បូត៖**

**ឆ៖** កាលបរិច្ឆេទនោះគឺថាថ្ងៃទី២០ ដល់ថ្ងៃ២៤ ខែសីហា ឆ្នាំ១៩៧៥ លើឯកសារទាំងពីរ។ ខ្ញុំឆ្ងល់បន្តិច អង់គ្លេសបកប្រែនោះនិយាយខេត្តកំពង់សោមដែលស្ថិតនៅក្នុងភូមិភាគនិរតី ប៉ុន្តែនៅទីនេះគេនិយាយអំពីភូមិភាគពាយ័ព្យ។ ខ្ញុំគិតថាលោកនិយាយត្រូវហើយអាចជាកំហុសនៃការបកប្រែទៅដែលចំណុចខុសគ្នានោះ។

[១៥:៣៦:៥២]

**ស៖** បើយើងមើលទៅទំព័រដែលចាប់ផ្តើមនៅក្នុងអត្ថបទរបស់លោកជាភាសាអង់គ្លេសនោះ។ សូមមើលចំណុចមួយដែលខ្ញុំ ទំព័រទី៦ ដើម្បីឲ្យលោកដឹង។ ខ្មែរ ERN ហ្នឹងគឺ 00003492, បារាំង 00343379 ហើយនិងអង់គ្លេសគឺ 00850975 នៅចំណុចទី២ "មិនទាន់ម្ចាស់ការលើទឹក កម្លាំងមនុស្សមិនគ្រប់ត្រូវបន្ថែមកម្លាំងពលកម្ម ៣ ឬ ៤០០.០០០ ទៀតមិនគ្រប់។ កម្លាំង១លាននាក់ បច្ចុប្បន្នធ្វើបានតែ៥០ភាគរយទេ ត្រូវតែថែម ៤ ឬ៤០០.០០០ ទៀត"។

ឥឡូវនេះ តើសេចក្តីសម្រេចនេះវាទាក់ទងទៅនឹងអ្វីដែលព័ត៌មានដែលលោកបានប្រមូលទេ? តើវាទាក់ទងទៅការចលនាប្រជាជនដែលកើតឡើងនៅក្នុងភូមិភាគពាយ័ព្យដែរឬទេ?

**ឆ៖** បាទ វាពិតជាអ៊ីចឹងមែន។ សូមអនុញ្ញាតពីតុលាការ ខ្ញុំសូមនៅចុងថ្ងៃនេះបន្ទាប់ពីថ្ងៃនេះ ខ្ញុំចង់ពិនិត្យមើលឲ្យបានមើល ថាតើឯកសារណាខ្លះដែលខ្ញុំអាចនឹងរកបានដើម្បីយកជាមូលដ្ឋានឲ្យច្បាស់ ពីព្រោះខ្ញុំនៅសង្ស័យបន្តិចបន្តួចអំពីភាពខុសគ្នាអំពីព័ត៌មាននេះ។

**ស៖** ដោយមានការអនុញ្ញាតពីតុលាការ ពីលោកប្រធាន ខ្ញុំគិតថាមានសារប្រយោជន៍ណាស់ឲ្យលោកពិនិត្យឡើងវិញ។

**ឆ៖** សូមអរគុណ។

**ស៖** ឥឡូវនេះយើងបន្តមើលទៅការធ្វើចលនាផ្លាស់ប្តូរទីលំនៅប្រជាជន។ ផ្នែកដែលយើងមើលខាងដើម គឺថាជាចេតនារបស់របបនោះក្នុងការកុហកប្រជាជន។ សូមលោកនិយាយពន្យល់បន្ថែមទៀតថាតើលោកផ្អែកលើអ្វីបានលោកសន្និដ្ឋានបែបនេះ?

[១៥:៣៩:២២]

**ឆ៖** ការកុហកបែបនេះគឺថា គេកុហកថានឹងអនុញ្ញាតឲ្យប្រជាជនត្រឡប់ទៅភូមិកំណើត ទៅភូមិ -- ហើយគេនិយាយថាអ្នកណាមកពីភូមិស្រុកណាត្រូវត្រឡប់ទៅទីនោះវិញ។ ប៉ុន្តែតាមពិតគេមិនទៅភូមិកំណើតទេ គេត្រូវទៅសហករណ៍នៅភូមិភាគពាយ័ព្យឯណោះទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំបន្តទៅផ្នែកមួយនៅទំព័រក្នុងឯកសារនេះ លោកនិយាយដូចខាងក្រោមនេះ៖ "មិនមែនជានយោបាយដែលមិនសមស្របទេ ប៉ុន្តែពេលវេលាទេអាក្រក់ណាស់ ហើយគឺថាភូមិភាគពាយ័ព្យមិនអាចដោះស្រាយបានចំពោះប្រជាជនរាប់ម៉ឺននាក់នោះទេ គេមិនអាចចិញ្ចឹមបានដែលថាការប្រមូលភោគផលមិនបានគ្រប់សម្រាប់មនុស្សច្រើនទេ គេសម្រាប់តែមនុស្សភាគតិចនៅក្នុងភូមិ

ភាគទេ។ ប៉ុន្តែមូលហេតុនៃការជម្លៀសក្នុងខែមេសា នុំង គឺថា ប៉ុល ពត ហើយនិងអ្នករួមការងាររបស់គាត់គិតថា ប្រជាជនកម្ពុជាលែងជាមនុស្ស ជាបុគ្គលជានេះទៀតហើយ ម្នាក់ៗសង្ឃឹម ហើយនិងត្រូវភ័យខ្លាច ហើយនិងគេត្រូវតែធ្វើការ ហើយនិងត្រូវគោរពទៅតាមគោលការណ៍របស់គេ។ តើលោកអាចនឹងសម្រេចឈានដល់ការសន្និដ្ឋាននេះដោយផ្អែកលើអ្វីដែរ?

[១៥:៤០:៥៤]

**ឆ៖** លើកលែងតែខ្ញុំស្តាប់លោកនោះ គឺថាហើយគាត់និយាយថា ជាមេរៀនៗពីលើការ -- សម្រាប់ការជម្លៀសពីទីក្រុងភ្នំពេញ។ ពិតហើយ គឺថាគេចាត់ទុកថាប្រជាជននេះគឺគ្មានតម្លៃអីទេ គឺថាគោលដៅជាសញ្ញាបញ្ជាក់ពីវិធីដែលត្រូវធ្វើ។ ហេតុដូច្នេះហើយគេត្រូវថ្លឹងថ្លែងនោះទេ គេគិតថាគោលនយោបាយមាគ៌ាវាខ្ពស់ជាងប្រជាជន មានតម្លៃជាប្រជាជន។

**សៈ** តើលោកអាចនឹងពិចារណាលើផលប៉ះពាល់លម្អិតអំពីសេចក្តីសម្រេច និងការអនុវត្តនៃគោលនយោបាយរបស់គេហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំដូចជាស្ទាក់ស្ទើរ។ ខ្ញុំគិតថាមិនផ្អែកទៅលើស្ថិតិទេ ប៉ុន្តែមានកត្តាចង្អុលបង្ហាញថា អ្នកដែលត្រូវបានគេបញ្ជូនទៅភូមិភាគពាយ័ព្យហ្នឹង គឺថាមានការលំបាកច្រើនណាស់។ ខ្ញុំបាននិយាយទៅរកអ្នកបកប្រែចិននៅប៉េកាំង ដែលធ្លាប់មកកម្ពុជានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនៅរដូវមួយនោះបានរៀបរាប់ថា គាត់បានឃើញដំណើរ ក្បួនមនុស្សដើរតាមបណ្តោយផ្លូវពីខាងត្បូងទៅខាងជើង គឺថាការពិតនោះ ជាការបំលាស់ទីប្រជាជនដ៏ចំនួនច្រើន។ គាត់បានប្រាប់ខ្ញុំអ៊ីចឹងអ្នកបកប្រែនោះ។

[១៥:៤២:២៧]

**សៈ** សូមអរគុណ។ ឥឡូវនេះគឺខ្ញុំនឹងប្តូរទៅប្រធានបទថ្មី ហើយយើងដូចជាចុងនៅថ្ងៃនេះហើយលោកប្រហែលជានឿយហត់ខ្លាំង។ ប្រធានបទបន្ទាប់ដែលខ្ញុំនិយាយនោះ គឺខ្ញុំនិយាយអំពីព្រឹត្តិការណ៍ដែលលោកបានរៀបរាប់ភាគច្រើនទាក់ទងទៅនឹងចំណុចដែលខ្ញុំដកស្រង់ ជាពិសេសអំពីការអនុវត្តនូវក្បាលម៉ាស៊ីនប្រព័ន្ធសន្តិសុខរបស់គេ។ ហើយនិងបញ្ហាផ្សេងទៀតទាក់ទងនឹងបញ្ហានេះ។ ហើយខ្ញុំចាប់ផ្តើមដំបូងដែលលោកបានពណ៌នាផងដែរ ថាជាទស្សនៈមេដឹកនាំបានកំណត់ទាក់ទងទៅនឹងប្រជាជនដែលត្រូវបានជម្លៀស ហើយនិងការបោសសម្អាតនៅក្នុងជួរដែរ គឺថាពីបារាំង ERN 0063920, អង់គ្លេស 00396391។ តាមពិតយើងមើលទំព័រ១ គឺថាដោយសារពេលខ្លី ខ្ញុំអានផ្នែកសង្ខេបទេ។

សូមដកស្រង់៖ “យោធានៅគ្រប់ទីកន្លែង គឺថាត្រូវហ្វឹកហ្វឺន គឺថាឲ្យធ្វើការងារដោយមិនគិត

ពីការខូចខ្លាច -- អន្តរាយនោះទេ ខ្មែរក្រហមគឺថា មិនអើពើនឹងអ្វីៗនោះទេ។ ប៉ុន្តែបរិបទនយោបាយ គឺ អនុញ្ញាតឲ្យពួកគេធ្វើអ្វីដែលគេចង់ គឺថាដូចដែលកំណត់ដោយលោក ប៉ុល ពត ហើយនិងគណៈ អចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា"។ នៅខាងក្រោម "មេដឹកនាំផ្សេងៗដែលមានមនោគមន៍ខុសគ្នា អាចនឹងជ្រើសរើសនយោបាយសម្របសម្រួលជាតិ ផ្សះផ្សាជាតិ។ ប៉ុន្តែ ប៉ុល សម្រេចផ្សេងពីនេះ ចំពោះគាត់ អ្នកក្រុង ហើយអ្នកកសិករដែលចូលរួមគាត់នៅចុង -- ប៉ុន្មានខែចុងក្រោយ គេនឹងគោរព សិទ្ធិឲ្យសេរីភាពពួកហ្នឹងទៅតាមហ្នឹង។ បន្ទាប់ទៅទៀត យោធាក៏ត្រូវបានឲ្យកាត់ចិត្តកាត់ថ្លើមចំពោះ ពួកខ្មាំង ជាពិសេសចំពោះអ្នកដែលជម្លៀសមកពីទីក្រុង"។

[១៥:៤៤:៥៣]

ខ្ញុំសូមចាប់ផ្តើមផ្នែកចំណុចចុងក្រោយទស្សនៈដែលថា អ្នកដែលជម្លៀសមកពីទីក្រុង ពីជាយក្រុង ហ្នឹងគេចាត់ទុកថា "ជាខ្មាំង" ហើយជាការណែនាំទៅដល់យោធាឲ្យចាត់អ្នកទាំងអស់ហ្នឹងជាខ្មាំងហ្នឹង។ តើលោកអាចពន្យល់តុលាការអ្វីបន្ថែមបានខុសពីអ្វីដែលសរសេរក្នុងសៀវភៅទេ?

**ឆ៖** នេះជាព័ត៌មានស៊ីសង្វាក់គ្នាដែលដូចដែលយើងរៀបរាប់ដែលថាគោលដៅ វាជាកត្តាកំណត់ ពីមធ្យោបាយដែលគេត្រូវធ្វើ បើអ្នកណាជាខ្មាំង គេត្រូវចាត់ការដូចម្តេច អ្នកណាដែលត្រូវសម្រេចចិត្ត ថានៅក្នុងក្រុង ឬក៏ចេញពីក្រុងទៅចូលខាងខ្មែរក្រហមហ្នឹង អាហ្នឹងគឺគេត្រូវបែងចែកតាមហ្នឹង។ ខ្ញុំបាន សរសេរផ្នែកទៅលើមនោគមន៍វិជ្ជាខុសៗគ្នា វិធីសាស្ត្រខុសៗគ្នាដែលត្រូវបានកំណត់ថាបើអ្នកណាជ្រើស រើសយកការផ្សះផ្សាជាតិ សម្រុះសម្រួលដូចជាមួយក្រុមផ្សេងទៀតហ្នឹងគឺថាបើសិនជាធ្វើឲ្យគេទុកចិត្ត គេនឹងធ្វើការជាមួយអ្នកនោះ។ ប៉ុន្តែចរិតលក្ខណៈនៃបក្សកុម្មុយនីស្តកម្ពុជានោះគឺថា គឺជាការខ្វះការទុក ចិត្តទៅលើអ្នកណាទាំងអស់ដែលនៅក្រៅបក្សនោះ គឺមិនទុកចិត្តទាំងអស់។ តាមពិតគឺគេសង្ស័យអ្នក ណាក៏ដោយដែលនៅក្នុងបក្សដែលនាំឲ្យមានការបោសសម្អាត គឺថាការដែលគ្មានសេចក្តីទុកចិត្តលើអ្នក ណាម្នាក់ អានេះហើយគឺជាបញ្ហារបស់របបនោះឯង។

[១៥:៤៦:២៨]

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅដល់ទស្សនៈមួយដែលយើងមិនទាន់បាននិយាយដល់នោះទេ គឺនេះចេញ មកអំពីទង់បដិវត្ត ដូចគ្នាហ្នឹងខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយយើងខ្ញុំបានជូនឯកសារនេះទៅ លោករួចហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន នេះឯកសារ E3/748។ សូមការអនុញ្ញាតដើម្បីជូនឯកសារនេះទៅអ្នកជំនាញនូវទំព័រដែលយើងខ្ញុំនឹងយោងបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនអ្នកជំនាញពិនិត្យ!

[១៥:៤៧:២៧]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** បាទ អត្ថបទដែលលោកបានទទួលហើយ ទំព័រទី២ ERN ដែលពាក់ព័ន្ធនោះគឺខ្មែរ 0063283, ហើយបន្ទាប់មកបារាំង 00499685, អង់គ្លេស 00495802។ នេះជាឯកសារវែង អ៊ីចឹងខ្ញុំនឹងស្រង់យកចំណុចដែលពាក់ព័ន្ធជាងគេបំផុត។ សូមដកស្រង់ "ការគ្រប់គ្រងគោលជំហរដ៏រឹងមាំតាមមាគ៌ាបក្ស និងវណ្ណៈបក្សនោះ គឺមិនបណ្ដែតបណ្ដោយការធ្វេសប្រហែសណាដើម្បីឲ្យខ្មាំងជ្រៀតចូលក្នុងបក្ស ឬក៏ជួរបក្សនៅក្នុងអនាគត ក៏ទៅដូចជាបច្ចុប្បន្ននោះដែរ"។ នៅក្នុងកថាខណ្ឌបន្ទាប់ "នៅពេលដែលបក្សមានកម្លាំងគ្រប់ អំណាចទូទាំងបក្សហើយ គឺថាការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ ជាកត្តាសំខាន់មួយក្នុងការនាំមកជ័យជម្នះដល់បដិវត្តន៍។ អង្គការគ្មានគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍ ខ្មាំងរបស់បដិវត្តន៍វាអាចដណ្ដើមយកអំណាចបាន។ ដូច្នេះគ្រប់ពេលវេលា ជនកុម្មុយនីស្តត្រូវតែពង្រឹងគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍ឲ្យរឹងប៉ឹងជានិច្ចដើម្បីវាយកម្ទេចគ្រប់ឧបាយកលសម្ងាត់ និងជំហររបស់ចក្រពត្តិគ្រប់ប្រភេទ ជាពិសេសសម្រេចចក្រពត្តិអាមេរិក និងបរិវាររបស់វា ទើបយើងការពារប្រទេសបាន"។

[១៥:៤៩:២០]

យើងមើលពេលវេលាឯកសារហ្នឹងគឺថាខែតុលា វិច្ឆិកា ឆ្នាំ១៩៧៥។ ហើយលោកបាននិយាយអំពីហេតុការណ៍ឆ្នាំ១៩៧៦ ក្នុងសៀវភៅរបស់លោក។ តើលោកអាចសម្ដែងមតិអ្វីជូនតុលាការបានទាក់ទងពីការអនុវត្តនូវគោលការណ៍និយាយពីខ្មាំងស៊ីរូងផ្ទៃក្នុង ឬក៏ខ្មាំងបង្កប់ក្នុងជួរបក្សរបស់គេនោះ?

**លោក ហ្វីលីព ស្សូត៖**

**ឆ៖** ជាថ្មីម្ដងទៀត វាបង្ហាញពីភាពស៊ីសង្វាក់គ្នា គឺថាលោកនិយាយត្រូវហើយតាំងពីដំបូងមកខែតុលា វិច្ឆិកា ប្រហែលគេសរសេរក្នុងខែតុលានោះហើយ។ គឺវិច្ឆិកា ឆ្នាំ១៩៧៥ គឺជាពេលវេលាពី

ទស្សនៈរបស់របបនោះវិញ។ និយាយគឺថាខ្មាំងរបស់បក្សបដិវត្ត គឺបង្កប់ផ្ទៃក្នុង វាមិនមែនជាបញ្ហាជាក់ស្តែងមើលឃើញទេ។ ប៉ុន្តែគេអាចនឹងរកឃើញថា មានឯកសារពីមុន ឆ្នាំ១៩៧៥ទេ។ នេះហើយគឺជាជំហរ គោលជំហរស៊ីសង្វាក់របស់ពួកគេ នៅពេលដែលទំនាក់ទំនងរវាងវៀតណាម កាន់តែលំបាកនៅក្នុងឆ្នាំ១៩៧៦ជាដើម។ ដូច្នេះហើយ គឺវាមានលក្ខណៈជាទ្រឹស្តី ជាបញ្ហាដែលក្លាយទៅជាការអនុវត្តវិញហើយ។

[១៥:៥០:៤៩]

**ស៖** ឥឡូវនេះ គឺយើងចូលទៅដល់ហេតុការណ៍មុនឆ្នាំ១៩៧៦ ចាប់ផ្តើមពីទំព័រ៣៥៤ នៅក្នុងសៀវភៅរបស់លោក។ បាទជាជំពូកថ្មីមួយ ខ្ញុំនឹងអានចេញពីទំព័របន្ទាប់នេះ។ ខ្ញុំនឹងអានទៅទំព័រ ERN នោះ គឺបារាំង 00639921, ហើយអង់គ្លេស 00396563។ រៀបរាប់នៅទីនេះ នៅការរាំងខ្ទប់មួយនៅខេត្តសៀមរាប។ ហើយនៅទំព័របន្ទាប់ -- នៅទំព័រខាងក្រោមទេ សូមទោស -- ហើយនិងទំព័របន្ទាប់ ហើយលោកបាននិយាយដូចខាងក្រោមនេះ៖

នៅចុងខែមីនា ហ៊ូ នឹម បានជូនដំណឹងពីរឿងអាស្រូវ កុយ ធួន នូវភូមិភាគឧត្តរ ឥឡូវនេះជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ ហើយគាត់បានរៀបរាប់ពីព័ត៌មានជាក់លាក់ដែលបានផ្តល់ទៅឲ្យ ប៉ុល ពត អំពី កុយ ធួន។ ហើយគាត់និយាយថា ចំពោះ ប៉ុល ពត នេះលើកឡើងពីបញ្ហាធ្ងន់ធ្ងរ។ អាកប្បកិរិយារបស់ ធួន នេះ គឺថាផ្ទុយពីជំហរបដិវត្តន៍។ សៀមរាប គឺស្ថិតនៅក្នុងភូមិភាគដែលគាត់ដឹកនាំ ហើយសុត ជាអ្នករួមការងារ។ តើ ធួន អាចនឹងគេឆ្លើយដាក់ទេ? ហើយត្រូវដាក់គាត់នៅក្នុងកំហាត់លំនៅនៅក-១ ជាអតីតធនាគារ។ រីឯបន្ទាប់មកទៀតគឺ ឌឿន ជាប្រធានគណៈមជ្ឈិម អគ្គសេនាធិការ។ ហើយបន្ទាប់មក ឌឿន អាចនឹងជាអ្នកលាក់កំបាំងនោះ ហើយនៅក្នុងកម្ពុជាប្រជាធិបតេយ្យ វាអាចចាប់ផ្តើមគេមើលថា ជាការរួមគំនិតរវាងភូមិភាគឧត្តរដើម្បីផ្តួលរំលំរបបនេះ។

មានហេតុការណ៍ទាក់ទងនោះមួយចំនួន ដោយសារ -- សូមឲ្យលោកសម្តែងមតិទាក់ទងទៅនឹងថាតើការវិវត្តហេតុការណ៍នីមួយៗនេះ លោកមើលឃើញដូចម្តេចដែរ?

[១៥:៥៣:២១]

**ឆ៖** យើងមិនច្បាស់ថា តើមជ្ឈិម ប៉ុល ពត ហើយនិង នួន ជា ទាក់ទង គឺថាបានដឹងច្បាស់ពីអ្វីដែលបានកើតឡើងនៅសៀមរាប។ ប៉ុន្តែតាមពិត គឺថាមានអ្វីកើតឡើង គេមានរបាយការណ៍មកគណៈអចិន្ត្រៃយ៍ មានកំណត់ហេតុ។ អៀង សារី ប្រាប់ខ្ញុំថាវាមិនមែនជាការបះបោរទេ។ មានអ្វីធ្ងន់ធ្ងរ

កើតឡើងដែលរំខានដល់ពួកគាត់។ បន្ទាប់មកមានកត្តាផ្សេងៗទៀតវាពាក់ព័ន្ធដែរ។ ចំពោះរបបនេះដែលងាយនឹងរងនូវការភ័យខ្លាច បែបសត្វត្រដេវវិចនេះ គឺថា រឿងអីតិចតួចគេចាត់ទុកថាជាអំពើក្បត់ហើយ ជាការសមគំនិតដើម្បីផ្តួលគេហើយ។ ដូច្នេះហើយជាឧបហេតុទីមួយដែលកើតឡើង។ ហើយជាហេតុការណ៍ដែលជំរុញឲ្យមានការប្រុងប្រយ័ត្នជាតាមទ្រឹស្តី។ បើសិនជាយើងត្រឡប់ទៅក្រោយ៧៥ ឬក៏មុនហ្នឹង វាចាប់ផ្តើម គេថាអាចជាអាកប្បកិរិយាដ៏សំខាន់ ដោយហេតុថា អាចមានភស្តុតាងជាការវាយប្រហារ ហើយនិងអំពើក្បត់ជាក្រុមហ្នឹង។ ដូច្នេះហើយ គេនឹង -- ពេលនោះ គេពិនិត្យមើលអ្វីៗជាលទ្ធភាពដែលអាចនឹងកើតបែបនេះទៀត។

[១៥:៥៤:៤០]

**ស៖** នៅក្នុងផ្នែកនៃសៀវភៅនេះ ក្នុងផ្នែកដែលខ្ញុំអាននេះ គឺថាលោកបាននិយាយពីបុគ្គលម្នាក់ឈ្មោះ សុត ប៉ុន្តែនៅក្នុងផ្នែកផ្សេងទៀត ដែលអំពីរបាយការណ៍ដែលគេរាយការណ៍ទៅគណៈអចិន្ត្រៃយ៍អំពីហេតុការណ៍នៅសៀមរាប។ ហើយខ្ញុំចង់បង្ហាញឯកសារមួយផ្សេងទៀតដែរ ដែលយើងខ្ញុំបានបញ្ជូនដែរ ជាកំណត់ហេតុអង្គប្រជុំអំពីការងារមូលដ្ឋាន ចុះថ្ងៃទី១៨ មីនា ឆ្នាំ១៩៧៦។ ឯកសារនោះគឺ E3/132 បាទ -- 232 បាទ *ស្លាក*ខាងក្រោយ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនអ្នកជំនាញពិនិត្យ!

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនអ្នកជំនាញ)*

[១៥:៥៥:៣៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានសូមអនុញ្ញាតថា យើងខ្ញុំសូមបង្ហាញនៅលើអេក្រង់ ដើម្បីឲ្យមានអត្ថបទភាសាខ្មែរពីខាងប្រព័ន្ធសោតទស្សន៍ដើម្បីជាប្រយោជន៍ដល់អ្នកអានភាសាខ្មែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ បុគ្គលិកសោតទស្សន៍ដាក់បង្ហាញឯកសារលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រតាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**ស៖** ទំព័រទី១ នៃឯកសារនេះ លោក ស្បូត នៅលើអេក្រង់នេះជាអត្ថបទខ្មែរទេ ជាច្បាប់ដើម។ សមាសភាពនៃអង្គប្រជុំនោះ គឺសមមិត្តលេខា, សមមិត្តអនុលេខា និងសមមិត្តហែម រួមទាំងសមមិត្ត ខឿន។ ដើម្បីជាកំណត់ត្រាតុលាការសូមឲ្យលោកបញ្ជាក់ថា តើលោកយល់ថាឈ្មោះទាំងអស់នេះអ្នកណាខ្លះ?

[១៥:៥៦:៣៨]

**លោក ហ្វីលីព ស្បូត៖**

**ឆ៖** សមមិត្តលេខាគឺ ប៉ុល ពត, សមមិត្តអនុលេខា នួន ជា, សមមិត្តហែម គឺ ខៀវ សំផន។

**ស៖** បាទ គ្រប់គ្រាន់ ចុះសមមិត្ត ខឿន?

**ឆ៖** ក្នុងគំនិតរបស់ខ្ញុំ ខ្ញុំស្គាល់គាត់តែសមមិត្ត ខឿន ទេ ដែលខ្ញុំសរសេរក្នុងសៀវភៅ។ ជាឈ្មោះបដិវត្តន៍របស់គាត់ទេ។ ខ្ញុំមិនបាច់លម្អិតជាងហ្នឹងទេ។

**ស៖** តើ ខឿន ដដែលដែលលោកនិយាយក្នុងសៀវភៅទេ?

**ឆ៖** បាទ តាមពិតគឺថា ខឿន ដែលយើងបាននិយាយដល់នោះឯងជាប្រធានរបស់មន្ទីរនយោបាយរបស់បក្សនោះឯង។

**ស៖** ក្នុងឯកសារនេះគឺថា យើងឃើញថាមានរបាយការណ៍ពីបុគ្គលបីរូបមាន : ស្រេង, មានសុត, មានហុង បាទ នៅតំបន់១០៦ និង១០៣ បាទ។ ១០៦ គឺសមមិត្ត សុត ហើយគាត់រាយការណ៍នេះចង្អុលថា គឺមិនមានមូលហេតុនៃហេតុការណ៍នៅសៀមរាបទេ គាត់រកមិនឃើញទេពីមូលហេតុ។ តើនេះជាព័ត៌មានដែលលោកពិនិត្យមើលទេនៅពេលដែលលោកអានសៀវភៅនោះ? លោកបានអានត្រង់ចំណុចនេះទេ?

[១៥:៥៨:១២]

**ឆ៖** បាទ តាមពិត ហើយឯកសារនេះឯងជាប្រភពសម្រាប់ដែលខ្ញុំសិក្សានោះ។

**ស៖** ឥឡូវឈានមួយជំហានថយក្រោយ អំពីរបាយការណ៍របស់ ស្រេង ទាក់ទងទៅនឹងតំបន់៣០៣។ របាយការណ៍នោះគឺថា និយាយគឺថា "សមមិត្តស្រេងរាយការណ៍ជូនអង្គការអំពីសកម្មភាពរបស់ អាងួន ដែលថាមានមនុស្ស ៣៤នាក់មកពីយោធាភូមិភាគត្រូវបានចាប់ខ្លួនរួចហើយ។ ក្រុមអា

អ៊ុក ម៉ុន ឈ្មោះ អ៊ុក ហុង ប៉ុនប៉ងចង់រត់ទៅវៀតណាមខាងត្បូង ហើយនិង -- ហើយសូមការណែនាំពីអង្គការ"។

ដោយសារពេលវេលាខ្លីខ្ញុំអានរបាយការណ៍របស់ ហុង នោះទាក់ទងទៅនឹងតំបន់១០៣ ទាក់ទងទៅនឹងខ្លឹមសារដូចខាងក្រោមនេះ។ "ចំពោះតំបន់ទាំងមូលមិនមានសកម្មភាពខ្លាំងទេ មានតែក្រុមដែលរត់ចេញពីកន្លែងមួយទៅកន្លែងមួយដូចជារត់ពីតំបន់៣០៣ ឬពីកំពង់ឆ្នាំងតាំងពីខែមករារហូតដល់ពេលនេះគឺយើងចាប់បានជិត ១០០នាក់ហើយ"។

[១៥:៥៩:៣៤]

ដោយសារការសិក្សារបស់លោកនោះ តើលោកឃើញថាអាចនឹងបង្ហាញថានេះជារបាយការណ៍ជាប្រព័ន្ធរបាយការណ៍គេបញ្ជូនពីថ្នាក់ក្រោមទៅថ្នាក់លើរបស់គេទេ ទៅមេដឹកនាំទាក់ទងទៅនឹងពីចំនួនមនុស្សពីការចាប់ខ្លួនអីជាដើមហ្នឹង។

**ឆ៖** នេះជាប្រព័ន្ធគំរូហើយដែលខ្ញុំឃើញឯកសារដែលទទួលបានពីពេលនោះជាសារទូរលេខ ឬក៏កំណត់ហេតុអង្គប្រជុំ សេចក្ដីលម្អិត លក្ខខណ្ឌនៅតាមមូលដ្ឋាន ការរំខានការងាររបស់គេ គេរាយ-ការណ៍។ នេះហើយជាឯកសារជាស្តង់ដារដែលគេរាយការណ៍ឡើងចុះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន សូមជម្រាបថាឥឡូវនេះពេលវេលាដូចជាដល់ពេលសម្រាកពេលល្ងាច។ ដូច្នេះតើខ្ញុំត្រូវបន្ត ឬក៏លោកប្រធានផ្អាកពេលនេះសិន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកអ្នកជំនាញ ឥឡូវដល់ពេលសម្រាកហើយ កិច្ចដំណើរការសម្រាប់ថ្ងៃនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០៨ ខែឧសភា ឆ្នាំ២០១៣ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សីអ្នកជំនាញ ហ្វីលីព ស្សូត ដែលនឹងបន្តសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលព្រឹក និងនៅពេលរសៀលនឹងផ្ដើមសួរដេញដោលដោយក្រុមមេធាវីការពារក្ដីទាំងពីក្រុម។ ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្ដី នួន ជា មុន។ សូមភាគីនៃរឿងក្ដី និងសាធារណជនជ្រាប។

[១៦:០១:១៣]

លោក ហ្វីលីព ស្មូត ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះក៏សូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ហ្វីលីព ស្មូត ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការនេះវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនមួយនៅពីក្រោមសាលសវនាការនេះ ដើម្បីឲ្យគាត់ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*